# នីតិវិធីនៃការអនុវត្តហ៊ីប៉ូតែក

# មាតិកា


ផ្នែកទី ១ ការរឹបអូស ........ ១

ដំណាក់កាលទី ១. ការរៀបចំការដាក់ពាក្យ ........ ១

សំណួរទី ១៖ តើត្រូវធ្វើដូចម្ដេច ទើបអាចទទួលបានឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត? ........ ២

សំណួរទី ២៖ តើធ្វើដូចម្ដេចទើបអាចទទួលបានរូបមន្តអនុវត្ត? ........ ៤

សំណួរទី ៣៖ តើត្រូវធ្វើដូចម្ដេចទើបអាចទទួលបាននូវលិខិតបញ្ជាក់អំពីការបញ្ជូន? ........ ៥

សំណួរទី ៤៖ តើធ្វើដូចម្ដេចទើបអាចទទួលបាននូវឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ? ........ ៥

ដំណាក់កាលទី ២. ការធ្វើពាក្យសុំ ........ ៦

សំណួរទី ៥៖ តើត្រូវសរសេរអ្វីខ្លះនៅក្នុងពាក្យសុំឲ្យអនុវត្តហ៊ីប៉ូតែក? ........ ៦

សំណួរទី ៦៖ តើពាក្យសុំឲ្យអនុវត្តហ៊ីប៉ូតែកត្រូវភ្ជាប់ជាមួយនឹងឯកសារអ្វីខ្លះ? ........ ៧

ដំណាក់កាលទី ៣. ការដាក់ពាក្យសុំ ........ ៧

សំណួរទី ៧៖ តើសោហ៊ុយសម្រាប់ការអនុវត្តជាបន្ទុករបស់អ្នកណា? ........ ៧

សំណួរទី ៨៖ តើពាក្យសុំឲ្យអនុវត្តហ៊ីប៉ូតែកត្រូវដាក់នៅតុលាការណា? ........ ៨

ដំណាក់កាលទី ៤. ការពិនិត្យពាក្យសុំ ........ ៨

សំណួរទី ៩៖ តើត្រូវសរសេរអ្វីខ្លះនៅក្នុងដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ? ........ ៨

សំណួរទី ១០៖ តើតុលាការអនុវត្ត ត្រូវធ្វើដូចម្ដេចក្នុងករណីដែលឈ្មោះរបស់អ្នកបង្កើតហ៊ីប៉ូតែកដែលបានសរសេរនៅក្នុងលិខិតអនុវត្ត ខុសពីឈ្មោះរបស់កម្មសិទ្ធិករ ដែលបានសរសេរនៅក្នុងឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ? ........ ៩

សំណួរទី ១១៖ ក្នុងករណីដែលតុលាការអនុវត្តបានចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំលើដីបន្ទាប់មកក៏មានពាក្យសុំឲ្យអនុវត្តហ៊ីប៉ូតែក តើតុលាការអនុវត្តត្រូវធ្វើដូចម្ដេច? ........ ១០

ដំណាក់កាលទី ៥. ការលើកចោលពាក្យសុំ ........ ១១

ដំណាក់កាលទី ៦. ដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំ ........ ១១

**សំណួរទី ១២៖** ហេតុអ្វីបានជានៅក្នុងដំណាក់កាលនេះ ការមិនទាន់បញ្ជូនដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំទៅកូនបំណុលនៃការអនុវត្តគឺ ការល្អជាង? ........ ១២

**ដំណាក់កាលទី ៧. ការផ្ទុកផ្ដាក់ឲ្យចុះបញ្ជីរឹបអូស** ........ ១២

**សំណួរទី ១៣៖** តើលិខិតផ្ទុកផ្ដាក់ឲ្យចុះបញ្ជីត្រូវបង្កើតឡើងដោយរបៀបណា? ........ ១២

**សំណួរទី ១៤៖** តើត្រូវបង់សោហ៊ុយ និង ពន្ធដែលពាក់ព័ន្ធនឹងការចុះបញ្ជីយ៉ាងដូចម្ដេច? ........ ១៤

**ដំណាក់កាលទី ៨. ការចុះបញ្ជីអំពីការរឹបអូស** ........ ១៤

**សំណួរទី ១៥៖** តើមន្ត្រីចុះបញ្ជីដែលបានទទួលលិខិតផ្ទុកផ្ដាក់អំពីការចុះបញ្ជី ត្រូវសរសេរអ្វីខ្លះនៅក្នុងសៀវភៅគោលបញ្ជី? ........ ១៤

**សំណួរទី ១៦៖** តើមន្ត្រីចុះបញ្ជីត្រូវធ្វើដូចម្ដេចក្នុងករណីឈ្មោះរបស់កូនបំណុលនៃការអនុវត្តដែលបានសរសេរនៅក្នុងលិខិតផ្ទុកផ្ដាក់ខុសពីឈ្មោះដែលបានសរសេរនៅលើឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ? ........ ១៥

**សំណួរទី ១៧៖** ក្នុងករណីដែលអចលនវត្ថុហ៊ីប៉ូតែកតែមួយត្រូវបានចុះបញ្ជីអំពីការរឹបអូសរួច ហើយត្រូវបានផ្ទុកផ្ដាក់ឲ្យចុះបញ្ជីអំពីរឹបអូសបន្ថែមទៀត តើមន្ត្រីចុះបញ្ជីត្រូវធ្វើដូចម្ដេច? ........ ១៥

**សំណួរទី ១៨៖** ក្រោយការចុះបញ្ជីអំពីការរឹបអូស តើកូនបំណុលនៃការអនុវត្តអាចបន្តការប្រើប្រាស់អចលនវត្ថុហ៊ីប៉ូតែកបានដែរឬទេ? ........ ១៥

**សំណួរទី ១៩៖** ក្រោយពីបានចុះបញ្ជីអំពីការរឹបអូសផ្អែកតាមហ៊ីប៉ូតែករបស់ម្ចាស់បំណុល X កូនបំណុលនៃការអនុវត្តបានបង្កើតហ៊ីប៉ូតែកលើអចលនវត្ថុដើម្បីធានាបំណុលឲ្យ A ហើយក៏បានទៅចុះបញ្ជីរួមគ្នាជាមួយ A ។ លើសពីនេះ កូនបំណុលនៃការអនុវត្តបានលក់អចលនវត្ថុនោះទៅឲ្យ B ហើយក៏បានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិជាមួយ B ។ តើមន្ត្រីចុះបញ្ជីត្រូវធ្វើដូចម្ដេច? ........ ១៦

**ដំណាក់កាលទី ៩. ការបញ្ជូនឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ** ........ ១៧

**ដំណាក់កាលទី ១០. ការបញ្ជូនដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំទៅកូនបំណុលនៃការអនុវត្ត** ........ ១៧

**ផ្នែកទី ២ ការលក់**..........១៧

**ជំណាក់កាលទី ១១. ដីកាសម្រេចកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក និង ការប្រកាសជាសាធារណៈ**..........១៨

**ជំណាក់កាលទី ១២. ការទាមទារឲ្យចែកចំណែក**..........១៨

**សំណួរទី ២០៖** តើអ្នកណាខ្លះដែលអាចទាមទារឲ្យចែកចំណែកបាន?..........១៩

**សំណួរទី ២១៖** តើការទាមទារឲ្យចែកចំណែកត្រូវធ្វើឡើងយ៉ាងដូចម្ដេច?..........១៩

**សំណួរទី ២២៖** តើតុលាការអនុវត្តដែលបានទទួលការទាមទារឲ្យចែកចំណែកត្រូវធ្វើដូចម្ដេច?..........១៩

**ជំណាក់កាលទី ១៣. ការជាស់តឿនឲ្យរាយការណ៍អំពីសិទ្ធិលើបំណុល**..........២០

**សំណួរទី ២៣៖** ប្រសិនបើ ម្ចាស់បំណុលដែលទទួលការជាស់តឿន មិនបានរាយការណ៍អំពីសិទ្ធិលើបំណុល តើតុលាការអនុវត្តត្រូវធ្វើដូចម្ដេច?..........២០

**ជំណាក់កាលទី ១៤ . ការវាយតម្លៃ**..........២០

**សំណួរទី ២៤៖** ប្រសិនបើអ្នកកាន់កាប់អចលនវត្ថុហ៊ីប៉ូតែក មិនចូលរួមសហការក្នុងការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្នទេ តើអ្នកវាយតម្លៃត្រូវធ្វើដូចម្ដេច?..........២១

**សំណួរទី ២៥៖** តើអ្នកវាយតម្លៃត្រូវធ្វើការគណនានូវចំនួនទឹកប្រាក់នៃការវាយតម្លៃដោយរបៀបណា? ២១

**ជំណាក់កាលទី ១៥. ឯកសារលំអិតអំពីវត្ថុ**..........២២

**សំណួរទី២៦៖** ប្រសិនបើខ្វះខាតរបាយការណ៍ក្នុងការធ្វើឯកសារលំអិតអំពីវត្ថុ តើតុលាការអនុវត្តត្រូវធ្វើដូចម្ដេច?..........២២

**ជំណាក់កាលទី ១៦. ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា**..........២៣

**សំណួរទី ២៧៖** តើតម្លៃលក់អប្បបរមាត្រូវកំណត់យ៉ាងដូចម្ដេច?..........២៣

**ជំណាក់កាលទី ១៧. ការបង្គាប់ឲ្យអនុវត្តការលក់**..........២៣

**ជំណាក់កាលទី ១៨. ការប្រកាសជាសាធារណៈនូវកាលបរិច្ឆេទនៃការលក់ជាអាទិ៍ និង ការទុកឯកសារលំអិតអំពីវត្ថុជាអាទិ៍**..........២៣

**សំណួរទី ២៨៖** តើតុលាការអនុវត្តត្រូវធ្វើដូចម្ដេច ប្រសិនបើការសរសេរនៅក្នុងឯកសារលំអិតអំពីវត្ថុមានកំហុស ហើយតម្លៃលក់អប្បបរមាទាបពេក?..........២៣

**ដំណាក់កាលទី ១៩. ការអនុវត្តការលក់** ....................................................................................... ២៤

**សំណួរទី ២៩៖** តើម្ចាស់បំណុលនៃការអនុវត្តអាចធ្វើសំណើទិញបានដែរ ឬទេ? ................................ ២៤

**សំណួរទី ៣០៖** តើកូនបំណុលនៃការអនុវត្តអាចធ្វើសំណើទិញបានដែរ ឬទេ? ..................................... ២៥

**សំណួរទី ៣១៖** ក្នុងករណីដែលគ្មានជនដែលមានគោលបំណងទិញសូម្បីតែម្នាក់ តើតុលាការអនុវត្តត្រូវធ្វើដូចម្ដេច? ....................................................................................................... ២៥

**ដំណាក់កាលទី ២០. ការកំណត់កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់** .................................... ២៦

**ដំណាក់កាលទី ២១. ដីកាសម្រេចអនុញ្ញាតឲ្យលក់ ឬ ដីកាសម្រេចមិនអនុញ្ញាតឲ្យលក់** ..................... ២៧

**សំណួរទី ៣២៖** តើកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ ត្រូវធ្វើឡើងដោយនីតិវិធីបែបណា? ....................................................................................................... ២៧

**សំណួរទី ៣៣៖** តើការលក់ហួសកម្រិតជាអ្វី? ....................................................................... ២៨

**ដំណាក់កាលទី ២២. ការកំណត់ពេលនៃការបង់ថ្លៃលក់** .............................................................. ២៩

**ដំណាក់កាលទី ២៣. ការបង់ថ្លៃលក់** ......................................................................................... ២៩

**សំណួរទី ៣៤៖** តើការបង់តែចំនួនខ្វះជាអ្វី? ........................................................................ ២៩

**សំណួរទី ៣៥៖** នៅក្នុងករណីដែលអ្នកទិញមិនបានបង់ប្រាក់ថ្លៃលក់ឲ្យបានទាន់ពេលកំណត់នៃការបង់ថ្លៃលក់ តើតុលាការអនុវត្តត្រូវធ្វើយ៉ាងណា? ...................................................... ៣០

**ដំណាក់កាលទី ២៤. ការផ្ទុកផ្ដាក់ឲ្យចុះបញ្ជី** ............................................................................. ៣០

**សំណួរទី ៣៦៖** តើត្រូវធ្វើលិខិតផ្ទុកផ្ដាក់ឲ្យចុះបញ្ជីដោយរបៀបណា? ............................................ ៣០

**សំណួរទី ៣៧៖** តើនរណាជាអ្នកបង់សោហ៊ុយចាំបាច់ដើម្បីផ្ទុកផ្ដាក់ឲ្យចុះបញ្ជី ហើយបង់ដោយរបៀបណា? ....................................................................................................... ៣៣

**សំណួរទី ៣៨៖** តើការចុះបញ្ជីណាដែលត្រូវលុបចោលដោយការផ្ទុកផ្ដាក់? ..................................... ៣៣

**ដំណាក់កាលទី ២៥. ការចុះបញ្ជីផ្អែកតាមការផ្ទុកផ្ដាក់** ................................................................ ៣៨

**សំណួរទី ៣៩៖** តើមន្ត្រីចុះបញ្ជីដែលបានទទួលលិខិតផ្ទុកផ្ដាក់ឲ្យចុះបញ្ជី ត្រូវសរសេរអ្វីខ្លះទៅក្នុងសៀវភៅចុះបញ្ជី? ....................................................................................................... ៣៨

**ផ្នែកទី ៣ ការចែកចំណែក** ........................................................ ៤០

**ជំណាក់កាលទី ២៦. ការកំណត់កាលបរិច្ឆេទនៃការចែកចំណែក** ........................................................ ៤០

**ជំណាក់កាលទី ២៧. ការជូនដំណឹងអំពីកាលបរិច្ឆេទនៃការចែកចំណែក និង ការដាស់តឿនឲ្យដាក់លិខិតគណនា ជាដើម** ........................................................ ៤០

**សំណួរទី ៤០៖** ក្នុងករណី ដែលម្ចាស់បំណុលមិនបានផ្តល់លិខិតគណនា តើតុលាការអនុវត្តចាំបាច់ត្រូវអនុវត្តការចែកចំណែកទៅឲ្យម្ចាស់បំណុលនោះដែរឬទេ? ........................................................ ៤១

**ជំណាក់កាលទី ២៨. ការបង្កើតសេចក្តីព្រាងដើមនៃតារាងចែកចំណែក** ........................................................ ៤១

**សំណួរទី ៤១៖** តើសេចក្តីព្រាងដើមនៃតារាងចែកចំណែកត្រូវបង្កើតឡើងដោយរបៀបណា? ........ ៤១

**ជំណាក់កាលទី ២៩. ការបើកកាលបរិច្ឆេទនៃការចែកចំណែក និង ការអនុវត្តការចែកចំណែក** ................ ៥០

**សំណួរទី ៤២៖** តើតុលាការអនុវត្ត ត្រូវធ្វើអ្វីខ្លះ នៅកាលបរិច្ឆេទនៃការចែកចំណែក? ................ ៥០

# នីតិវិធីនៃការអនុវត្តហ៊ីប៉ូតែក

នៅក្នុងប្រទេសកម្ពុជា ការដាក់ធានា (gage) គឺកំពុងត្រូវបានគេយកមកប្រើប្រាស់។ ប៉ុន្តែស្របជាមួយនឹងការកើនឡើងនៃការចុះបញ្ជីអចលនវត្ថុ និង ចំនួនសារការីនៅថ្ងៃអនាគត គេគិតថាចំនួនហ៊ីប៉ូតែកនឹងមានការកើនឡើង។ ការអនុវត្តហ៊ីប៉ូតែកដែលត្រូវអនុលោមតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី ខុសពីការអនុវត្តការដាក់ធានាដែលត្រូវបានបង្កើតឡើងដោយម្ចាស់បំណុលគ្រាន់តែកាន់កាប់ប័ណ្ណ។ ដូច្នេះ **ចៅក្រម ក្រឡាបញ្ជី មន្ត្រីចុះបញ្ជីអាជ្ញាសាលា មេធាវី សារការី ត្រូវតែយល់ឲ្យបានត្រឹមត្រូវអំពីនីតិវិធីទាក់ទងនឹងហ៊ីប៉ូតែក។**

យ៉ាងណាមិញ ឯកសារនេះនឹងពន្យល់អំពី នីតិវិធីនៃការអនុវត្តហ៊ីប៉ូតែកលើកម្មសិទ្ធិនៃដីដែលបានចុះបញ្ជីជាប្រព័ន្ធរួចរាល់។ ចំណែកឯ នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះដីដែលមិនបានចុះបញ្ជីជាប្រព័ន្ធ គឺខុសគ្នាពីឯកសារនេះ។

****************************************

ជាធម្មតា នីតិវិធីនៃការអនុវត្តហ៊ីប៉ូតែក គឺស្ទើរតែដូចគ្នាទៅនឹងនីតិវិធីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ(ក្រមនីតិ/ណី មាត្រា ៥២០) ដែលត្រូវបានបែងចែក ៣ ដំណាក់កាលគឺ រឹបអូស⟶លក់⟶ចែកចំណែក។ នៅក្នុងឯកសារនេះ មានសរសេរអំពីលំហូរនៃនីតិវិធីការអនុវត្តហ៊ីប៉ូតែកដែលមានលក្ខណៈជាមូលដ្ឋាន ប៉ុន្តែលំហូរនៃនីតិវិធីនេះអាចនឹងមានការប្រែប្រួលទៅតាមស្ថានភាពនៃរឿងក្តីជាក់ស្តែងដូចជា ការលុបចោលនិងការផ្អាកការអនុវត្តសិទ្ធិប្រាតិភោគ និង បណ្តឹងតវ៉ាជាអាទិ៍ (ក្រមនីតិ/ណី មាត្រា ៣៤៤, មាត្រា ៣៦៣, មាត្រា ៣៦៤, មាត្រា ៣៦៥ ជាអាទិ៍) នៅក្នុងដំណាក់កាលនីមួយៗ (Slide 1)។

## ផ្នែកទី ១ ការរឹបអូស

**ដំណាក់កាលទី ១. ការរៀបចំការដាក់ពាក្យ៖** ម្ចាស់បំណុលនៃការអនុវត្តត្រូវរៀបចំដូចខាងក្រោម៖

1) ឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត (ក្រមនីតិ/ណី មាត្រា ៤៩៦, មាត្រា ៥០៩ កថា.២)។
2) រូបមន្តអនុវត្ត (ក្រមនីតិ/ណី មាត្រា ៣៥៤)
3) លិខិតបញ្ជាក់អំពីការបញ្ជូន (ក្រមនីតិ/ណី មាត្រា ៣៦០)
4) ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ (ក្រមនីតិ/ណី មាត្រា ៥០៩កថា.២)

**<u>សំណួរទី ១៖ តើត្រូវធ្វើដូចម្តេច ទើបអាចទទួលបានឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត? (Slide 2 ~ 4)</u>**

ដើម្បីអនុវត្តហ៊ីប៉ូតែកត្រូវមានលិខិតអនុវត្ត ២ ប្រភេទ ដូចខាងក្រោម (ក្រមនីតិ/ណី មាត្រា ៤៩៦)។ ដោយសារតែតុលាការ និង សារការីជាអ្នករក្សាទុកនូវ**<u>ច្បាប់ដើម</u>**នៃលិខិតអនុវត្ត ដូច្នេះ ម្ចាស់បំណុលនៃការអនុវត្តត្រូវរៀបចំ**<u>ឯកសារចម្លងយថាភូត</u>**ណាមួយនៃ A ឬក៏ B ដូចតទៅ៖

A. **សាលក្រម ឬ សាលដីកាស្ថាពរដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ឬ លិខិតដែលមានអានុភាពដូចសាលក្រម ឬ សាលដីកាស្ថាពរនោះ៖** អាចជាសាលក្រមដែលបង្គាប់ឲ្យផ្តល់តាវកាលិក (សាលក្រមបង្គាប់ឲ្យធ្វើនីតិវិធីចុះបញ្ជី) ក៏បាន ឬ សាលក្រមដែលទាមទារឲ្យបញ្ជាក់ក៏បាន ឲ្យតែសាលក្រមទាំងពីរនេះសរសេរពីខ្លឹមសារដែលបញ្ជាក់អំពីអត្ថិភាពនៃហ៊ីប៉ូតែក។ ឧទាហរណ៍៖ សាលក្រមស្ថាពរដែលទទួលស្គាល់នូវការទាមទារនៃបណ្តឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃហ៊ីប៉ូតែក [1] សាលក្រមស្ថាពរដែលច្រានចោលការទាមទារនៃបណ្តឹងទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃហ៊ីប៉ូតែក សាលក្រមស្ថាពរដែលបង្គាប់ឲ្យធ្វើនីតិវិធីចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក[2] កំណត់ហេតុសះជា ឬ កំណត់ហេតុទទួលស្គាល់ការទាមទារដែលមានអត្ថន័យដូចគ្នានឹងសាលក្រមខាងលើនេះ ជាអាទិ៍។

B. **លិខិតយថាភូតដែលធ្វើឡើងដោយសារការីហើយដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ៖** មានដូចជាលិខិតយថាភូតនៃកិច្ចសន្យាបង្កើតហ៊ីប៉ូតែក។

---

[1] បណ្តឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃហ៊ីប៉ូតែកគឺ ឧទាហរណ៍ដូចជាករណីបែបនេះ។ X បានបង្កើតកិច្ចសន្យាបង្កើតហ៊ីប៉ូតែកលើដី A ដែលជាកម្មសិទ្ធិរបស់ Y និងបានចុះបញ្ជី។ បន្ទាប់មក នៅពេលកំណត់សង Y មិនបានសង ហេតុនេះ X គិតចង់អនុវត្តហ៊ីប៉ូតែក ប៉ុន្តែ X គ្មានលិខិតអនុវត្តទេ។ ហេតុនេះ X បានដាក់ពាក្យបណ្តឹងទាមទារថា "បញ្ជាក់ថា ដើមចោទ X មានហ៊ីប៉ូតែកដែល ... លើដី A" ចំពោះ Y ។ បើ X ឈ្នះក្តី X នឹងទទួលបានសាលក្រមស្ថាពរដែលទទួលស្គាល់នូវការទាមទារនៃបណ្តឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃហ៊ីប៉ូតែក ដែលវានឹងក្លាយជាលិខិតអនុវត្ត។ ទោះបីជា X បានចុះបញ្ជីបង្កើតហ៊ីប៉ូតែកក៏ដោយ ប៉ុន្តែឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ មិនមែនជាលិខិតអនុវត្តទេ ហេតុនេះ X ចាំបាច់ត្រូវដាក់ពាក្យបណ្តឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃហ៊ីប៉ូតែក ដើម្បីអាចទទួលបាននូវលិខិតអនុវត្ត។

[2] សាលក្រមដែលបង្គាប់ឲ្យធ្វើនីតិវិធីចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែកគឺ ឧទាហរណ៍ដូចជាករណីបែបនេះ។ X បានបង្កើតកិច្ចសន្យាបង្កើតហ៊ីប៉ូតែកលើដី A ដែលជាកម្មសិទ្ធិរបស់ Y ប៉ុន្តែ Y មិនព្រមសហការក្នុងការធ្វើនីតិវិធីចុះបញ្ជី។ ហេតុនេះ X បានដាក់ពាក្យបណ្តឹងទាមទារថា "បង្គាប់ឲ្យចុងចម្លើយ Y ធ្វើនីតិវិធីចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែកដែល ... លើដី Aទៅឲ្យដើមចោទ X" ចំពោះ Y ។ បើ X ឈ្នះក្តី X នឹងទទួលបានសាលក្រមស្ថាពរដែលបង្គាប់ឲ្យធ្វើនីតិវិធីចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក ដែលវានឹងក្លាយជាលិខិតអនុវត្ត។

នៅពេលបង្កើតហ៊ីប៉ូតែក ប្រសិនបើម្ចាស់បំណុលហ៊ីប៉ូតែកមិនបានពឹងពាក់សារការីឲ្យធ្វើលិខិតយថាភូតទេ នោះម្ចាស់បំណុលហ៊ីប៉ូតែកត្រូវរៀបចំ "សាលក្រម ឬ សាលដីកាស្ថាពរដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ឬ លិខិតដែលមានអានុភាពដូចសាលក្រម ឬ សាលដីកាស្ថាពរនោះ"។ ឧទាហរណ៍៖ ក្នុងករណីដែលម្ចាស់បំណុលហ៊ីប៉ូតែកបានដាក់ពាក្យបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីអត្ថិភាពនៃហ៊ីប៉ូតែក ចំពោះអ្នកបង្កើតហ៊ីប៉ូតែក ហើយបានឈ្នះក្តី នោះម្ចាស់បំណុលហ៊ីប៉ូតែកនឹងទទួលបានអានុសារសាលក្រមពីតុលាការ (ក្រមនីតិ/ណី មាត្រា ១៩០)។ម្យ៉ាងវិញទៀត ក្នុងករណីដែលបានធ្វើការផ្សះផ្សាអំពីខ្លឹមសារដែលទទួលស្គាល់អត្ថិភាពនៃហ៊ីប៉ូតែកក្នុងអំឡុងពេលធ្វើបណ្ដឹង ម្ចាស់បំណុលហ៊ីប៉ូតែកអាចទាមទារឲ្យតុលាការប្រគល់ឯកសារចម្លងយថាភូតនៃកំណត់ហេតុសះជាបាន (ក្រមនីតិ/ណី មាត្រា ២៥៨ កថា.១)។ ក្នុងករណីនេះ ក្រឡាបញ្ជីត្រូវថតចម្លងលិខិតសាលក្រម និង កំណត់ហេតុសះជា ហើយបញ្ជាក់ថា ជាឯកសារចម្លងយថាភូត និង ចុះហត្ថលេខា រួចបញ្ជូនទៅម្ចាស់បំណុលហ៊ីប៉ូតែក (ក្រមនីតិ/ណី មាត្រា ២៥៨ កថា.១)។

នៅពេលបង្កើតហ៊ីប៉ូតែក ប្រសិនបើម្ចាស់បំណុលហ៊ីប៉ូតែកបានពឹងពាក់សារការីឲ្យធ្វើលិខិតយថាភូត ហើយដោយសារតែលិខិតនោះគឺជា "លិខិតយថាភូតដែលធ្វើឡើងដោយសារការីហើយដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ" នោះម្ចាស់បំណុលហ៊ីប៉ូតែកត្រូវស្នើសុំសារការីឲ្យចេញឯកសារចម្លងយថាភូតនៃលិខិតនោះ។ ដោយសារតែក្រមនីតិវិធីរដ្ឋប្បវេណី មិនមានកំណត់អំពីនីតិវិធីនៃការចេញឯកសារចម្លងយថាភូតដែលធ្វើឡើងដោយសារការី ហេតុនេះ គេត្រូវពឹងផ្អែកលើបទដ្ឋានគតិយុត្តផ្សេងទៀត និង ការអនុវត្តជាក់ស្តែងដែលមានលក្ខណៈសមស្រប ។ ប៉ុន្តែ ការចេញឯកសារចម្លងយថាភូតនេះ មាននីតិវិធីដូចគ្នានឹងការចេញឯកសារចម្លងយថាភូតដែលធ្វើឡើងដោយក្រឡាបញ្ជីដែរ ហើយសារការីត្រូវប្រគល់ឯកសារចម្លងយថាភូតនេះទៅឲ្យម្ចាស់បំណុលហ៊ីប៉ូតែក។ ទោះបីជា លិខិតយថាភូតនេះមិនបានធ្វើឡើងដោយសារការីក៏ដោយ ក៏អាចចុះបញ្ជីបង្កើតហ៊ីប៉ូតែកបានដែរ។ ប៉ុន្តែ <u>ប្រសិនបើ លិខិតយថាភូតនោះធ្វើឡើងដោយសារការី វានឹងមានភាពងាយស្រួលដោយមិនចាំបាច់ប្ដឹងទៅតុលាការនៅពេលរៀបចំឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត</u>។

យ៉ាងណាមិញ ទោះបីជាលិខិតយថាភូតមិនបានធ្វើឡើងដោយសារការីក៏ដោយ ក៏នៅពេលដែលម្ចាស់បំណុលហ៊ីប៉ូតែកចុះបញ្ជីហ៊ីប៉ូតែក មេឃុំ ឬ ចៅសង្កាត់ច្បាស់ជាបានធ្វើ "លិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជី" (ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា៩ កថា.២) ជាមិនខាន។ ប៉ុន្តែ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៤៩៦ មិនមានចែងអំពីលិខិតនេះទេ។ ហេតុនេះ បើយោងតាមក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៤៩៦ គឺមិនអាចធ្វើការអនុវត្តហ៊ីប៉ូតែកដោយផ្អែកតាមលិខិតនោះបានទេ។ ប៉ុន្តែ ប្រសិនបើ យកលិខិតនេះធ្វើជា

លិខិតអនុវត្តបាន នោះការអនុវត្តហ៊ីប៉ូតែកនឹងក្លាយជាងាយស្រួល។ ទន្ទឹមនឹងនេះ ប្រសិនបើ មានគោលបំណងចង់ឲ្យការអនុវត្តហ៊ីប៉ូតែកនៅកម្ពុជាកាន់តែមានភាពងាយស្រួល គេអាចពិចារណា រួមបញ្ចូល "លិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជី" ជាលិខិតអនុវត្តដោយវិធី ធ្វើការបកស្រាយក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៤៩៦ និង ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា ៩ ចំណុច ខ ឬ ដោយធ្វើវិសោធនកម្មក្រមនីតិវិធីរដ្ឋប្បវេណី ឬ បង្កើតប្រកាសថ្មី នាពេលអនាគត ជាដើម។ ចំណុចនេះ គឺអាស្រ័យទៅលើស្ថានភាពជាក់ស្តែងរបស់ប្រទេសកម្ពុជា នាពេលអនាគត។

**<u>សំណួរទី ២៖ តើធ្វើដូចម្តេចទើបអាចទទួលបានរូបមន្តអនុវត្ត?</u>**

ម្ចាស់បំណុលនៃការអនុវត្តត្រូវដាក់នូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត រួមជាមួយនឹងពាក្យសុំឲ្យផ្តល់រូបមន្តអនុវត្ត ទៅឲ្យតុលាការដែលមានសំណុំរឿង ឬ សារការីដែលជាអ្នករក្សាទុកនូវច្បាប់ដើមនៃលិខិតយថាភូត (ក្រមនីតិ/ណី៣៥៤ កថា.២, មាត្រា ៣៥៥)។ ក្រឡាបញ្ជី ឬ សារការីធ្វើការផ្ទៀងផ្ទាត់លើច្បាប់ដើមនៃលិខិតអនុវត្ត និង សំណុំរឿងជាអាទិ៍ ហើយធ្វើការត្រួតពិនិត្យថាតើបានសរសេរអំពីអត្ថិភាពនៃប្រាតិភោគ ឬ អត់ និងធ្វើការពិនិត្យសាលក្រមថាបានចូលជាស្ថាពរហើយ ឬនៅ ប្រសិនបើយល់ឃើញថាត្រឹមត្រូវ ក្រឡាបញ្ជី ឬ សារការី នឹងផ្តល់រូបមន្តអនុវត្តលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត។

ផ្អែកតាមបញ្ញត្តិដែលកំណត់នៅក្នុងក្រមរដ្ឋប្បវេណី មាត្រា ៣៥៧ កថា.១ រូបមន្តអនុវត្តត្រូវសរសេរភ្ជាប់បន្ថែមនៅផ្នែកខាងក្រោមនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ហើយក្រឡាបញ្ជី ឬ សារការីត្រូវចុះហត្ថលេខាលើរូបមន្តអនុវត្តដោយសរសេរ ថ្ងៃ ខែ ឆ្នាំ នៃការផ្តល់រូបមន្តអនុវត្ត។ ជាធម្មតា ប្រសិនបើខ្លឹមសារនៃរូបមន្តអនុវត្តសរសេរថា "ម្ចាស់បំណុលនៃការអនុវត្ត X អាចអនុវត្តហ៊ីប៉ូតែក ចំពោះកូនបំណុលនៃការអនុវត្ត Y បាន ដោយផ្អែកតាមលិខិតអនុវត្តនេះ។ *ហត្ថលេខារបស់ក្រឡាបញ្ជី ឬ សារការី* ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៥" នោះវាមានលក្ខណៈគ្រប់គ្រាន់ហើយ។ ប៉ុន្តែ វាមានភាពចាំបាច់ក្នុងការសរសេរបន្ថែមនូវចំណុច ដូចដែលមានចែងក្នុងចំណុច ខ គ ឃ នៃមាត្រា ៣៥៧ កថា.១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រសិនបើមានស្ថានភាពបែបនោះ។

*នៅពេលផ្តល់រូបមន្តអនុវត្ត ក្រឡាបញ្ជី ឬ សារការី ត្រូវសរសេរនូវចំណុចដែលបានកំណត់នៅក្នុង មាត្រា ៣៥៩ កថា.១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៅលើ**<u>ច្បាប់ដើម</u>**នៃលិខិតអនុវត្ត (ក្រមនីតិ/ណី មាត្រា ៣៥៩ កថា.១)។ ម្យ៉ាងទៀត ក្នុងករណីដែលបានផ្តល់រូបមន្តអនុវត្តច្រើនច្បាប់ និង ច្រើនដង ក្រឡាបញ្ជី ឬ សារការី ត្រូវជូនដំណឹងទៅកូនបំណុលនៃការអនុវត្តអំពីហេតុការណ៍ និង មូលហេតុនោះ និង ចំនួននៃឯកសារចម្លងយថាភូតដែលត្រូវបានផ្តល់រូបមន្តអនុវត្ត (ក្រមនីតិ/ណី មាត្រា ៣៥៨ កថា.២)។

**<u>សំណួរទី ៣៖ តើត្រូវធ្វើដូចម្តេចទើបអាចទទួលបាននូវលិខិតបញ្ជាក់អំពីការបញ្ជូន?</u>**

មុនពេលដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែក ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬ ឯកសារចម្លងយថាភូតនៃលិខិតអនុវត្តត្រូវបញ្ជូនទៅកូនបំណុលនៃការអនុវត្ត។ ម្យ៉ាងទៀត ក្នុងករណីដែលបានផ្តល់រូបមន្តអនុវត្តពិសេស នោះរូបមន្តអនុវត្ត និង ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃឯកសារដែលម្ចាស់បំណុលនៃការអនុវត្តបានដាក់ដើម្បីទទួលបានរូបមន្តអនុវត្តពិសេស ក៏ត្រូវបញ្ជូនទៅឲ្យកូនបំណុលផងដែរ (ក្រមនីតិវិធី/ណី មាត្រា ៣៦០)។ បន្ទាប់មកម្ចាស់បំណុលហ៊ីប៉ូតែកទទួលបាននូវលិខិតបញ្ជាក់ពីការបញ្ជូន ហើយត្រូវភ្ជាប់លិខិតនោះជាមួយនឹងពាក្យសុំឲ្យអនុវត្តហ៊ីប៉ូតែក។

ក្នុងករណីដែលក្រឡាបញ្ជីបានធ្វើការបញ្ជូន នោះក្រឡាបញ្ជីដែលបានអនុវត្តការបញ្ជូនជាអ្នកចេញលិខិតបញ្ជាក់អំពីការបញ្ជូននោះ (ក្រមនីតិ/ណី មាត្រា ២៥៨ កថា.១)។ ក្នុងករណីដែលយកលិខិតយថាភូតដែលបញ្ជាក់អំពីសិទ្ធិប្រាតិភោគមកធ្វើជាលិខិតអនុវត្ត ការបញ្ជូនលិខិតយថាភូតនោះគឺមិនមានកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីទេ។ ហេតុនេះ សារការី អាច ឬ មិនអាចធ្វើការបញ្ជូនបាននោះ គឺអាស្រ័យលើបទដ្ឋានគតិយុត្តផ្សេងៗ និង ការអនុវត្តជាក់ស្តែងដែលមានលក្ខណៈសមស្រប។ ប៉ុន្តែ ក្នុងករណីដែលសារការីបានធ្វើការបញ្ជូន នោះសារការីត្រូវចេញលិខិតបញ្ជាក់អំពីបញ្ជូន ដែលមាននីតិវិធីដូចគ្នាទៅនឹងនីតិវិធីនៃការបញ្ជូនដោយក្រឡាបញ្ជីដែរ។

**<u>សំណួរទី ៤៖ តើធ្វើដូចម្តេចទើបអាចទទួលបាននូវឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ? (Slide 5)</u>**

ម្ចាស់បំណុលនៃការអនុវត្ត ត្រូវដាក់ពាក្យសុំឲ្យបញ្ជាក់សៀវភៅចុះបញ្ជីអចលនវត្ថុហ៊ីប៉ូតែក ទៅរដ្ឋបាលសុរិយោដី ហើយមន្ត្រីចុះបញ្ជីត្រូវចេញលិខិតបញ្ជាក់មិនឲ្យលើសរយៈពេល ៣ ថ្ងៃ (ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ប្រការ ១៣៨, ប្រការ ១៣៩)។ **<u>មន្ត្រីចុះបញ្ជីមិនត្រូវបដិសេធការចេញលិខិតបញ្ជាក់ទេ ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តបានដាក់ពាក្យសុំត្រឹមត្រូវហើយ និងបានបង់សោហ៊ុយរួចរាល់។</u>** ពោលគឺ ទោះបីជាមានករណីដែល បុគ្គលមិនមែនជាកម្មសិទ្ធិករបានដាក់ពាក្យសុំឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅគោលបញ្ជីអចលនវត្ថុក៏ដោយ មន្ត្រីចុះបញ្ជី ត្រូវចេញឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅគោលបញ្ជីអចលនវត្ថុ។

**ដំណាក់កាលទី ២ ការធ្វើពាក្យសុំ៖** ម្ចាស់បំណុលនៃការអនុវត្តត្រូវធ្វើពាក្យសុំឲ្យអនុវត្តហ៊ីប៉ូតែក (ក្រមនីតិ/ណី មាត្រា ៥០៩)។ យ៉ាងណាមិញ ពាក្យសុំឲ្យអនុវត្តហ៊ីប៉ូតែកត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ( ក្រមនីតិ/ណី មាត្រា ៥២០, មាត្រា ៣៤៩ កថា.១)។

<u>**សំណួរទី ៥៖ តើត្រូវសរសេរអ្វីខ្លះនៅក្នុងពាក្យសុំឲ្យអនុវត្តហ៊ីប៉ូតែក?**</u>

នៅក្នុងពាក្យសុំឲ្យអនុវត្តហ៊ីប៉ូតែក ត្រូវសរសេរនូវចំណុចដូចខាងក្រោម (ក្រមនីតិ/ណី មាត្រា ៥០៩)៖

- **សញ្ញាណនៃម្ចាស់បំណុលនៃការអនុវត្ត កម្មសិទ្ធិករនៃអចលនវត្ថុដែលជាកូនបំណុលនៃការអនុវត្ត កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា និង អ្នកតំណាង**
- **សញ្ញាណនៃសិទ្ធិប្រាតិភោគ និង សិទ្ធិលើបំណុលដែលត្រូវបានធានា៖** ត្រូវសរសេរឲ្យបានច្បាស់អំពីថ្ងៃបង្កើត ថ្ងៃចុះបញ្ជី លេខចុះបញ្ជីសិទ្ធិប្រាតិភោគ ជាអាទិ៍ ហើយត្រូវសរសេរឲ្យបានច្បាស់អំពីប្រភេទនៃកិច្ចសន្យា ថ្ងៃបង្កើតកិច្ចសន្យា ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានា ជាអាទិ៍។ យ៉ាងណាមិញ ក្នុងករណីដែលទាមទារការប្រាក់ និង ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ នោះត្រូវសរសេរអំពីចំនួនទឹកប្រាក់ និង ការប្រាក់នោះ ព្រមទាំង ថ្ងៃចាប់ផ្តើមផងដែរ។
- **សញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តសិទ្ធិប្រាតិភោគ៖** គឺធ្វើការបញ្ជាក់ដោយផ្អែកតាមទីតាំងដែលអចលនវត្ថុនោះតាំងនៅ លេខក្បាលដី ជាអាទិ៍ ហើយ <u>**ត្រូវធ្វើការផ្ទៀងផ្ទាត់ជាមួយនឹងឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ និងត្រូវសរសេរឲ្យដូចគ្នាជាមួយនឹងឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីនោះ។**</u>
- **ហេតុការណ៍ និង ទំហំនៃផ្នែកនៃសិទ្ធិលើបំណុលដែលត្រូវបានធានា បើធ្វើការអនុវត្តសិទ្ធិប្រាតិភោគចំពោះផ្នែកមួយនៃសិទ្ធិលើបំណុលដែលត្រូវបានធានា៖** ទោះបីជា ក្នុងករណីដែលបានអនុវត្តហ៊ីប៉ូតែកតែចំពោះផ្នែកមួយនៃសិទ្ធិលើបំណុលដែលត្រូវបានធានាក៏ដោយ ក៏សិទ្ធិប្រាតិភោគត្រូវរលត់ដែរ (ក្រមនីតិ/ណី មាត្រា ៥១០ កថា.២) ហើយម្ចាស់បំណុលនៃការអនុវត្ត ត្រូវប្រុងប្រយ័ត្ន ដោយសារតែផ្នែកដែលនៅសល់នៃសិទ្ធិលើបំណុលដែលត្រូវបានធានានោះ ក្លាយទៅជាសិទ្ធិលើបំណុលដែលមិនត្រូវបានធានាដោយប្រាតិភោគ។
- ឧទាហរណ៍ ក្នុងករណីដែលធ្វើការអនុវត្តហ៊ីប៉ូតែកតែចំពោះផ្នែកមួយនៃសិទ្ធិលើបំណុលដែលត្រូវបានធានា៖ ឧបមាថា តម្លៃនៃអចលនវត្ថុហ៊ីប៉ូតែកទាបជាងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានា នោះក៏

អាចមានករណី ដែលអាចដាក់ពាក្យសុំបន្ថយនូវចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានាត្រឹមទំហំនៃតម្លៃរបស់អចលនវត្ថុហ៊ីប៉ូតែក។

<u>**សំណួរទី ៦៖ តើពាក្យសុំឲ្យអនុវត្តហ៊ីប៉ូតែកត្រូវភ្ជាប់ជាមួយនឹងឯកសារអ្វីខ្លះ?**</u>

- **ឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយរូបមន្តអនុវត្ត** (ក្រមនីតិ/ណី មាត្រា ៥០៩ កថា.២)
- **លិខិតបញ្ជាក់អំពីការបញ្ជូន** (ក្រមនីតិ/ណី មាត្រា ៣៦០)
- **ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុហ៊ីប៉ូតែក** (ក្រមនីតិ/ណី មាត្រា ៥០៩ កថា.២)
- **លិខិតដែលបញ្ជាក់អំពីសិទ្ធិតំណាង៖** ត្រូវតែភ្ជាប់នូវលិខិតនេះ ក្នុងករណីអ្នកតំណាងដាក់ពាក្យសុំ (ក្រមនីតិ/ណី មាត្រា ៥៣ កថា.២)។

* មិនមានភាពចាំបាច់ ក្នុងការភ្ជាប់នូវប័ណ្ណកម្មសិទ្ធិនៃអចលនវត្ថុទេ។

* មិនមានភាពចាំបាច់ ក្នុងការភ្ជាប់នូវឯកសារចម្លងយថាភូតនៃសាលក្រមដែលបង្គាប់ឲ្យផ្តល់តាវកាលិកនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ជាអាទិ៍ទេ។ ជាធម្មតា ក្នុងករណីដែលធ្វើការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវដាក់ឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលបង្ហាញអំពីអត្ថិភាពនៃសិទ្ធិលើបំណុលដែលទាមទារ ជាសាលក្រមដែលបង្គាប់ឲ្យផ្តល់តាវកាលិកនៃសិទ្ធិលើបំណុលដែលទាមទារ ជាអាទិ៍។ ប៉ុន្តែ ករណីអនុវត្តហ៊ីប៉ូតែក វាមិនមានភាពចាំបាច់ក្នុងការដាក់លិខិតជាលាយល័ក្ខណ៍អក្សរដែលបញ្ជាក់ពីអត្ថិភាពនៃសិទ្ធិលើបំណុលដែលត្រូវបានធានាទេ ។

**ដំណាក់កាលទី ៣. ការដាក់ពាក្យសុំ៖** ម្ចាស់បំណុលនៃការអនុវត្ត ត្រូវដាក់ពាក្យសុំឲ្យអនុវត្តហ៊ីប៉ូតែក និងឯកសារភ្ជាប់ទៅតុលាការអនុវត្ត ហើយបង់ពន្ធដាក់ពាក្យសុំ (១០.០០០រៀល ក្រមនីតិ/ណី មាត្រា ៥២០, មាត្រា ៣៧២ កថា.១ ) និងធ្វើការបង់សោហ៊ុយជាមុន ( ក្រមនីតិ/ណី មាត្រា ៥២០, មាត្រា ៣៧៥) ។ (Slide 6)

<u>**សំណួរទី ៧៖ តើសោហ៊ុយសម្រាប់ការអនុវត្តជាបន្ទុករបស់អ្នកណា? (Slide 7 ~ 10)**</u>

<u>**សោហ៊ុយសម្រាប់ការអនុវត្តជាបន្ទុករបស់កូនបំណុលនៃការអនុវត្ត**</u> (ក្រមនីតិ/ណី មាត្រា ៣៧៦ កថា.១)។ ប៉ុន្តែ នីតិវិធីអនុវត្តដោយបង្ខំមិនអាចបន្តទៅមុខទៀតបានទេ ប្រសិនបើ សោហ៊ុយសម្រាប់ការអនុវត្តមិនត្រូវបានបង់ ដូច្នេះ

ជាដំបូង ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់សោហ៊ុយសម្រាប់ការអនុវត្តជាមុនសិន បន្ទាប់មក ម្ចាស់បំណុលនៃការអនុវត្តនឹងទទួលបានសោហ៊ុយសម្រាប់ការអនុវត្តមកវិញពីកូនបំណុលនៃការអនុវត្ត។

សោហ៊ុយសម្រាប់ការអនុវត្ត គឺជាសោហ៊ុយដែលចំណាយ នៅពេលដែលក្រឡាបញ្ជីធ្វើការបញ្ជូនតាមរយៈប្រៃសណីយ៍ ជាអាទិ៍ ហើយបូករួមជាមួយនឹងសោហ៊ុយដែលចំណាយ នៅពេលក្រឡាបញ្ជីធ្វើការផ្ទុកផ្ដាក់ឲ្យចុះបញ្ជីទៅរដ្ឋបាលសុរិយោដី។ ដោយសារតែសោហ៊ុយទាំងនេះ គឺជាការចំណាយដែលបានមកពីការបង់សោហ៊ុយជាមុនរបស់ម្ចាស់បំណុលនៃការអនុវត្ត ដូច្នេះ **<u>តុលាការអនុវត្តដាច់ខាតត្រូវតែឲ្យម្ចាស់បំណុលនៃការអនុវត្តបង់សោហ៊ុយជាមុន</u>**។ ប្រសិនបើប្រាក់នៃការបង់សោហ៊ុយជាមុនមិនគ្រប់គ្រាន់ តុលាការអនុវត្តអាចបង្គាប់ឲ្យម្ចាស់បំណុលនៃការអនុវត្តបង់ប្រាក់ដែលជាសោហ៊ុយជាមុននោះបន្ថែមទៀតបាន (ក្រមនីតិវិធី/ណី មាត្រា ៣៧៥ កថា.ទី ១ វាក្យខណ្ឌទី ២)។

**<u>នៅពេលបន្តនីតិវិធីលក់ដោយបង្ខំរហូតដល់នីតិវិធីចែកចំណែក ម្ចាស់បំណុលនៃការអនុវត្តនឹងទទួលបានសោហ៊ុយសម្រាប់ការអនុវត្តពីការចែកចំណែកមកវិញ</u>** (ក្រមនីតិ/ណី មាត្រា ៣៧៦ កថា.ទី២, មាត្រា ៤៩០ កថា.៤)។

**<u>សំណួរទី ៨៖ តើពាក្យសុំឲ្យអនុវត្តហ៊ីប៉ូតែកត្រូវដាក់នៅតុលាការណា?</u>**

គឺដាក់ទៅសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលអចលនវត្ថុនោះតាំងនៅ។ ឧទាហរណ៍ ប្រសិនបើ ដីនោះស្ថិតនៅខេត្តកំពត ពាក្យសុំឲ្យអនុវត្តហ៊ីប៉ូតែក ត្រូវដាក់ទៅសាលាដំបូងខេត្តកំពត (ក្រមនីតិ/ណី មាត្រា ៤១៨)។ ដោយសារតែសមត្ថកិច្ចនោះជាសមត្ថកិច្ចផ្ដាច់មុខ(ក្រមនីតិ/ណី មាត្រា ៣៤៦) គូភាគីមិនអាចដាក់ពាក្យសុំទៅតុលាការផ្សេង បានទេ ទោះបីជាមានការព្រមព្រៀងគ្នាក៏ដោយ។

**ដំណាក់កាលទី៤. ការពិនិត្យពាក្យសុំ៖** ក្នុងករណីដែលមានពាក្យសុំឲ្យអនុវត្តហ៊ីប៉ូតែក តុលាការអនុវត្តត្រូវធ្វើការពិនិត្យអំពីខ្លឹមនៃពាក្យសុំ ឯកសារភ្ជាប់ ពន្ធដាក់ពាក្យសុំ និង ការបង់សោហ៊ុយជាមុន។ ប្រសិនបើ ពាក្យសុំមានភាពត្រឹមត្រូវហើយ នោះតុលាការអនុវត្តនឹងចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ។ ប្រសិនបើ ពាក្យសុំមិនបានរៀបចំឲ្យបានត្រឹមត្រូវទេ នោះតុលាការអនុវត្តនឹងចេញដីកាសម្រេចលើកចោលពាក្យសុំ។ ប៉ុន្តែ ប្រសិនបើភាពខ្វះខាតនោះអាចកែតម្រូវបាន នោះវាមានភាពសមរម្យដែលតុលាការអនុវត្តអាចជំរុញឲ្យម្ចាស់បំណុលនៃការអនុវត្តធ្វើការកែតម្រូវចំពោះចំណុចខ្វះខាតនោះ។

**<u>សំណួរទី ៩៖ តើត្រូវសរសេរអ្វីខ្លះនៅក្នុងដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ? (Slide 11)</u>**

ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៤១៩ កថា.១ បានកំណត់ថា "នៅពេលចាប់ផ្តើមនីតិវិធីនៃការលក់ដោយបង្ខំ តុលាការអនុវត្តត្រូវចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ហើយត្រូវប្រកាសអំពីការរឹបអូសអចលនវត្ថុដើម្បីម្ចាស់បំណុលនៃការអនុវត្តក្នុងដីកាសម្រេចចាប់ផ្តើមនេះ" ។ ហេតុនេះដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំត្រូវសរសេរថា ឧទាហរណ៍៖ "ត្រូវចាប់ផ្តើមនីតិវិធីលក់ដោយបង្ខំ ហើយត្រូវរឹបអូសអចលនវត្ថុ............ដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ដើម្បីសងបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកចំពោះម្ចាស់បំណុលនៃការអនុវត្ត ដោយផ្អែកលើហ៊ីប៉ូតែក............។" **<u>តុលាការអនុវត្តត្រូវប្រកាសអំពីការរឹបអូសនោះ ទោះបីជាគ្មានសរសេរអំពីការទាមទារឲ្យរឹបអូសនៅក្នុងពាក្យសុំឲ្យអនុវត្តហ៊ីប៉ូតែកក៏ដោយ</u>**។ ម្យ៉ាងវិញទៀត ចៅក្រមដែលបានចេញដីកាសម្រេច ត្រូវចុះហត្ថលេខាលើដីកាសម្រេចនោះ (ក្រមនីតិ/ណី មាត្រា ៣៣៥, មាត្រា ២១៣ កថា.២)។

លើសពីនេះទៀត នៅក្នុងដីកាសម្រេចចាំបាច់ត្រូវសរសេរអំពីសញ្ញាណនៃគូភាគី សញ្ញាណនៃហ៊ីប៉ូតែក សញ្ញាណនៃសិទ្ធិលើបំណុលដែលត្រូវបានធានា និង សញ្ញាណរបស់អចលនវត្ថុហ៊ីប៉ូតែក ជាអាទិ៍។ ប្រសិនបើសញ្ញាណរបស់កូនបំណុលនៃការអនុវត្ត និង សញ្ញាណរបស់អចលនវត្ថុហ៊ីប៉ូតែក ខុសពីលិខិតអនុវត្ត និង ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ នោះការផ្ទុកផ្តាក់ឲ្យចុះបញ្ជីមិនអាចធ្វើបានទេ។ ហេតុនេះ **<u>ចៅក្រមត្រូវអានឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ និង លិខិតអនុវត្តដោយយកចិត្តទុកដាក់ បន្ទាប់មក ចៅក្រមត្រូវសរសេរឈ្មោះរបស់កូនបំណុលនៃការអនុវត្ត និង សញ្ញាណនៃអចលនវត្ថុនៅក្នុងដីកាសម្រេចនោះ ឲ្យដូចគ្នាទៅនឹងឈ្មោះ និង សញ្ញាណនៃអចលនវត្ថុដែលមាននៅក្នុងឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ</u>**។

**<u>សំណួរទី ១០៖ តើតុលាការអនុវត្ត ត្រូវធ្វើដូចម្តេចក្នុងករណីដែលឈ្មោះរបស់អ្នកបង្កើតហ៊ីប៉ូតែកដែលបានសរសេរនៅក្នុងលិខិតអនុវត្ត ខុសពីឈ្មោះរបស់កម្មសិទ្ធិករ ដែលបានសរសេរនៅក្នុងឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ? (Slide 12 ~ 15)</u>**

តុលាការអនុវត្តត្រូវធ្វើការទាក់ទងទៅម្ចាស់បំណុលនៃការអនុវត្ត ដើម្បីធ្វើការបញ្ជាក់ថាបុគ្គលដែលត្រូវបានសរសេរនៅលើលិខិតអនុវត្ត និង បុគ្គលដែលត្រូវបានសរសេរនៅលើឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីជាមនុស្សតែមួយ ឬ ផ្សេងគ្នា។ ក្នុងករណី ជាមនុស្សផ្សេងគ្នា តុលាការអនុវត្តត្រូវលើកចោលពាក្យសុំ លើកលែងតែក្នុងករណីដែលត្រូវបានផ្តល់ដោយរូបមន្តអនុវត្តពិសេស (ក្រមនីតិ/ណី មាត្រា ៣៥៦ កថា.២)។ ទោះបីជា

ក្នុងករណីដែលពាក្យសុំត្រូវបានលើកចោលក៏ដោយ បើម្ចាស់បំណុលនៃការអនុវត្តទទួលបានការផ្តល់រូបមន្តអនុវត្តពិសេស នោះម្ចាស់បំណុលនៃការអនុវត្តអាចដាក់ពាក្យសុំឲ្យអនុវត្តហ៊ីប៉ូតែកម្តងទៀតបាន(ក្រមនីតិ/ណី មាត្រា ៣៥៦ កថា.២)។ រូបមន្តអនុវត្តពិសេសគឺ ឧទាហរណ៍ត្រូវបានប្រើប្រាស់ក្នុងករណីសិក្សាបែបនេះ។ ម្ចាស់បំណុលនៃការអនុវត្ត X មានសាលក្រមដែលមាន Y1 ជាអ្នកបង្កើតហ៊ីប៉ូតែក។ បន្ទាប់មក Y1 បានលក់អចលនវត្ថុហ៊ីប៉ូតែកទៅឲ្យ Y2។ X បានដាក់ពាក្យសុំឲ្យក្រឡាបញ្ជីផ្តល់រូបមន្តអនុវត្តពិសេស (ក្រមនីតិ/ណី មាត្រា ៣៥៤ កថា. ២, មាត្រា ៣៥៥)។ ក្រឡាបញ្ជីត្រូវត្រួតពិនិត្យអំពីរឿងដែល Y2 បានទទួលបន្តអចលនវត្ថុហ៊ីប៉ូតែកពី Y1 ត្រូវទទួលការអនុញ្ញាតពីតុលាការអនុវត្ត រួចត្រូវសរសេរអំពីការណ៍ដែល Y2 បានទទួលបន្តអចលនវត្ថុហ៊ីប៉ូតែកពី Y1 ទៅក្នុងឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត (ក្រមនីតិ/ណី មាត្រា ៣៥៦ កថា. ២~ ៤, មាត្រា ៣៥៧)។ នេះគឺជា រូបមន្តអនុវត្តពិសេស។ នៅក្នុងករណីដែល ម្ចាស់បំណុលនៃការអនុវត្តបានដាក់ឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលបានផ្តល់រូបមន្តអនុវត្តពិសេសរួច ទៅឲ្យតុលាការអនុវត្ត នោះតុលាការអនុវត្ត នឹងអាចដឹងអំពីការណ៍ដែល Y2 បានទទួលបន្តអចលនវត្ថុហ៊ីប៉ូតែកពី Y1 ។ ហេតុនេះ ទោះបីជានៅក្នុងលិខិតអនុវត្តមានសរសេរអំពី Y1 ដែលជាអ្នកបង្កើតហ៊ីប៉ូតែក ឬអត់ក៏ដោយ ក៏នីតិវិធីលក់ដោយបង្ខំអាចបន្តទៅបានដោយមាន Y2 ជាកូនបំណុលនៃការអនុវត្តដែរ។

ម្យ៉ាងទៀត បុគ្គលដែលត្រូវបានសរសេរនៅលើលិខិតអនុវត្ត និង បុគ្គលដែលត្រូវបានសរសេរនៅលើឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី គឺជាមនុស្សតែមួយ ប៉ុន្តែក៏អាចមានករណីដែលសរសេរខុសអក្ខរាវិរុទ្ធនៅលើលិខិតអនុវត្ត ឬ ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី។ ដោយសារតែករណីនេះមិនមានបញ្ញត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ដូច្នេះ ដំណោះស្រាយគឺ អាស្រ័យលើការអនុវត្តជាក់ស្តែងដែលមានលក្ខណៈសមរម្យ។ ក្នុងករណីជាក់ស្តែង ប្រសិនបើមានការបញ្ជាក់ច្បាស់លាស់ថា បុគ្គលដែលត្រូវបានសរសេរនៅលើលិខិតអនុវត្ត និង បុគ្គលដែលត្រូវបានសរសេរនៅលើឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី គឺជាមនុស្សតែមួយ នោះតុលាការអនុវត្តនឹងចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ព្រមទាំងសរសេរឈ្មោះទាំងពីរនោះនៅលើដីកាសម្រេចនេះ ។

**<u>សំណួរទី ១១៖ ក្នុងករណីដែលតុលាការអនុវត្តបានចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំលើដី បន្ទាប់មកក៏មានពាក្យសុំឲ្យអនុវត្តហ៊ីប៉ូតែក តើតុលាការអនុវត្តត្រូវធ្វើដូចម្តេច? (Slide 16 ~ 20)</u>**

តុលាការអនុវត្តនឹងធ្វើការពិនិត្យលើពាក្យសុំឲ្យអនុវត្តហ៊ីប៉ូតែក។ ប្រសិនបើមានភាពត្រឹមត្រូវ នោះតុលាការអនុវត្តនឹងចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ (ដីកាសម្រេចចាប់ផ្តើមត្រួតគ្នា ក្រមនីតិ/ណី មាត្រា ៥១១

កថា.១)។ លើសពីនេះ តុលាការអនុវត្ត ត្រូវជូនដំណឹងអំពីការណ៍ដែលបានចេញដីកាសម្រេចចាប់ផ្ដើមត្រួតគ្នាទៅឲ្យម្ចាស់បំណុលនៃការអនុវត្តដែលទាក់ទងនឹងដីកាសម្រេចចាប់ផ្ដើមមុន (មាត្រា ៥១១ កថា.១)។

ជាងទៅទៀតនេះ ក្រឡាបញ្ជី ត្រូវជូនដំណឹងទៅម្ចាស់បំណុលនៃការអនុវត្តដែលបានដាក់ពាក្យសុំឲ្យអនុវត្តហ៊ីប៉ូតែកដោយមធ្យោបាយសមរម្យ (ក្រមនីតិ/ណី មាត្រា ៣៣៥, មាត្រា ២១៣ កថា.១) ហើយត្រូវផ្ទុកផ្ដាក់ឲ្យចុះបញ្ជីអំពីការរឹបអូសដែលពាក់ព័ន្ធនឹងដីកាសម្រេចចាប់ផ្ដើមទៅរដ្ឋបាលសុរិយោដី (ក្រមនីតិ/ណី មាត្រា ៤២០) និង ត្រូវបញ្ជូនឯកសារចម្លងយថាភូតនៃដីកាសម្រេចចាប់ផ្ដើមទៅកូនបំណុលនៃការអនុវត្ត (ក្រមនីតិ/ណី មាត្រា ៤១៩ កថា.២)។ មកដល់ដំណាក់កាលនេះ តុលាការអនុវត្តមិនបន្តនីតិវិធីបន្ទាប់ពីនេះទេ ដោយបន្តតែនីតិវិធីនៃការលក់ដោយបង្ខំនៃដីកាសម្រេចចាប់ផ្ដើមមុនតែប៉ុណ្ណោះ។ ហើយម្ចាស់បំណុលនៃការអនុវត្តដែលបានដាក់ពាក្យសុំឲ្យអនុវត្តហ៊ីប៉ូតែកក្រោយ ក៏អាចទទួលបានចំណែកដែរ (ក្រមនីតិ/ណីមាត្រា ៥១៩, មាត្រា ៤៥៣ ចំណុច ក)។ ប្រសិនបើ នីតិវិធីលក់ដោយបង្ខំនៃដីកាសម្រេចចាប់ផ្ដើមមុន ត្រូវបានដក ឬ ត្រូវបានលុបចោល នោះតុលាការអនុវត្តត្រូវបន្តនីតិវិធីអនុវត្តហ៊ីប៉ូតែកនៃដីកាសម្រេចចាប់ផ្ដើមក្រោយ(ក្រមនីតិ/ណី មាត្រា ៥១១ កថា.២)។

**ដំណាក់កាលទី ៥. ការលើកចោលពាក្យសុំ៖** ក្នុងករណីដែលតុលាការអនុវត្តបានចេញដីកាសម្រេចលើកចោលពាក្យសុំ នោះតុលាការអនុវត្តត្រូវជូនដំណឹងទៅម្ចាស់បំណុលនៃការអនុវត្តដោយមធ្យោបាយសមរម្យ (ក្រមនីតិ/ណី មាត្រា ៣៣៥ មាត្រា២១៣ កថា.៣) ហើយនីតិវិធីនឹងត្រូវបញ្ចប់។ វាមិនមានភាពចាំបាច់ក្នុងការជូនដំណឹងទៅកូនបំណុលនៃការអនុវត្តទេ។ ម្យ៉ាងវិញទៀត ក្រឡាបញ្ជីត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់នូវហេតុការណ៍ និង វិធីនៃការជូនដំណឹងនោះដាក់នៅក្នុងសំណុំរឿងអំពីការណ៍ដែលបានជូនដំណឹង ( ក្រមនីតិ/ណី មាត្រា ៣៣៥, មាត្រា ២១៣ កថា.៣)។

**ដំណាក់កាលទី ៦. ដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំ៖** នៅពេលចេញដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំ តុលាការអនុវត្តត្រូវជូនដំណឹងដោយមធ្យោបាយសមរម្យទៅម្ចាស់បំណុលនៃការអនុវត្តអំពី ដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំនោះ។ ម្យ៉ាងទៀត ក្រឡាបញ្ជីត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់នូវហេតុការណ៍ និង វិធីនៃការជូនដំណឹងនោះដាក់ក្នុងសំណុំរឿងអំពីការណ៍ដែលបានជូនដំណឹង (ក្រមនីតិ/ណី មាត្រា ៣៣៥, មាត្រា ២១៣ កថា.៣)។ យ៉ាងណាមិញ ក្រឡាបញ្ជីត្រូវបញ្ជូនដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំទៅកូនបំណុលនៃការអនុវត្ត (មាត្រា ៤១៩ កថា.២) ប៉ុន្តែ ក្នុងដំណាក់កាលនេះកុំទាន់បញ្ជូនល្អជាង។

**សំណួរទី ១២៖ ហេតុអ្វីបានជានៅក្នុងដំណាក់កាលនេះ ការមិនទាន់បញ្ជូនដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំទៅកូនបំណុលនៃការអនុវត្តគឺ ការល្អជាង? (Slide 21 ~ 23)**

ប្រសិនបើ ដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំត្រូវបានបញ្ជូនទៅឲ្យកូនបំណុលនៃការអនុវត្ត នោះកូនបំណុលនៃការអនុវត្តនឹងដឹងអំពីការណ៍នៃការចាប់ផ្ដើមលក់ដោយបង្ខំ ហេតុនេះ គេបារម្ភថា កូនបំណុលនៃការអនុវត្តនឹងធ្វើអនុប្បទានអចលនវត្ថុហ៊ីប៉ូតែកទៅឲ្យតតិយជន ក្នុងគោលបំណងរារាំងការអនុវត្តនោះ។ ប្រសិនបើអចលនវត្ថុនោះត្រូវបានចុះបញ្ជីផ្ទេរកម្មសិទ្ធិនៅមុនពេលការចុះបញ្ជីរឹបអូស នោះគេមិនអាចចុះបញ្ជីអំពីការរឹបអូសនៅលើអចលនវត្ថុហ៊ីប៉ូតែកបានទេ ហេតុនេះតុលាការអនុវត្តត្រូវលុបចោលនីតិវិធីនៃការលក់ដោយបង្ខំ (ក្រមនីតិ/ណី មាត្រា ៤២៧)។ បន្ទាប់ពីម្ចាស់បំណុលនៃការអនុវត្តទទួលបាននូវវិបមន្តអនុវត្តពិសេស (ក្រមនីតិ/ណី មាត្រា ៣៥៦ កថា.២) នោះវាមានភាពចាំបាច់ក្នុងការដាក់ពាក្យសុំឲ្យអនុវត្តហ៊ីប៉ូតែកម្ដងទៀត ចំពោះអនុប្បទាយីនៃអចលនវត្ថុហ៊ីប៉ូតែក។ នីតិវិធីដែលបានធ្វើដូចបានរៀបរាប់ខាងលើនេះមានលក្ខណៈលំបាក ហេតុដូច្នេះ វាជាការល្អដែលតុលាការអនុវត្តធ្វើការបញ្ជូនដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំទៅឲ្យកូនបំណុលនៃការអនុវត្ត បន្ទាប់ពីបានធ្វើការបញ្ជាក់អំពីការចុះបញ្ជីឲ្យរឹបអូសរួច។

**ដំណាក់កាលទី ៧. ការផ្ញើកផ្ដាក់ឲ្យចុះបញ្ជីរឹបអូស៖** ក្នុងករណីដែលតុលាការអនុវត្តបានចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ក្រឡាបញ្ជីត្រូវធ្វើលិខិតផ្ញើកផ្ដាក់ឲ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុឲ្យបានឆាប់រហ័ស ហើយត្រូវបញ្ជូនលិខិតផ្ញើកផ្ដាក់នេះទៅរដ្ឋបាលសុរិយោដី រាជធានី/ខេត្ត ដែលអចលនវត្ថុនោះតាំងនៅ (ក្រមនីតិ/ណី មាត្រា ៤២០ កថា.១, ប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ប្រការ ៤ កថា.១)។

**សំណួរទី ១៣៖ តើលិខិតផ្ញើកផ្ដាក់ឲ្យចុះបញ្ជីត្រូវបង្កើតឡើងដោយរបៀបណា?**

របៀបនៃការសរសេរលិខិតផ្ញើកផ្ដាក់ឲ្យចុះបញ្ជី គឺមានកំណត់នៅក្នុងប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ប្រការ ៥, ប្រការ ១០ និង មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី ៤ នៃប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណីនេះដែរ ។

**កម្មវត្ថុ៖** ឧទាហរណ៍ គេសរសេរថា "ផ្ទុកផ្ដាក់ឲ្យចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិលើអចលនវត្ថុផ្អែកតាមការអនុវត្តសិទ្ធិប្រាតិភោគ"។

- **ក- អត្តសញ្ញាណនៃអចលនវត្ថុ៖** ត្រូវសរសេរ លេខក្បាលដី ឬ លេខប័ណ្ណ និងទីតាំងដី។ **ក្រឡាបញ្ជី ត្រូវអានដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ និង ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុឲ្យបានច្បាស់លាស់ ហើយត្រូវសរសេរតាមអត្តសញ្ញាណទាំងនេះ។**
- **ខ- ឈ្មោះ និងអាសយដ្ឋានរបស់កម្មសិទ្ធិករ (ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគី) នៃអចលនវត្ថុ៖ ក្រឡាបញ្ជីត្រូវអានដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ និង ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុឲ្យបានច្បាស់លាស់ ហើយត្រូវសរសេរតាមអត្តសញ្ញាណទាំងនេះ។**
- **គ- គោលបំណងនៃការចុះបញ្ជី៖** ឧទាហរណ៍ គេសរសេរថា "រឹបអូសកម្មសិទ្ធិលើអចលនវត្ថុ ចំណុច "ក" ។
- **ឃ- មូលហេតុ៖** ឧទាហរណ៍ គេសរសេរថា " ដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ លេខ ១២៣៤ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៥ របស់សាលាដំបូងខេត្តកំពត"។
- **ង- ឈ្មោះ និង អាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត៖ ក្រឡាបញ្ជី ត្រូវអានដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំឲ្យបានច្បាស់លាស់ ហើយត្រូវសរសេរឲ្យដូចអត្តសញ្ញាណដែលមានកំណត់នៅក្នុងដីកាសម្រេចនោះ។**
- **ច- ឈ្មោះ និង អាសយដ្ឋានរបស់កូនបំណុលនៃការអនុវត្ត៖ ក្រឡាបញ្ជី ត្រូវអានដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ និង ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុឲ្យបានច្បាស់ ហើយត្រូវសរសេរឲ្យដូចអត្តសញ្ញាណដែលមានកំណត់នៅក្នុងឯកសារទាំងនោះ**។ ប្រសិនបើ ឈ្មោះដែលបានសរសេរក្នុងដីកាសម្រេចចាប់ផ្ដើមឲ្យលក់ដោយបង្ខំ និង ឈ្មោះដែលបានសរសេរនៅក្នុងឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុខុសគ្នា នោះវានឹងមានបញ្ហា។ ក្រមនីតិវិធីរដ្ឋប្បវេណីមិនបានកំណត់អំពីករណីនេះ ហេតុដូច្នេះ ដំណោះស្រាយគឺ អាស្រ័យទៅតាមការអនុវត្តជាក់ស្ដែងដែលមានលក្ខណៈសមស្រប។ ប្រសិនបើ មានកំហុសក្នុងការសរសេរនៅក្នុងដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ តុលាការអនុវត្តគប្បីធ្វើការកែតម្រូវ មុនពេលផ្ទុកផ្ដាក់ឲ្យចុះបញ្ជី។ ប្រសិនបើ មានកំហុសចំពោះការចុះបញ្ជីអចលនវត្ថុ តុលាការអនុវត្ត គប្បីសរសេរអក្ខរាវិរុទ្ធឲ្យបានត្រឹមត្រូវនៅលើលិខិតផ្ទុកផ្ដាក់។ ប៉ុន្តែ ក្នុងករណីដែលអក្ខរាវិរុទ្ធនៃលិខិតផ្ទុកផ្ដាក់ខុសពីអក្ខរាវិរុទ្ធនៃការចុះបញ្ជីអចលនវត្ថុ នោះការផ្ទុកផ្ដាក់ឲ្យចុះបញ្ជីនឹងត្រូវបានលើក

ចោល។ ហេតុនេះ គេសរសេរអក្ខរាវិរុទ្ធនៃឈ្មោះទាំងពីរនៅលើលិខិតផ្ទុកផ្តាក់។ ជនដែលពាក់ព័ន្ធ ចាំបាច់ត្រូវរកមធ្យោបាយផ្សេងៗដើម្បីបន្តការអនុវត្តទៅមុខ។

ឯកសារដែលត្រូវតែភ្ជាប់ជាមួយនឹងលិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជី

-ឯកសារចម្លងយថាភូតនៃដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ

*មិនមានភាពចាំបាច់ដែលត្រូវភ្ជាប់ប័ណ្ណកម្មសិទ្ធិនៃអចលនវត្ថុទេ។

**សំណួរទី ១៤ ៖ តើត្រូវបង់សោហ៊ុយ និង ពន្ធដែលពាក់ព័ន្ធនឹងការចុះបញ្ជីយ៉ាងដូចម្តេច?**

ក្រឡាបញ្ជី ត្រូវ**បង់សោហ៊ុយ និង ពន្ធដែលទទួលបានពីម្ចាស់បំណុលនៃការអនុវត្ត ដែលបានបង់សោហ៊ុយជាមុន ទៅតុលាការអនុវត្ត**។ ក្រមនីតិវិធីរដ្ឋប្បវេណីមិនមានកំណត់អំពីវិធីនៃការបង់នេះទេ ដូច្នេះ ដំណោះស្រាយគឺអាស្រ័យទៅលើការអនុវត្តជាក់ស្តែងដែលមានលក្ខណៈសមស្រប។ ឧទាហរណ៍ ដូចជា វិធីដែលក្រឡាបញ្ជីធ្វើការបញ្ជូនលិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីទៅរដ្ឋបាលសុរិយោដីដោយភ្ជាប់ជាមួយនឹងសោហ៊ុយ និង ពន្ធដែលទទួលបានពីម្ចាស់បំណុលនៃការអនុវត្ត ដែលបានបង់សោហ៊ុយជាមុន ជាអាទិ៍ ។

**ដំណាក់កាលទី ៨. ការចុះបញ្ជីអំពីការរឹបអូសៈ** ប្រសិនបើមន្ត្រីចុះបញ្ជីបានទទួលលិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីហើយ មន្ត្រីចុះបញ្ជីនោះត្រូវធ្វើការចុះបញ្ជីអំពីការរឹបអូស (យោងតាមក្រមនីតិ/ណី មាត្រា ៤២០ កថា.២, ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ប្រការ ២៦)។

**សំណួរទី ១៥៖ តើមន្ត្រីចុះបញ្ជីដែលបានទទួលលិខិតផ្ទុកផ្តាក់អំពីការចុះបញ្ជី ត្រូវសរសេរអ្វីខ្លះនៅក្នុងសៀវភៅគោលបញ្ជី?**

របៀបនៃការចុះបញ្ជី ត្រូវបានកំណត់នៅក្នុងប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ប្រការ ២៦។ យោងតាមប្រការនេះ ជាឧទាហរណ៍នៅក្នុង "ខ្ទង់បន្ទុកនៃអចលនវត្ថុ" នៃសៀវភៅគោលបញ្ជីត្រូវសរសេរដូចខាងក្រោម។ វាមានភាពចាំបាច់ក្នុងការប្រើប្រាស់ពាក្យពេចន៍ឲ្យស្របទៅនឹងការអនុវត្តជាក់ស្តែង។

"ត្រូវបានរឹបអូសកម្មសិទ្ធិតាមដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំ លេខ ១២៣៤ ចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៥ ដោយតុលាការអនុវត្តនៃសាលាដំបូងខេត្តកំពត ល.រ Aj 5678 "។ (សរសេរជាទឹកក្រហម)។

បោះត្រាលេខាចារឹកនៅ ថ្ងៃទី១០ ខែសីហា ឆ្នាំ ២០១៥ (សរសេរជាទឹកខៀវ ឬ ទឹកខ្មៅ)

**<u>សំណួរទី ១៦៖ តើមន្ត្រីចុះបញ្ជីត្រូវធ្វើដូចម្តេច ក្នុងករណីឈ្មោះរបស់កូនបំណុលនៃការអនុវត្តដែលបានសរសេរនៅក្នុងលិខិតផ្ទុកផ្តាក់ខុសពីឈ្មោះដែលបានសរសេរនៅលើឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ?</u>**

ជាដំបូង មន្ត្រីចុះបញ្ជី ត្រូវទាក់ទងទៅក្រឡាបញ្ជីឲ្យធ្វើការបញ្ជាក់អំពីមូលហេតុដែលខុសនោះ។ ប្រសិនបើក្រឡាបញ្ជីសរសេរអក្ខរាវិរុទ្ធខុសនៅលើលិខិតផ្ទុកផ្តាក់ នោះមន្ត្រីចុះបញ្ជីត្រូវបង្គាប់ឲ្យក្រឡាបញ្ជីធ្វើការកែតម្រូវ។ ក្នុងករណីដែលកូនបំណុលនៃការអនុវត្ត និង កម្មសិទ្ធិករដែលត្រូវបានចុះបញ្ជីជាបុគ្គលផ្សេងគ្នា នោះការចុះបញ្ជីអំពីការរឹបអូសនឹងមិនអាចធ្វើទៅបានទេ។ ហេតុនេះ ក្រឡាបញ្ជីត្រូវដកការផ្ទុកផ្តាក់ ឬ មន្ត្រីចុះបញ្ជីត្រូវលើកចោលការផ្ទុកផ្តាក់នោះ (ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ប្រការ ៩)។ ក្នុងករណីនេះ ដោយសារតែមិនអាចធ្វើការបន្តនីតិវិធីលក់ដោយបង្ខំបាន ដូច្នេះ តុលាការអនុវត្តត្រូវលុបចោលនីតិវិធីនៃការលក់ដោយបង្ខំ (ក្រមនីតិ/ណី មាត្រា ៤២៧)។

**<u>សំណួរទី ១៧៖ ក្នុងករណីដែលអចលនវត្ថុហ៊ីប៉ូតែកតែមួយត្រូវបានចុះបញ្ជីអំពីការរឹបអូសរួច ហើយត្រូវបានផ្ទុកផ្តាក់ឲ្យចុះបញ្ជីអំពីរឹបអូសបន្ថែមទៀត តើមន្ត្រីចុះបញ្ជីត្រូវធ្វើដូចម្តេច?</u>**

ក្នុងករណីដែលដីកាសម្រេចឲ្យចាប់ផ្តើមលក់ដោយបង្ខំត្រួតគ្នាត្រូវបានចេញចំពោះអចលនវត្ថុតែមួយ គឺមិនមានបញ្ហាទេ ព្រោះមាននីតិវិធីធម្មតាដែលត្រូវបានបញ្ញត្តិក្នុងក្រមនីតិវិធីរដ្ឋប្បវេណី (ក្រមនីតិ/ណីមាត្រា ៤២៤, មាត្រា ៥១១, មាត្រា ៥១២)។ ហេតុនេះ **<u>មន្ត្រីចុះបញ្ជីត្រូវចុះបញ្ជីអំពីការរឹបអូសតាមធម្មតា។</u>**

**<u>សំណួរទី ១៨ ៖ ក្រោយការចុះបញ្ជីអំពីការរឹបអូស តើកូនបំណុលនៃការអនុវត្តអាចបន្តការប្រើប្រាស់អចលនវត្ថុហ៊ីប៉ូតែកបានដែរ ឬទេ?</u>**

ការរឹបអូសពុំត្រូវរារាំងកូនបំណុលនៃការអនុវត្តក្នុងការប្រើប្រាស់ ឬ អាស្រ័យផលពីអចលនវត្ថុតាមវិធីប្រើធម្មតាឡើយ (ក្រមនីតិ/ណី មាត្រា ៤២១ កថា.៣)។ ពោលគឺ ក្នុងករណីដែលកូនបំណុលនៃការអនុវត្តមានផ្ទះផ្ទាល់ខ្លួននៅលើអចលនវត្ថុហ៊ីប៉ូតែក គឺកូនបំណុលនៃការអនុវត្តអាចបន្តការរស់នៅបាន ហើយប្រសិនបើមានរោងចក្រក៏អាចបន្តការងារនៅក្នុងរោងចក្រនោះបានដែរ។

ប្រសិនបើអចលនវត្ថុហ៊ីប៉ូតែកនោះ គឺជាដីកសិកម្ម ក៏កូនបំណុលនៃការអនុវត្តអាចបន្តការធ្វើកសិកម្មបានដែរ ប៉ុន្តែ ហ៊ីប៉ូតែកនឹងត្រូវមានអានុភាពលើផលក្រោយពេលរឹបអូស (ក្រមរដ្ឋ/ណី មាត្រា ៨៤៨, មាត្រា ៨៤៩ កថា.២) ដូច្នេះ ផលដែលកើតឡើងក្រោយការរឹបអូសនឹងត្រូវបានលក់ដោយបង្ខំជាមួយនឹងអចលនវត្ថុហ៊ីប៉ូតែកនោះ។

ហេតុនេះ កូនបំណុលនៃការអនុវត្តមិនអាចកាន់កាប់ផលដែលបានមកពីអចលនវត្ថុហ៊ីប៉ូតែកក្រោយការរឹបអូសបានទេ បើគ្មានការយល់ព្រមពីម្ចាស់បំណុលនៃការអនុវត្ត។

ប្រសិនបើអចលនវត្ថុហ៊ីប៉ូតែកនោះគឺជា Apartment សម្រាប់ជួល កូនបំណុលនៃការអនុវត្តក៏អាចបន្តការជួលទៀតបានដែរ ប៉ុន្តែ ហ៊ីប៉ូតែកនឹងត្រូវមានអានុភាពលើសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលពេលថ្ងៃកំណត់សងបានមកដល់ក្រោយពេលរឹបអូស (ក្រមរដ្ឋ/ណី មាត្រា ៨៤៨, មាត្រា ៨៤៩ កថា.២) ដូច្នេះ ម្ចាស់បំណុលនៃការអនុវត្តអាចដាក់ពាក្យសុំឲ្យរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលនោះបាន។ ក្នុងករណីនេះ តុលាការអនុវត្តត្រូវបញ្ជូនដីកាសម្រេច អំពីការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលទៅភតិកៈនៃអចលនវត្ថុហ៊ីប៉ូតែក ហើយភតិកៈត្រូវធ្វើប្រាក់ថ្លៃឈ្នួលនោះទៅតុលាការអនុវត្ត (ចាប់ពី មាត្រា ៥១៦ នៃក្រមនីតិ/ណី)។

**<u>សំណួរទី ១៩៖ ក្រោយពីបានចុះបញ្ជីអំពីការរឹបអូសផ្អែកតាមហ៊ីប៉ូតែករបស់ម្ចាស់បំណុល X កូនបំណុលនៃការអនុវត្តបានបង្កើតហ៊ីប៉ូតែកលើអចលនវត្ថុដើម្បីធានាបំណុលឲ្យ A ហើយក៏បានទៅចុះបញ្ជីរួមគ្នាជាមួយ A ។ លើសពីនេះ កូនបំណុលនៃការអនុវត្តបានលក់អចលនវត្ថុនោះទៅឲ្យ B ហើយក៏បានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិជាមួយ B ។ តើមន្ត្រីចុះបញ្ជីត្រូវធ្វើដូចម្តេច? (Slide ២៤~២៦)</u>**




ក្រមនីតិវិធីរដ្ឋប្បវេណី និង ប្រកាសអន្តរក្រសួងទាក់ទងនឹងការចុះបញ្ជីអចលនវត្ថុ មិនផ្តល់សមត្ថកិច្ចទៅឲ្យមន្ត្រីចុះបញ្ជីធ្វើការបដិសេធនូវការទទួលពាក្យសុំចុះបញ្ជីបង្កើតហ៊ីប៉ូតែក និង ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិ ជាអាទិ៍ក្រោយការចុះបញ្ជីរឹបអូសទេ។ ហេតុនេះ <u>មន្ត្រីចុះបញ្ជីត្រូវទទួលការចុះបញ្ជី ហើយត្រូវសរសេរចូលក្នុងសៀវភៅគោលបញ្ជី</u>។

បន្ទាប់មក នីតិវិធីនៃការអនុវត្តហ៊ីប៉ូតែកនឹងត្រូវបានបន្ត ប្រសិនបើអចលនវត្ថុហ៊ីប៉ូតែកត្រូវបានលក់ដោយបង្ខំនោះហ៊ីប៉ូតែករបស់ A និង ការផ្ទេរកម្មសិទ្ធិទៅឲ្យ B ផងដែរនោះនឹងត្រូវរលត់ (ក្រមនីតិ/ណី មាត្រា ៥១០ កថា.១ និង

កថា.២)។ លើសពីនេះ ក្រឡាបញ្ជីត្រូវធ្វើការផ្ទុកផ្ដាក់ឲ្យចុះបញ្ជីអំពីការលុបការចុះបញ្ជីបង្កើតហ៊ីប៉ូតែករបស់ A និង ការលុបការចុះបញ្ជីផ្ទេរកម្មសិទ្ធិទៅឲ្យ B (ក្រមនីតិ/ណី មាត្រា ៤៤៨ កថា.១ ចំណុច ខ) ដូច្នេះ មន្ត្រីចុះបញ្ជីត្រូវលុប ការចុះបញ្ជីទាំងនោះផ្អែកតាមលិខិតផ្ទុកផ្ដាក់នោះ។ ផ្ទុយទៅវិញ ករណីដែលការរឹបអូសផ្អែកតាមហ៊ីប៉ូតែករបស់ X ត្រូវ បាន ដក ឬ លុបចោល នោះទាំងហ៊ីប៉ូតែករបស់ A និង ការផ្ទេរកម្មសិទ្ធិទៅឲ្យ B គឺមានអានុភាពពេញលេញ។

**ដំណាក់កាលទី ៩. ការបញ្ជូនឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ៖** **ក្រោយពីបានចុះបញ្ជីអំពីការរឹបអូសរួចរាល់ហើយ រដ្ឋបាលសុរិយោដីត្រូវបញ្ជូនលិខិតផ្ទុកផ្ដាក់ដែលបានធ្វើរួច ទៅក្រឡាបញ្ជីដោយមានភ្ជាប់ជាមួយនឹងសេចក្ដីបញ្ជាក់ពីប្រធានរដ្ឋបាលសុរិយោដី រាជធានី/ខេត្ត ថា "បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម" លើឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ** (ក្រមនីតិ/ណី មាត្រា ៥២០ កថា.២ ប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ប្រការ ៣៨)។ (Slide 27)

**ដំណាក់កាលទី ១០. ការបញ្ជូនដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំទៅកូនបំណុលនៃការអនុវត្ត៖** តុលាការអនុវត្តត្រូវមើលឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុដែលបានទទួលពីរដ្ឋបាលសុរិយោដី ហើយបន្ទាប់ពីតុលាការអនុវត្តបានធ្វើការបញ្ជាក់អំពីការសម្រេចឲ្យចុះបញ្ជីអំពីការរឹបអូសរួចហើយ ត្រូវបញ្ជូនដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំទៅកូនបំណុលនៃការអនុវត្ត (ក្រមនីតិ/ណី ៥១៩ កថា.២)។ (Slide 28)

## ផ្នែកទី២ ការលក់

នៅក្នុងផ្នែកទី ១ នៃនីតិវិធីនៃការរឹបអូស ម្ចាស់បំណុលនៃការអនុវត្ត តុលាការអនុវត្ត និងមន្ត្រីចុះបញ្ជី អ្នកទាំង ៣ នេះ ធ្វើនីតិវិធីដោយសម្ងាត់។ ប៉ុន្តែ ចាប់ពីផ្នែកទី ២ នៃនីតិវិធីនៃការលក់ នីតិវិធីត្រូវបើកជាសាធារណៈ។ មូលហេតុដែលធ្វើបែបនេះ មាន ២។ មូលហេតុទី ១ គឺ ជូនដំណឹងទៅម្ចាស់បំណុលរបស់កូនបំណុលនៃការអនុវត្ត អំពីនីតិវិធី ដើម្បីផ្ដល់ឱកាសឲ្យអ្នកទាំងនោះទទួលបានការចែកចំណែក។ មូលហេតុមួយទៀតគឺ ជូនដំណឹងទៅប្រជាជនទូទៅអំពីនីតិវិធី ដើម្បីស្វែងរកអ្នកដែលចង់ទិញអចលនវត្ថុហ៊ីប៉ូតែក។ (Slide 29,30)

វិធីជូនដំណឹងអំពីនីតិវិធីដល់ម្ចាស់បំណុល មានសរសេរនៅក្នុងដំណាក់កាលចាប់ពីទី ១១ ដល់ទី ១៣។ តុលាការអនុវត្តចាំបាច់ត្រូវធ្វើការជូនដំណឹងអំពីនីតិវិធីទៅម្ចាស់បំណុលដោយប្រើវិធី ២ គឺ "ការប្រកាសអំពីការកំណត់

ពេលចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក" និង "ការដាស់តឿនឲ្យរាយការណ៍អំពីសិទ្ធិលើបំណុល"។ ការប្រកាសអំពីការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក" គឺជាការជូនដំណឹងទៅម្ចាស់បំណុលទាំងអស់ថា ម្ចាស់បំណុលដែលចង់បានចំណែក សូមធ្វើការទាមទារឲ្យចែកចំណែកនៅតុលាការអនុវត្ត។ "ការដាស់តឿនឲ្យរាយការណ៍អំពីសិទ្ធិលើបំណុល" គឺជាការសាកសួរទៅកាន់ម្ចាស់បំណុលដែលតុលាការអនុវត្តស្គាល់ថា សិទ្ធិលើបំណុលរបស់អ្នកមានចំនួនប៉ុន្មាន? (Slide 28)

ការជូនដំណឹងអំពីនីតិវិធីដល់ប្រជាជនទូទៅ មានសរសេរនៅក្នុងដំណាក់កាលចាប់ពីទី ១៤ ដល់ទី ១៨។ នីតិវិធីនេះ ធ្វើឡើងដើម្បីស្វែងរកអ្នកដែលចង់ទិញអចលនវត្ថុហ៊ីប៉ូតែក និងផ្តល់ឱកាសឲ្យពួកគេបានចូលរួមក្នុងការលក់។ ហេតុនេះ តុលាការអនុវត្ត នឹងផ្តល់ព័ត៌មានសំខាន់ ៣ ទៅដល់ប្រជាជនទូទៅគឺ ស្ថានភាពអចលនវត្ថុ តម្លៃអចលនវត្ថុ ព្រមទាំងកាលបរិច្ឆេទ និង ទីកន្លែងនៃការលក់។ ចាប់ពីដំណាក់កាលទី ១៤ ដល់ដំណាក់កាលទី ១៨ គឺជានីតិវិធីដែលតុលាការអនុវត្តប្រមូលព័ត៌មានអំពីចំណុចទាំង ៣ នេះ និង បើកជាសាធារណៈដល់ប្រជាជនទូទៅ។

**ដំណាក់កាលទី ១១. ដីកាសម្រេចកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក និង ការប្រកាសជាសាធារណៈ ៖** ក្រោយពីតុលាការអនុវត្ត បានធ្វើការបញ្ជាក់អំពីការសម្រេចឲ្យចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកតាមឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ តុលាការអនុវត្ត ត្រូវកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក ហើយត្រូវធ្វើការប្រកាសជាសាធារណៈអំពីការណ៍ ដែលដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំត្រូវបានចេញ និង អំពីពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក (ក្រមនីតិ/ណី មាត្រា ៤២២ កថា.១, កថា.២)។(Slide 31)

**ដំណាក់កាលទី ១២. ការទាមទារឲ្យចែកចំណែក៖** ករណីមានម្ចាស់បំណុលផ្សេងទៀតក្រៅពីម្ចាស់បំណុលនៃការអនុវត្តក៏ដោយ ក៏ម្ចាស់បំណុលនោះអាចទាមទារឲ្យចែកចំណែកក្នុងអំឡុងពេលចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែកបានដែរ(ក្រមនីតិ/ណី មាត្រា ៤២៦)។

**សំណួរទី ២០៖ តើអ្នកណាខ្លះដែលអាចទាមទារឲ្យចែកចំណែកបាន? (Slide 32 ~ 40)**

ម្ចាស់បំណុលរបស់កូនបំណុលនៃការអនុវត្តទាំងអស់ មិនមែនសុទ្ធតែអាចទាមទារឲ្យចែកចំណែកបាននោះទេ គឺមានតែម្ចាស់បំណុលខាងក្រោមតែប៉ុណ្ណោះ ទើបអាចទាមទារឲ្យចែកចំណែកបាន (ក្រមនីតិ/ណី មាត្រា ៤២៦ កថា.១)៖

ក. ម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ភ្ជាប់ជាមួយរូបមន្តអនុវត្ត ឬ ម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូត ដូចមានកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៣៥៤ កថា.១ ចំណុច ក ខ គ។ ប៉ុន្តែ ប្រសិនបើមានសិទ្ធិប្រាតិភោគប្រត្យក្ស (ហ៊ីប៉ូតែក ឬ ការបញ្ចាំអចលនវត្ថុ) ដែលត្រូវបានចុះបញ្ជីមុនហ៊ីប៉ូតែករបស់ម្ចាស់បំណុលនៃការអនុវត្ត នោះម្ចាស់បំណុលដែលត្រូវបានចុះបញ្ជីសិទ្ធិប្រាតិភោគប្រត្យក្សមុន មិនអាចទាមទារឲ្យចែកចំណែកបានទេ ។ ប្រសិនបើ ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគប្រត្យក្សបែបនេះចង់ទទួលបានចំណែកនោះ ចាំបាច់ត្រូវដាក់ពាក្យសុំឲ្យអនុវត្តប្រាតិភោគ ហើយទទួលដីកាសម្រេចចាប់ផ្តើមត្រួតគ្នា (ក្រមនីតិ/ណី មាត្រា ៥១២, មាត្រា ៥១៣ កថា.២, មាត្រា ៥១៩)។

ខ. ម្ចាស់បំណុលដែលត្រូវបានចុះបញ្ជីអំពីការរឹបអូសបណ្តោះអាសន្ន នៅក្រោយពេលចុះបញ្ជីអំពីការរឹបអូស

គ. ម្ចាស់បំណុលដែលបានបញ្ជាក់ដោយឯកសារថា មានឯកសិទ្ធិជាទូទៅ

**សំណួរទី ២១៖ តើការទាមទារឲ្យចែកចំណែកត្រូវធ្វើឡើងយ៉ាងដូចម្តេច?**

ម្ចាស់បំណុល ត្រូវប្រគល់លិខិតលាយលក្ខណ៍អក្សរ ដោយសរសេរនូវមូលហេតុ និង ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល (ប្រាក់ដើម ការប្រាក់ ប្រាក់នៃសំណងការខូចខាតដោយសារការយឺតយ៉ាវ) ដាក់ជូនតុលាការអនុវត្ត (ក្រមនីតិ/ណី មាត្រា ៤២៦ កថា.២)។

**សំណួរទី ២២៖ តើតុលាការអនុវត្តដែលបានទទួលការទាមទារឲ្យចែកចំណែកត្រូវធ្វើដូចម្តេច?**

បើមានការទាមទារឲ្យចែកចំណែក តុលាការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នោះទៅឲ្យម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត (ក្រមនីតិ/ណី មាត្រា ៤២៦ កថា.៣)។ ប្រសិនបើខ្លឹមសារនៃការទាមទារឲ្យចែកចំណែកមិនពិតប្រាកដ ឬ ច្រើនហួសហេតុ នោះម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្តនឹងបាត់បង់នូវផលប្រយោជន៍។ ដូច្នេះ តុលាការអនុវត្តត្រូវសរសេរចំនួនទឹកប្រាក់ដែលត្រូវបានទាមទារឲ្យចែកចំណែក នៅពេលជូនដំណឹង ឬ ភ្ជាប់ឯកសារចម្លងនៃលិខិតទាមទារឲ្យចែកចំណែក។

**ដំណាក់កាលទី ១៣. ការដាស់តឿនឲ្យរាយការណ៍អំពីសិទ្ធិលើបំណុល៖** តុលាការអនុវត្ត ត្រូវដាស់តឿនម្ចាស់បំណុល ដែលបានកំណត់ ឲ្យរាយការណ៍អំពីសិទ្ធិលើបំណុល (ក្រមនីតិ/ណី មាត្រា ៤២២ កថា.២)។

(Slide 41 ~ 46)

**<u>សំណួរទី ២៣៖ ប្រសិនបើ ម្ចាស់បំណុលដែលទទួលការដាស់តឿន មិនបានរាយការណ៍អំពីសិទ្ធិលើបំណុល តើតុលាការអនុវត្តត្រូវធ្វើដូចម្តេច?</u>**

ម្ចាស់បំណុលដែលទទួលការដាស់តឿន មានកាតព្វកិច្ចត្រូវរាយការណ៍អំពីសិទ្ធិលើបំណុល ទៅតុលាការអនុវត្ត (ក្រមនីតិ/ណី មាត្រា ៤២៣ កថា.១)។ ប៉ុន្តែ ទោះបីជាមិនបានរាយការណ៍អំពីសិទ្ធិលើបំណុលក៏ដោយ ក៏មិនមែនមានន័យថា សិទ្ធិលើបំណុលនោះត្រូវរលត់ដែរ។ ហេតុនេះ ប្រសិនបើ ម្ចាស់បំណុលដែលមិនបានធ្វើសេចក្តីរាយការណ៍អំពីសិទ្ធិលើបំណុល មានលក្ខណៈដូចគ្នានឹងម្ចាស់បំណុលដែលត្រូវទទួលចំណែកដូចដែលមានកំណត់នៅក្នុង មាត្រា ៥១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី នោះតុលាការអនុវត្ត **<u>ត្រូវធ្វើការចែកចំណែកជាធម្មតាចំពោះម្ចាស់បំណុលទាំងនោះ</u>**។ ប៉ុន្តែ ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៤២៣ បញ្ញត្តថា ម្ចាស់បំណុលដែលពុំបានធ្វើសេចក្តីរាយការណ៍ ឬ បានធ្វើសេចក្តីរាយការណ៍មិនពិតដោយចេតនា ឬ ដោយមានកំហុស ត្រូវទទួលខុសត្រូវសងការខូចខាតដែលកើតឡើងដោយសារហេតុនោះ (ក្រមនីតិ/ណី មាត្រា ៤២៣ កថា.៣)។

**ដំណាក់កាលទី ១៤ . ការវាយតម្លៃ៖** តុលាការអនុវត្ត ត្រូវជ្រើសតាំងអ្នកវាយតម្លៃ និង បង្គាប់ឲ្យវាយតម្លៃអចលនវត្ថុ ដោយផ្អែកលើការស្រាវជ្រាវអំពីសណ្ឋាននៃអចលនវត្ថុ ទំនាក់ទំនងនៃការកាន់កាប់ និង ស្ថានភាពបច្ចុប្បន្នឯទៀត (ក្រមនីតិ/ណី មាត្រា ៤៣០ កថា.១)។ ប្រសិនបើ អ្នកវាយតម្លៃទទួលបានការបង្គាប់ឲ្យវាយតម្លៃ នោះអ្នកវាយតម្លៃត្រូវធ្វើការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុហើយប៉ុន្តែក និង ធ្វើការវាយតម្លៃអំពីចំនួនទឹកប្រាក់ បន្ទាប់មកអ្នកវាយតម្លៃនោះត្រូវសរសេរចូលក្នុងរបាយការណ៍វាយតម្លៃ ហើយដាក់ជូនទៅតុលាការអនុវត្ត (ក្រមនីតិ/ណី មាត្រា ៤៣០ កថា.៥)។ (Slide 47 ~ 49)

**<u>សំណួរទី ២៤៖ ប្រសិនបើអ្នកកាន់កាប់អចលនវត្ថុហ៊ីប៉ូតែក មិនចូលរួមសហការក្នុងការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្នទេ តើអ្នកវាយតម្លៃត្រូវធ្វើដូចម្តេច?</u>**

នៅពេលស្រាវជ្រាវដើម្បីវាយតម្លៃ អ្នកវាយតម្លៃអាចចូលទៅកាន់អចលនវត្ថុ ឬ អាចសួរសំណួរ ឬ ទាមទារឲ្យបង្ហាញឯកសារពីកូនបំណុលនៃការអនុវត្ត ឬ តតិយជនដែលកាន់កាប់អចលនវត្ថុនោះបាន (ក្រមនីតិ/ណី មាត្រា ៤៣០ កថា.៣) ។ អ្នកវាយតម្លៃអាចចូលទៅដល់ទីកន្លែងនៃអចលនវត្ថុហ៊ីប៉ូតែកបាន ដោយមិនចាំបាច់មានការយល់ព្រមពីអ្នកកាន់កាប់អចលនវត្ថុហ៊ីប៉ូតែក និង កូនបំណុលនៃការអនុវត្តឡើយ ដូច្នេះ ទោះបីជាអ្នកកាន់កាប់អចលនវត្ថុហ៊ីប៉ូតែកមិននៅក៏ដោយ ក៏អ្នកវាយតម្លៃអាចចូលបានដែរ។ ប៉ុន្តែ ប្រសិនបើ អចលនវត្ថុហ៊ីប៉ូតែកនោះជាដីកសិកម្ម ហាង ឬ រោងចក្រ ជាអាទិ៍ នោះវាមិនមានបញ្ហាទេ។ ប៉ុន្តែបើ អចលនវត្ថុហ៊ីប៉ូតែកជាទីកន្លែងដែលមនុស្សរស់នៅ ហើយបើអ្នកចម្បងនៃទីកន្លែងរស់នៅមិននៅ នោះត្រូវឲ្យមានវត្តមានរបស់មន្ត្រីឃុំ សង្កាត់ មន្ត្រីនគរបាល ឬ អ្នកដទៃទៀតដែលអាចទទួលស្គាល់ថាជាសាក្សីសមរម្យ (ក្រមនីតិ/ណី មាត្រា ៣៣៩)។

លើសពីនេះ ក្នុងករណីដែលអ្នកវាយតម្លៃមិនអាចចូលទៅខាងក្នុងអចលនវត្ថុហ៊ីប៉ូតែកបាន ដោយសារជាប់សោរ នោះអ្នកវាយតម្លៃមិនត្រូវបើកសោរនោះតាមទំនើងចិត្តទេ។ ក្នុងករណីនេះ អ្នកវាយតម្លៃអាចសុំជំនួយពីអាជ្ញាសាលា ក្រោយពីបានទទួលការអនុញ្ញាតពីតុលាការអនុវត្ត (ក្រមនីតិ/ណី មាត្រា ៤៣០ កថា.២, មាត្រា ៣៣៨ កថា.២) ហើយអាជ្ញាសាលានឹងធ្វើការបើកសោរ (ក្រមនីតិ/ណី មាត្រា ៤៣០ កថា.៤)។ ក្នុងករណីដូចខាងលើនេះ ប្រសិនបើអ្នកចម្បងនៃទីកន្លែងរស់នៅមិននៅ ហើយបើអ្នកវាយតម្លៃចូលទៅក្នុងទីកន្លែងរស់នៅនោះ ត្រូវឲ្យមានវត្តមានមន្ត្រីឃុំ សង្កាត់ មន្ត្រីនគរបាល ឬ អ្នកដទៃទៀត ដែលអាចទទួលស្គាល់ថាជាសាក្សីសមរម្យ (ក្រមនីតិ/ណី មាត្រា ៣៣៩)។

**<u>សំណួរទី ២៥៖ តើអ្នកវាយតម្លៃត្រូវធ្វើការគណនានូវចំនួនទឹកប្រាក់នៃការវាយតម្លៃដោយរបៀបណា?</u>**

អ្នកវាយតម្លៃ ត្រូវធ្វើការគណនាដោយយោងទៅតាមទីកន្លែងនៃអចលនវត្ថុ ទំហំ វាយតម្លៃលើចំនួនទឹកប្រាក់លើពន្ធ ប៉ុន្តែ មិនត្រូវធ្វើការគណនាចំពោះតែផ្នែកដែលទទួលបានពីរបាយការណ៍ប៉ុណ្ណោះនោះទេ។ ជាក់ស្តែង អ្នកវាយតម្លៃត្រូវធ្វើការពិចារណាទៅលើកាលៈទេសៈពិសេសនៃអចលនវត្ថុនោះ ដោយមើលទៅលើអចលនវត្ថុនោះថាតើអ្នកណាដែលកំពុងប្រើប្រាស់អចលនវត្ថុនោះ ប្រើប្រាស់យ៉ាងដូចម្តេច ហើយស្ថានភាពបច្ចុប្បន្នយ៉ាងដូចម្តេចដែរ។ ជាពិសេស ប្រសិនបើអចលនវត្ថុនោះមានអ្នកកាន់កាប់ តើការកាន់កាប់នោះផ្អែកតាមសិទ្ធិអ្វី? ម្យ៉ាងទៀត អ្នកវាយតម្លៃត្រូវធ្វើការពិចារណាថា បើផ្អែកតាមការលក់ដោយបង្ខំ តើសិទ្ធិកាន់កាប់នោះរលត់ ឬ មិនរលត់ ជាអាទិ៍

និង ត្រូវពិចារណាទៅលើទំនាក់ទំនងគតិយុត្តផងដែរ។ ប្រសិនបើ ការធ្វើការវិនិច្ឆ័យលើទំនាក់ទំនងគតិយុត្តមានការលំបាក អ្នកវាយតម្លៃអាចសុំជំនួយពីអាជ្ញាសាលាបាន។

របៀបវាយតម្លៃអំពីចំនួនទឹកប្រាក់ គឺពឹងផ្អែកទៅលើអ្នកវាយតម្លៃដែលមានជំនាញ។ យ៉ាងណាមិញ **<u>វានឹងមានភាពសមរម្យ ប្រសិនបើអ្នកវាយតម្លៃធ្វើការវាយតម្លៃចំនួនទឹកប្រាក់ទាបជាងតម្លៃទីផ្សារ</u>**។ ប្រសិនបើការលក់ដោយបង្ខំមានលក្ខណៈខុសគ្នាទៅនឹងការលក់ធម្មតា នោះវានឹងមានភាពលំបាកសម្រាប់អ្នកទិញ។ ឧទាហរណ៍៖ អ្នកដែលមានគោលបំណងទិញ មិនអាចចូលមើលអចលនវត្ថុហ៊ីប៉ូតែកនៅខាងក្នុងបានទេ ហើយគាត់ត្រូវធ្វើការសម្រេចចិត្តភ្លាមៗ ថាទិញ ឬ មិនទិញ ត្រឹមកាលបរិច្ឆេទកំណត់លក់ ម្យ៉ាងទៀត វាអាចនឹងមានបញ្ហានៅក្រោយពេលទិញ ដោយសារតែ អ្នកកាន់កាប់ប្រកែកក្នុងការប្រគល់អចលនវត្ថុហ៊ីប៉ូតែកនោះ។ ប្រសិនបើ គេធ្វើការពិចារណាទៅលើចំណុចទាំងនេះ ទោះបីជាតម្លៃនៃការលក់ដោយបង្ខំដូចគ្នាទៅនឹងតម្លៃទីផ្សារក៏ដោយ ក៏មិនមានអ្នកដែលចង់ទិញដែរ ហេតុនេះ វាមានការព្រួយបារម្ភអំពីការយឺតយ៉ាវនៃនីតិវិធីលក់ដោយបង្ខំ។

**ដំណាក់កាលទី ១៥. ឯកសារលំអិតអំពីវត្ថុ៖** តុលាការអនុវត្តត្រូវចាប់ផ្តើមធ្វើឯកសារលំអិតអំពីវត្ថុ (ក្រមនីតិ/ណី មាត្រា ៤៣៤ កថា.១)។ (Slide 50)

**<u>សំណួរទី២៦៖ ប្រសិនបើខ្វះខាតរបាយការណ៍ក្នុងការធ្វើឯកសារលំអិតអំពីវត្ថុ តើតុលាការអនុវត្តត្រូវធ្វើដូចម្តេច?</u>**

តុលាការអនុវត្តត្រូវធ្វើឯកសារលំអិតអំពីវត្ថុ ដោយយោងតាមឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃចុះបញ្ជីអចលនវត្ថុ និង របាយការណ៍វាយតម្លៃ ជាអាទិ៍។ បើតុលាការអនុវត្តយល់ឃើញថា មានភាពចាំបាច់ក្នុងការប្រមូលរបាយការណ៍បន្ថែម តុលាការអនុវត្តអាចបង្គាប់ឲ្យអាជ្ញាសាលាធ្វើការស្រាវជ្រាវអំពីសណ្ឋាននៃអចលនវត្ថុ ស្ថានភាពនៃការកាន់កាប់ ស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ រចនាសម្ព័ន្ធនៃអាគារ ជាអាទិ៍ ហើយអាជ្ញាសាលាត្រូវរាយការណ៍អំពីលទ្ធផលនៃការស្រាវជ្រាវនោះជាលាយលក្ខណ៍អក្សរ (ឯកសារស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ន, ក្រមនីតិ/ណី មាត្រា ៤៣៤កថា.២)។ ម្យ៉ាងទៀត តុលាការអនុវត្តអាចធ្វើការប្រមូលរបាយការណ៍ដោយធ្វើការសួរភាគី និង ជនដែលពាក់ព័ន្ធ(ក្រមនីតិ/ណី មាត្រា ៣៣៥, មាត្រា ១១៤ កថា.២, មាត្រា ៣៣៧ កថា.២) ហើយអាចស្នើសុំពីក្រសួងមានសមត្ថកិច្ចឲ្យដាក់ជូននូវរបាយការណ៍បាន (ក្រមនីតិ/ណី មាត្រា ៣៤២)។

**ដំណាក់កាលទី ១៦. ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា៖** នៅពេលដែលបានទទួលរបាយការណ៍វាយតម្លៃពីអ្នកវាយតម្លៃ តុលាការអនុវត្តត្រូវកំណត់តម្លៃលក់អប្បបរមាដោយផ្អែកលើរបាយការណ៍វាយតម្លៃ (ក្រមនីតិ/ណីមាត្រា ៤៣២កថា.១)។(Slide 51)

***<u>សំណួរទី ២៧៖ តើតម្លៃលក់អប្បបរមាត្រូវកំណត់យ៉ាងដូចម្តេច?</u>***

តុលាការអនុវត្ត ត្រូវកំណត់តម្លៃលក់អប្បបរមា ដោយផ្អែកលើការវាយតម្លៃរបស់អ្នកវាយតម្លៃ (ក្រមនីតិ/ណីមាត្រា ៤៣២ កថា.១)។ ជាគោលការណ៍ តុលាការអនុវត្តកំណត់តម្លៃលក់ជាអប្បបរមាតាមចំនួនទឹកប្រាក់ដែលបានវាយតម្លៃដោយអ្នកវាយតម្លៃ។ ប៉ុន្តែ បន្ទាប់ពីតុលាការអនុវត្តបានធ្វើការបញ្ជាក់នូវឯកសារផ្សេងទៀត (ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចនវត្ថុ ឯកសារស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ន ឯកសារលំអិតអំពីវត្ថុសេចក្តីរាយការណ៍អំពីសិទ្ធិលើបំណុល (ក្រមនីតិ/ណី មាត្រា ៤២៣) ជាអាទិ៍) ហើយជាលទ្ធផល តុលាការអនុវត្តនឹងអាចរកឃើញថារបាយការណ៍វាយតម្លៃខុសពីស្ថានភាពជាក់ស្តែង និង ការគណនានៅលើរបាយការណ៍មានកំហុស។ ក្នុងករណីបែបនេះ វាមានភាពសមស្របដែលតុលាការអនុវត្តធ្វើការបង្គាប់ឲ្យអ្នកវាយតម្លៃធ្វើការវាយតម្លៃម្តងទៀត។ យ៉ាងណាមិញ បើកំហុសនោះមានភាពងាយស្រួលក្នុងការកែតម្រូវ តុលាការអនុវត្តមិនបាច់បង្គាប់ឲ្យធ្វើការវាយតម្លៃម្តងទៀតទេ គឺតុលាការអនុវត្តអាចកំណត់តម្លៃលក់អប្បបរមាដែលខុសពីចំនួនទឹកប្រាក់វាយតម្លៃបាន។

**ដំណាក់កាលទី ១៧. ការបង្គាប់ឲ្យអនុវត្តការលក់៖** តុលាការអនុវត្តត្រូវកំណត់កាលបរិច្ឆេទ និង ទីកន្លែងលក់ ហើយត្រូវបង្គាប់ឲ្យអាជ្ញាសាលាអនុវត្តការលក់នោះ (ក្រមនីតិ/ណី មាត្រា ៤៣៦ កថា.៣)។

**ដំណាក់កាលទី ១៨. ការប្រកាសជាសាធារណៈនូវកាលបរិច្ឆេទនៃការលក់ជាអាទិ៍ និង ការទុកឯកសារលំអិតអំពីវត្ថុជាអាទិ៍៖** ក្រឡាបញ្ជីត្រូវផ្សាយជាសាធារណៈនូវសញ្ញាណនៃអចលនវត្ថុដែលត្រូវលក់ តម្លៃលក់អប្បបរមា ព្រមទាំងកាលបរិច្ឆេទ និង ទីកន្លែងលក់ (ក្រមនីតិ/ណី មាត្រា ៤៣៦ កថា. ៤) ។ ម្យ៉ាងទៀត តុលាការអនុវត្តត្រូវទុកឯកសារចម្លងនៃឯកសារលំអិតអំពីវត្ថុនៅតុលាការអនុវត្តជាមួយនឹងឯកសារចម្លងនៃរបាយការណ៍វាយតម្លៃ (ក្រមនីតិ/ណី មាត្រា ៤៣៤ កថា.១)។(Slide 52)

***<u>សំណួរទី ២៨៖ តើតុលាការអនុវត្តត្រូវធ្វើដូចម្តេច ប្រសិនបើការសរសេរនៅក្នុងឯកសារលំអិតអំពីវត្ថុមានកំហុស ហើយតម្លៃលក់អប្បបរមាទាបពេក?</u>***

ប្រសិនបើបានដឹងថាខ្លួនមានកំហុស តុលាការអនុវត្តអាចសរសេរកែតម្រូវឯកសារលំអិតអំពីវត្ថុ ហើយអាចផ្លាស់ប្តូរតម្លៃលក់អប្បបរមាដោយឆន្ទានុសិទ្ធិបាន (ក្រមនីតិ/ណី មាត្រា ៤៣២ កថា.២)។ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្តបានដឹងថា មានកំហុស នោះពួកគាត់អាចតវ៉ាទៅតុលាការអនុវត្ត ដោយទាមទារឲ្យផ្លាស់ប្តូរតម្លៃលក់អប្បបរមា និង កែតម្រូវនៅក្នុងឯកសារលំអិតអំពីវត្ថុបាន (ក្រមនីតិ/ណី មាត្រា ៣៨៤ កថា.១) ។ តុលាការអនុវត្តត្រូវធ្វើការបញ្ជាក់ម្តងទៀត នូវរបាយការណ៍វាយតម្លៃ ហើយធ្វើការពិនិត្យអចលនវត្ថុហ៊ីប៉ូតែកម្តងទៀត និង ធ្វើការពិនិត្យភស្តុតាងដែលភាគីបានដាក់ឲ្យ ព្រមទាំងធ្វើការបញ្ជាក់អំពីការតវ៉ានោះ ថាមាន ឬ គ្មានហេតុផល។ លើសពីនេះ បើការតវ៉ាមានហេតុផល នោះតុលាការអនុវត្តត្រូវសរសេរកែតម្រូវនៅលើឯកសារលំអិតអំពីវត្ថុ ព្រមទាំងផ្លាស់ប្តូរតម្លៃលក់អប្បបរមាដោយដីកាសម្រេច។

**ដំណាក់កាលទី ១៩. ការអនុវត្តការលក់៖** អាជ្ញាសាលាត្រូវធ្វើការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ នៅកាលបរិច្ឆេទនៃការលក់។ ជនដែលមានបំណងទិញ ត្រូវដាក់ប្រាក់ធានាដូចដែលបានកំណត់ ហើយធ្វើសំណើទិញ (ក្រមនីតិ/ណី មាត្រា ៤៣៧ កថា.១)។ បន្ទាប់ពីអាជ្ញាសាលាបានកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ហើយបានប្រកាសនូវនាម ឬ នាមករណ៍ និង ថ្លៃលក់ឡាយឡុងនោះរួចហើយ អាជ្ញាសាលាត្រូវប្រកាសការបញ្ចប់កាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ (ក្រមនីតិ/ណី មាត្រា ៤៣៩ កថា.១)។ លើសពីនេះទៀត អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ហើយត្រូវដាក់ទៅតុលាការអនុវត្តភ្លាម (ក្រមនីតិ/ណី មាត្រា ៤៣៩ កថា.៤)។
(Slide 53)

*អាជ្ញាសាលា ជាអ្នកកំណត់ "អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា" ប៉ុន្តែអ្នកស្នើសុំទិញនេះ មិនទាន់ក្លាយជា អ្នកទិញទេ។ បន្ទាប់មក តុលាការអនុវត្ត ត្រូវពិនិត្យនីតិវិធីនៃការលក់ដោយបង្ខំទាំងស្រុងឡើងវិញ ហើយបើបានពិនិត្យឃើញថាគ្មានបញ្ហាទេ តុលាការអនុវត្តនឹងចេញដីកាសម្រេចអនុញ្ញាតឲ្យលក់។ នៅពេលនោះទើប "អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា" ក្លាយជា "អ្នកទិញ"។

**<u>សំណួរទី ២៩៖ តើម្ចាស់បំណុលនៃការអនុវត្តអាចធ្វើសំណើទិញបានដែរ ឬ ទេ?</u>**

ក្រមនីតិវិធីរដ្ឋប្បវេណីមិនបានហាមឃាត់ម្ចាស់បំណុលនៃការអនុវត្តក្នុងការធ្វើសំណើទិញទេ។ ហេតុនេះ ប្រសិនបើ ពុំមានការហាមឃាត់នៅក្នុងបញ្ញត្តិផ្សេងទៀតទេ នោះម្ចាស់បំណុលនៃការអនុវត្តអាចធ្វើសំណើទិញបាន។ ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តបានធ្វើសកម្មភាពមិនសមរម្យ ដោយរំខានក្នុងការដាក់ពាក្យស្នើសុំ

ទិញរបស់ជនដែលមានបំណងទិញ ជាអាទិ៍ នោះអាជ្ញាសាលាអាចចាត់វិធានការណ៍កម្រិតមិនឲ្យម្ចាស់បំណុលនៃការអនុវត្តចូលកន្លែងលក់ ដេញចេញពីកន្លែងលក់ ឬ អាចមិនឲ្យស្នើសុំទិញបាន (ក្រមនីតិ/ណី មាត្រា ៤៣៦ កថា.៥, មាត្រា ៣៩៦)។

**<u>សំណួរទី ៣០៖ តើកូនបំណុលនៃការអនុវត្តអាចធ្វើសំណើទិញបានដែរ ឬទេ? (Slide 54)</u>**

កូនបំណុលនៃការអនុវត្តពុំអាចធ្វើសំណើទិញបានទេ (ក្រមនីតិ/ណី មាត្រា ៤៣៨)។ ប្រសិនបើ កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា មានប្រាក់ដើម្បីស្នើសុំទិញ នោះកូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ត្រូវយកប្រាក់នោះទៅសងម្ចាស់បំណុលនៃការអនុវត្តដោយផ្ទាល់។

យ៉ាងណាមិញ ចំពោះនីតិវិធីអនុវត្តហ៊ីប៉ូតែក ក៏អាចមានករណីដែលកូនបំណុលនៃការអនុវត្តមិនមែនជាកូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដែរ (ជននោះហៅថា"អ្នកធានាដោយវត្ថុ")។ ដោយសារតែអ្នកធានាដោយវត្ថុមិនមានកាតព្វកិច្ចសងសិទ្ធិលើបំណុលដែលត្រូវបានធានាចំពោះម្ចាស់បំណុលនៃការអនុវត្ត ដូច្នេះ អ្នកធានាដោយវត្ថុមានជំហរខុសពីកូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា។ ហេតុនេះ ក្នុងករណីដែលកូនបំណុលនៃការអនុវត្តជាអ្នកធានាដោយវត្ថុ នោះគេអាចធ្វើការបកស្រាយបានថា អ្នកធានាដោយវត្ថុអាចស្នើសុំទិញបាន (ប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ប្រការ ១២ វាក្យខណ្ឌទី ២)។

**<u>សំណួរទី ៣១៖ ក្នុងករណីដែលគ្មានជនដែលមានគោលបំណងទិញសូម្បីតែម្នាក់ តើតុលាការអនុវត្តត្រូវធ្វើដូចម្ដេច? (Slide 55 ~ 57)</u>**

តុលាការអនុវត្តត្រូវកំណត់កាលបរិច្ឆេទលក់សារជាថ្មី ហើយឲ្យអាជ្ញាសាលាអនុវត្តការលក់ម្ដងទៀត។ ប្រសិនបើ មូលហេតុដែលគ្មានអ្នកទិញ ដោយសារតែតម្លៃលក់អប្បបរមាខ្ពស់ពេក នោះតុលាការអនុវត្តអាចបញ្ចុះតម្លៃលក់អប្បបរមាបាន (ក្រមនីតិ/ណី មាត្រា ៤៣២ កថា.២)។ ប៉ុន្តែ ប្រសិនបើធ្វើការបញ្ចុះតម្លៃលក់អប្បបរមាដោយមិនបានពិចារណា នោះវាអាចនឹងជះឥទ្ធិពលមិនល្អ។ ប្រសិនបើគ្មានអ្នកទិញ ហើយតុលាការអនុវត្តធ្វើការបញ្ចុះតម្លៃលក់អប្បបរមាឲ្យកាន់តែថោកទៅៗ នោះគេមានការព្រួយបារម្ភថា អ្នកមានគោលបំណងទិញនឹងកម្រធ្វើការស្នើសុំទិញ ដោយរង់ចាំឲ្យតម្លៃលក់អប្បបរមានោះចុះថោកសិន។ ប្រសិនបើធ្វើបែបនេះ នីតិវិធីនៃការលក់នឹងមានភាពយឺតយ៉ាវ ដូចនេះ តុលាការអនុវត្តមិនចាំបាច់ផ្លាស់ប្ដូរតម្លៃលក់អប្បបរមាទេ គឺគ្រាន់តែបង្គាប់ឲ្យអាជ្ញាសាលាធ្វើការលក់ម្ដងទៀត ដោយធ្វើការពិចារណាការអនុវត្តវិធីផ្សេងក្រៅពីវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ (ក្រមនីតិ/ណី មាត្រា ៤៣៦ កថា.២)។ ខ្លឹមសារលំអិតនៃក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៤៣៦ កថា.២ ដែលបានកំណត់ថា "វិធីលក់ផ្សេងទៀតក្រៅពីវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់"

គឺអាស្រ័យទៅលើការអនុវត្តជាក់ស្តែងដែលមានលក្ខណៈសមរម្យ ដោយពុំមានកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីទេ។ ឧទាហរណ៍ ក្នុងករណីដែលទីកន្លែងនៃអចលនវត្ថុនោះមានលក្ខណៈលំបាកក្នុងការធ្វើដំណើរទៅ នោះទោះបីជាគ្មានអ្នកទិញអចលនវត្ថុនោះដោយស្រោមសំបុត្រក៏ដោយ ក៏ប្រហែលជាមានអ្នកជិតខាងណាម្នាក់ដែលមានឆន្ទៈចង់ទិញផងដែរ។ ម្យ៉ាងទៀត ក្នុងករណីដែលមានអ្នកកាន់កាប់អចលនវត្ថុនោះ ទោះបីជាគ្មានអ្នកទិញដោយស្រោមសំបុត្រក៏ដោយ ក៏ប្រហែលជាអ្នកកាន់កាប់អចលនវត្ថុនោះផ្ទាល់ មានឆន្ទៈចង់ទិញដែរ។ តុលាការអនុវត្តអាចទៅចរចារដោយផ្ទាល់ជាមួយអ្នកទាំងនោះ ហើយអាចឲ្យអ្នកទាំងនោះទិញបាន។

យ៉ាងណាមិញ ក្នុងករណីដែលយល់ឃើញថា លទ្ធផលនៃការបញ្ចុះតម្លៃលក់អប្បបរមានៃអចលនវត្ថុក្រោយពីបានសងសោហ៊ុយសម្រាប់នីតិវិធីហើយ គ្មានលទ្ធភាពសល់ទេនោះ (ក្រមនីតិ/ណី មាត្រា ៣៧១ កថា.១) តុលាការអនុវត្ត ត្រូវជូនដំណឹងអំពីការណ៍នោះទៅឲ្យម្ចាស់បំណុលនៃការអនុវត្ត (ក្រមនីតិ/ណី មាត្រា ៤៣៥ កថា.១)។ ប្រសិនបើ ម្ចាស់បំណុលនៃការអនុវត្តស្នើទៅតុលាការអនុវត្តថា ខ្លួននឹងទិញក្នុងតម្លៃស្នើសុំ ដែលសំណើនោះត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍គិតចាប់ពីថ្ងៃដែលម្ចាស់បំណុលនៃការអនុវត្តទទួលបានដំណឹង ហើយតម្លៃស្នើសុំនោះត្រូវលើសពីតម្លៃប៉ាន់ប្រមាណនៃសោហ៊ុយសម្រាប់នីតិវិធី ហើយម្ចាស់បំណុលនៃការអនុវត្តបានដាក់ប្រាក់ធានាស្មើនឹងតម្លៃស្នើសុំ នោះតុលាការអនុវត្តអាចបន្តនីតិវិធីបាន។ ប៉ុន្តែ តុលាការអនុវត្តត្រូវលុបចោលនីតិវិធីលក់ដោយបង្ខំ ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តមិនបានធ្វើតាមវិធានការណ៍ដូចបានរៀបរាប់ខាងលើនេះ (ក្រមនីតិ/ណី មាត្រា ៤៣៥ កថា.២)។

**ដំណាក់កាលទី ២០. ការកំណត់កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់៖** នៅពេលដែលបានកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា និង កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ តុលាការអនុវត្ត ត្រូវជូនដំណឹងអំពីកាលបរិច្ឆេទនោះ ទៅជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ (ក្រមនីតិ/ណី មាត្រា ៤៤០ កថា. ២)។ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍មានដូចជា ម្ចាស់បំណុលនៃការអនុវត្ត កូនបំណុលនៃការអនុវត្ត ជនដែលស្នើសុំទិញក្នុងតម្លៃអតិបរមា ជនដែលអាចទទួលចំណែកពីប្រាក់ដែលបានមកពីការលក់ (ក្រមនីតិ/ណី មាត្រា ៥១៩) ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគី និង ម្ចាស់បំណុលហ៊ីប៉ូតែក ដែលត្រូវបានចុះក្នុងឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅបញ្ជីអចលនវត្ថុ ជាដើម។ (Slide 58)

**ដំណាក់កាលទី ២១. ដីកាសម្រេចអនុញ្ញាតឲ្យលក់ ឬ ដីកាសម្រេចមិនអនុញ្ញាតឲ្យលក់៖** តុលាការអនុវត្ត ត្រូវបើកកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ ហើយត្រូវប្រកាសអំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឲ្យលក់ (ក្រមនីតិ/ណី មាត្រា ៤៤០ កថា. ១)។ ប៉ុន្តែ ក្នុងករណីលក់ហួសកម្រិត តុលាការអនុវត្តត្រូវបម្រុងទុកនូវដីកាសម្រេចអនុញ្ញាតឲ្យលក់អចលនវត្ថុមួយផ្នែក (ក្រមនីតិ/ណី មាត្រា ៤៤៣ កថា. ១)។ម្យ៉ាងទៀត ក្រឡាបញ្ជីត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់នូវដីកាសម្រេចដែលបានប្រកាសនោះ ដាក់ក្នុងសំណុំរឿង (ក្រមនីតិ/ណី មាត្រា ៣៣៥, មាត្រា ២១៣ កថា. ៣)។(Slide 59)

**សំណួរទី ៣២៖ តើកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ ត្រូវធ្វើឡើងដោយនីតិវិធីបែបណា?**

តុលាការអនុវត្តនឹងចេញដីកាសម្រេចមិនអនុញ្ញាតឲ្យលក់ ដោយធ្វើការវិនិច្ឆ័យថា មាន ឬ គ្មាន ហេតុនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៤៤២ កថាខណ្ឌទី ២ ទោះជាក្នុងចំណោមហេតុទាំងនេះ មានហេតុតែមួយត្រូវបានទទួលស្គាល់ក៏ដោយ។ ផ្ទុយទៅវិញ ប្រសិនបើ ក្នុងចំណោមហេតុទាំងនេះ គ្មានហេតុណាមួយត្រូវបានទទួលស្គាល់ទេ នោះតុលាការអនុវត្តនឹងចេញដីកាសម្រេចអនុញ្ញាតឲ្យលក់។ ក្នុងករណីណាមួយក៏ដោយ នៅពេលចេញដីកាសម្រេចនោះ ចៅក្រមត្រូវចុះហត្ថលេខាលើដីកាសម្រេចនោះ (ក្រមនីតិ/ណី មាត្រា ៣៣៥, មាត្រា ២១៣ កថា. ២)។

តុលាការអនុវត្ត ធ្វើការទាញហេតុផលផ្ទាល់មាត់ក៏បាន ឬ មិនធ្វើការទាញហេតុផលផ្ទាល់មាត់ក៏បាន (ក្រមនីតិ/ណី មាត្រា ៣៣៥, មាត្រា ១១៤ កថា.១ វាក្យខណ្ឌទី ២)។ ប្រសិនបើ ធ្វើការទាញហេតុផលផ្ទាល់មាត់ នោះជាគោលការណ៍ តុលាការអនុវត្តត្រូវធ្វើឡើងនៅសាលសវនាការជាសាធារណៈ (ក្រមនីតិ/ណី មាត្រា ៣៣៥, មាត្រា ១១៥ កថា. ២)។

ក្នុងករណីដែលមិនធ្វើការទាញហេតុផលផ្ទាល់មាត់ តុលាការអនុវត្តមិនចាំបាច់ធ្វើឡើងនៅសាលសវនាការជាសាធារណៈទេ។ ប៉ុន្តែ តុលាការអនុវត្តមិនអាចគ្រាន់តែធ្វើការពិនិត្យឯកសារប៉ុណ្ណោះទេ គឺចាំបាច់ត្រូវបើកកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់។ ការបើកកាលបរិច្ឆេទនេះ មិនចាំបាច់ធ្វើជាសាធារណៈទេ ប៉ុន្តែត្រូវផ្តល់ឱកាសឲ្យជនដែលពាក់ព័ន្ធផលប្រយោជន៍ថ្លែងយោបល់ (ក្រមនីតិ/ណី មាត្រា ៤៤០ កថា. ២, មាត្រា ៤៤១)។ ក្នុងករណីដែលមិនធ្វើការទាញហេតុផលផ្ទាល់មាត់ តុលាការអនុវត្តអាចធ្វើការប្រមូលភស្តុតាងបាន ដោយសាកសួរភាគីនិង ជនដែលពាក់ព័ន្ធ (ក្រមនីតិ/ណី មាត្រា ៣៣៥, មាត្រា១១៤ កថា. ២, មាត្រា ៣៣៧ កថា. ២) ព្រមទាំងស្នើសុំព័ត៌មានពីស្ថាប័នមានសមត្ថកិច្ច (ក្រមនីតិ/ណី មាត្រា ៣៤២)។

**សំណួរទី ៣៣៖ តើការលក់ហួសកម្រិតជាអ្វី? (Slide 60, 61)**

ក្នុងករណីដែលបានលក់អចលនវត្ថុច្រើន បើតម្លៃស្នើសុំទិញនៃអចលនវត្ថុណាមួយ ឬ ច្រើនក្នុងចំណោមអចលនវត្ថុទាំងអស់នោះត្រូវបានប៉ាន់ប្រមាណឃើញថា អាចសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និងសោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បាន តុលាការអនុវត្តត្រូវបម្រុងទុកនូវដីកាសម្រេចអនុញ្ញាតឲ្យលក់អចលនវត្ថុផ្សេងទៀត (ក្រមនីតិ/ណី មាត្រា ៣៣៥, មាត្រា ៤៤៣ កថា. ២)។

ឧទាហរណ៍៖ ដើម្បីធានាសិទ្ធិលើបំណុល ២០០០ ដុល្លារ កូនបំណុល Y និង ម្ចាស់បំណុល X បានបង្កើតហ៊ីប៉ូតែកលើអចលនវត្ថុ A (២០០០ ដុល្លារ) អចលនវត្ថុ B (៤០០០ ដុល្លារ) និង អចលនវត្ថុ C (៦០០០ ដុល្លារ) ដែលជាកម្មសិទ្ធរបស់ Y។ ម្ចាស់បំណុល X បានដាក់ពាក្យសុំឲ្យអនុវត្តហ៊ីប៉ូតែកក្នុងពេលតែមួយលើអចលនវត្ថុទាំងនោះ ។ តុលាការអនុវត្តបានរឹបអូសអចលនវត្ថុទាំង ៣ ។ នៅពេលនីតិវិធីដំណើរការដល់ការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក ប្រសិនបើ ម្ចាស់បំណុលផ្សេងទៀតរាយការណ៍អំពីសិទ្ធិលើបំណុល (ក្រមនីតិ/ណី មាត្រា ៤២៣) និង ទាមទារឲ្យចែកចំណែក (ក្រមនីតិ/ណី មាត្រា ៤២៦) នៅពេលនោះចំនួនទឹកប្រាក់ដែលត្រូវបានប៉ាន់ប្រមាណថាត្រូវចែកចំណែកទៅឲ្យម្ចាស់បំណុល នឹងត្រូវបានបង្ហាញឲ្យឃើញច្បាស់លាស់។ ឧបមាថាចំនួនទឹកប្រាក់សរុបដែលត្រូវចែកចំណែកឲ្យទៅម្ចាស់បំណុលនីមួយៗ មានចំនួន ៤០០០ ដុល្លារ ហើយសោហ៊ុយសម្រាប់ការអនុវត្តគឺ ៥០០ ដុល្លារ។ ក្នុងករណីនេះ តុលាការអនុវត្តមិនត្រូវចេញដីកាសម្រេចអនុញ្ញាតឲ្យលក់អចលនវត្ថុទាំងអស់ទេ។ តុលាការអនុវត្ត ត្រូវសួរយោបល់របស់កូនបំណុលនៃការអនុវត្តជាមុន (ក្រមនីតិ/ណី មាត្រា ៤៤៣ កថា. ២) ហើយត្រូវជ្រើសរើសថា តើត្រូវចេញដីកាសម្រេចអនុញ្ញាតឲ្យលក់តែចំពោះអចលនវត្ថុ A និង អចលនវត្ថុ B ឬ ចេញដីកាសម្រេចអនុញ្ញាតឲ្យលក់តែចំពោះអចលនវត្ថុ C ។ ក្នុងករណីដែលតុលាការអនុវត្តចេញដីកាសម្រេចអនុញ្ញាតឲ្យលក់តែចំពោះអចលនវត្ថុ A និង អចលនវត្ថុ B នោះតុលាការអនុវត្ត ត្រូវបម្រុងទុកនូវដីកាសម្រេចអនុញ្ញាតឲ្យលក់អចលនវត្ថុ C (ក្រមនីតិ/ណី មាត្រា ៤៤៣ កថា. ១)។ ក្នុងករណីនេះ អ្នកទិញអចលនវត្ថុ C អាចលុបចោលសំណើទិញនោះបាន (ក្រមនីតិ/ណី មាត្រា ៤៤៣ កថា. ១)។ម្យ៉ាងទៀត បើថ្លៃលក់ត្រូវបានបង់ចំពោះអចលនវត្ថុ A និង អចលនវត្ថុ B ដែលមានដីកាសម្រេចអនុញ្ញាតឲ្យលក់ តុលាការអនុវត្តត្រូវលុបចោលនូវនីតិវិធីនៃការលក់ដោយបង្ខំដែលទាក់ទងនឹងអចលនវត្ថុ C (ក្រមនីតិ/ណី មាត្រា ៤៤៣ កថា. ៤)។

**ដំណាក់កាលទី ២២. ការកំណត់ពេលនៃការបង់ថ្លៃលក់៖** នៅពេលដីកាសម្រេចអនុញ្ញាតឲ្យលក់បានចូលជាស្ថាពរ តុលាការអនុវត្តត្រូវកំណត់ពេលនៃការបង់ថ្លៃលក់ឲ្យបានឆាប់រហ័ស និងជូនដំណឹងទៅអ្នកទិញ (ប៉ុន្តែ ក្នុងករណីដែលមានសំណើអំពីការបង់តែចំនួនប្រាក់ដែលនៅសល់ ក្រោយពីការដកចេញពីចំណែកដែលត្រូវទទួលបានពីការចែកចំណែករបស់អ្នកទិញ នោះតុលាការអនុវត្តមិនចាំបាច់ធ្វើការកំណត់ពេលនៃការបង់ថ្លៃលក់ទេ (ក្រមនីតិ/ណី មាត្រា ៤៤៣ កថា. ៣)។ ការកំណត់ពេលបង់ថ្លៃលក់ត្រូវស្ថិតក្នុងអំឡុងពេល១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលដីកាសម្រេចអនុញ្ញាតឲ្យលក់បានចូលជាស្ថាពរ (ក្រមនីតិ/ណី មាត្រា ៤៤៣ កថា. ១)។

**ដំណាក់កាលទី ២៣. ការបង់ថ្លៃលក់៖** អ្នកទិញ ត្រូវបង់ថ្លៃលក់ ដែលជាប្រាក់នៅសល់បន្ទាប់ពីដកប្រាក់ធានា ចេញពីចំនួនប្រាក់នៃសំណើទិញ (ក្រមនីតិ/ណី មាត្រា ៤៤៧ កថា.២) ទៅឲ្យតុលាការអនុវត្ត ឲ្យបានត្រឹមពេលដែលតុលាការអនុវត្តបានកំណត់ (ក្រមនីតិ/ណី មាត្រា ៤៤៧ កថា.១)។ ប៉ុន្តែ ក្នុងករណីដែលមានសំណើអំពីការបង់តែចំនួនប្រាក់ដែលនៅសល់ក្រោយពីការដកចេញពីចំណែកដែលត្រូវទទួលបានពីការចែកចំណែក (ការបង់តែចំនួនខ្វះ) គឺវាមាននីតិវិធីខុសគ្នា។ យ៉ាងណាមិញ តុលាការអនុវត្តចាំបាច់ត្រូវទទួលសោហ៊ុយចាំបាច់សម្រាប់ផ្ទុកផ្តាក់ឲ្យចុះបញ្ជី ឯកសារចម្លងនៃលិខិតឆ្លងដែន ឬ អត្តសញ្ញាណប័ណ្ណរបស់អ្នកទិញ ព្រោះវាចាំបាច់ត្រូវប្រើនៅក្នុងពេលផ្ទុកផ្តាក់ឲ្យចុះបញ្ជី។ (Slide 62, 63)

**<u>សំណួរទី ៣៤៖ តើការបង់តែចំនួនខ្វះជាអ្វី? (Slide 64, 66)</u>**

ប្រសិនបើ អ្នកទិញ គឺជាម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែកពីប្រាក់ថ្លៃលក់ អ្នកទិញនោះអាចស្នើសុំបង់តែចំនួនខ្វះ ទៅឲ្យតុលាការអនុវត្ត ឲ្យបានត្រឹមពេលបញ្ចប់កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ (ក្រមនីតិ/ណី មាត្រា ៤៤៧ កថា. ៣)។ ពោលក្នុងករណីដែល ម្ចាស់បំណុលនៃការអនុវត្ត និង ម្ចាស់បំណុលដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥១៩ បានក្លាយជាអ្នកទិញ ពួកគាត់អាចស្នើសុំបង់តែចំនួនខ្វះបាន។

ក្នុងករណី មានការស្នើសុំបង់តែចំនួនខ្វះ តុលាការអនុវត្តត្រូវកំណត់កាលបរិច្ឆេទនៃការចែកចំណែកភ្លាមបន្ទាប់ពីដីកាសម្រេចអនុញ្ញាតឲ្យលក់បានចូលជាស្ថាពរ ដោយមិនចាំបាច់កំណត់ពេលនៃការបង់ថ្លៃលក់ទេ (ក្រមនីតិ/ណី មាត្រា ៤៨៨ កថា. ១ ចំណុច គ)។ បន្ទាប់មក អ្នកទិញ ត្រូវបង់ថ្លៃលក់ដែលជាប្រាក់នៅសល់បន្ទាប់ពីដកប្រាក់ធានា ចេញពីចំនួនប្រាក់នៃសំណើទិញ នៅកាលបរិច្ឆេទនៃការចែកចំណែក។ ឧទាហរណ៍ ម្ចាស់បំណុលត្រូវទទួលបានពីការចែកចំណែកនូវប្រាក់ ៣០០០ ដុល្លារ ប៉ុន្តែ គាត់បានបង់ប្រាក់ធានាចំនួន ១០០០ ដុល្លារ សម្រាប់

ការលក់ឡាយឡុងក្នុងតម្លៃ ១០០០០ ដុល្លារ ហើយគាត់បានទទួលអចលនវត្ថុហ៊ីប៉ូតែក។ ក្នុងករណីនេះ ម្ចាស់បំណុល ត្រូវបង់ប្រាក់ឲ្យតុលាការអនុវត្តចំនួន ៩០០០ ដុល្លារ ប៉ុន្តែ វានឹងក្លាយជាការចំណាយប្រាក់ដោយឥតប្រយោជន៍ ព្រោះគាត់អាចនឹងទទួលបានការចែកចំណែកពីតុលាការអនុវត្តចំនួន ៣០០០ ដុល្លារ។ ប្រសិនបើ ម្ចាស់បំណុលនេះ ធ្វើការស្នើសុំបង់តែចំនួនខ្វះ នោះគាត់នឹងត្រូវបង់ប្រាក់ឲ្យតុលាការអនុវត្តចំនួន ៦០០០ ដុល្លារ ប៉ុណ្ណោះ ហេតុនេះ វាអាចកាត់បន្ថយការចំណាយប្រាក់ដោយឥតប្រយោជន៍បាន។

**<u>សំណួរទី ៣៥៖ នៅក្នុងករណីដែលអ្នកទិញមិនបានបង់ប្រាក់ថ្លៃលក់ឲ្យបានទាន់ពេលកំណត់នៃការបង់ថ្លៃលក់ តើតុលាការអនុវត្តត្រូវធ្វើយ៉ាងណា? (Slide 67)</u>**

បើអ្នកទិញមិនបង់ប្រាក់ថ្លៃលក់ទេ ដីកាសម្រេចអនុញ្ញាតឲ្យលក់នោះនឹងបាត់បង់អានុភាព។ ក្នុងករណីនេះ អ្នកទិញមិនអាចទាមទារឲ្យសងទឹកប្រាក់ដែលខ្លួនបានដាក់ជាការធានាលើសំណើទិញបានទេ (ក្រមនីតិ/ណី មាត្រា ៤៥១ កថា. ១)។ តុលាការអនុវត្ត ត្រូវធ្វើនីតិវិធីសាជាថ្មី ដោយចាប់ផ្តើមពីការចេញដីកាសម្រេចកំណត់កាលបរិច្ឆេទនៃការលក់ជាដើម និង ធ្វើការលក់ដោយបង្ខំសាជាថ្មី (ក្រមនីតិ/ណី មាត្រា ៤៥១ កថា.២)។ អ្នកទិញដែលមិនបានបង់ថ្លៃលក់មិនអាចធ្វើសំណើទិញនៅក្នុងការលក់ជាបង្ខំលើកទី ២ បានទេ (ក្រមនីតិ/ណី មាត្រា ៤៥១ កថា. ២)។

**ដំណាក់កាលទី ២៤. ការផ្ទុកផ្តាក់ឲ្យចុះបញ្ជី៖** ប្រសិនបើ អ្នកទិញបានបង់ថ្លៃលក់ហើយ ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឲ្យរដ្ឋបាលសុរិយោដីចុះបញ្ជី (ក្រមនីតិ/ណី មាត្រា ៤៤៨)។

**<u>សំណួរទី ៣៦៖ តើត្រូវធ្វើលិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជីដោយរបៀបណា? (Slide 68 ~ 77)</u>**

របៀបសរសេរលិខិតផ្ទុកផ្តាក់ មានចែងនៅក្នុងប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ប្រការ ៥ និង ប្រការ ១២។ យោងឯកសារឧបសម្ព័ន្ធទី ៦ ។ វាមានភាពចាំបាច់ក្នុងការប្រើប្រាស់ពាក្យពេចន៍ឲ្យស្របទៅនឹងការអនុវត្តជាក់ស្តែង។

ករណីសិក្សា

| | |
|---|---|
| X= ម្ចាស់បំណុលនៃការអនុវត្ត, | Y= កូនបំណុលនៃការអនុវត្ត, Z= អ្នកទិញ |
| - ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០១៣ | X បានធ្វើកិច្ចសន្យាបង្កើតហ៊ីប៉ូតែកលើដីរបស់ Y ហើយបានចុះបញ្ជីនៅក្នុងថ្ងៃដដែល |
| - ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៥ | ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំដោយផ្អែកតាមពាក្យសុំឲ្យអនុវត្តហ៊ីប៉ូតែករបស់ X |
| - ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៥ | ធ្វើការចុះបញ្ជីអំពីការរឹបអូសដើម្បី X |
| - ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៥ | Y បានធ្វើកិច្ចសន្យាបង្កើតហ៊ីប៉ូតែកឲ្យទៅ A ហើយបានចុះបញ្ជីនៅក្នុងថ្ងៃដដែល |
| - ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៥ | Y បានចុះបញ្ជីផ្ទេរកម្មសិទ្ធិឲ្យទៅ B ហើយបានចុះបញ្ជីនៅក្នុងថ្ងៃដដែល |
| - ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១៥ | ដីកាសម្រេចអនុញ្ញាតឲ្យលក់ដែលមាន Z ជាអ្នកទិញ |
| - ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ | Z បានបង់ថ្លៃលក់ |

- **កម្មវត្ថុ៖** ជាឧទាហរណ៍ គឺសរសេរដូចខាងក្រោម។ យ៉ាងណាមិញ នៅក្នុងលិខិតផ្ទុកផ្តាក់ ១សន្លឹក ក្រឡាបញ្ជីអាចធ្វើការសរសេរការផ្ទុកផ្តាក់ច្រើនករណី។

  ១. "ការចុះបញ្ជីផ្ទេរកម្មសិទ្ធិដែលអ្នកទិញបានធ្វើលទ្ធកម្ម" ៖ ប៉ុន្តែ ការសរសេរបែបនេះមិនចាំបាច់ទេ ក្នុងករណីដែលអ្នកទិញគឺជា អ្នកបង្កើតហ៊ីប៉ូតែក (ពោលគឺ ករណីដែលអ្នកធានាដោយវត្ថុជា អ្នកទិញ) ។

  ២. "ការលុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់"

  ៣. "ការលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលបានបាត់បង់អានុភាពដោយការលក់"

  ៤. "ការលុបការចុះបញ្ជី អំពីការរឹបអូស ឬ ការរឹបអូសជាបណ្តោះអាសន្ន"

- **ក- អត្តសញ្ញាណនៃអចលនវត្ថុ៖** ត្រូវសរសេរ លេខក្បាលដី ឬ លេខប័ណ្ណ និង ទីតាំងដី។ <u>**ក្រឡាបញ្ជី ត្រូវអានដីកាសម្រេចអនុញ្ញាតឲ្យលក់ និង ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុឲ្យបានច្បាស់លាស់ ហើយត្រូវសរសេរតាមអត្តសញ្ញាណទាំងនេះ។**</u>

- ខ- ឈ្មោះ និង អាសយដ្ឋានរបស់កម្មសិទ្ធិករ (ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគី) នៃអចលនវត្ថុ៖ ក្រឡាបញ្ជី ត្រូវអានដីកាសម្រេចអនុញ្ញាតឲ្យលក់ និង ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុឲ្យបានច្បាស់លាស់ ហើយត្រូវសរសេរតាមអត្តសញ្ញាណទាំងនេះ។
- **គ- គោលបំណងនៃការចុះបញ្ជី៖** ជាឧទាហរណ៍ ត្រូវសរសេរខ្លឹមសារដូចខាងក្រោម។ វាមានភាពចាំបាច់ក្នុងការប្រើប្រាស់ពាក្យពេចន៍ឲ្យស្របទៅនឹងការអនុវត្តជាក់ស្តែង។

  ១. ផ្ទេរកម្មសិទ្ធិតាមការលក់ដោយបង្ខំទៅឲ្យ Z

  ២.លុបការចុះបញ្ជីបង្កើតហ៊ីប៉ូតែកលំដាប់ទី ១ របស់ X ផ្អែកតាមកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០១៣

  ៣. លុបការចុះបញ្ជីបង្កើតហ៊ីប៉ូតែកលំដាប់ទី ២ របស់ A ផ្អែកតាមកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៥

  ៤. លុបការចុះបញ្ជីផ្ទេរកម្មសិទ្ធិទៅ B ផ្អែកតាមកិច្ចសន្យាលក់ទិញ ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៥

  ៥. លុបការចុះបញ្ជីអំពីការរឹបអូស ផ្អែកតាមដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ លេខ ១២៣៤ ចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៥ របស់សាលាដំបូងខេត្តកំពត ចំណុច "ក"

- **ឃ- មូលហេតុ៖** ឧទាហរណ៍ គេសរសេរថា "ដីកាសម្រេចអនុញ្ញាតឲ្យលក់ លេខ ៥៦៧៨ ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១៥ របស់សាលាដំបូងខេត្តកំពត និង អ្នកទិញបានបង់ប្រាក់ថ្លៃលក់ទៅឲ្យសាលាដំបូងខេត្តកំពត នៅថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៥"
- **ង- ឈ្មោះ និង អាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត៖** ក្រឡាបញ្ជី ត្រូវអានដីកាសម្រេចអនុញ្ញាតឲ្យលក់ឲ្យបានច្បាស់លាស់ ហើយត្រូវសរសេរឲ្យដូចអត្តសញ្ញាណដែលមានកំណត់នៅក្នុងដីកាសម្រេចនោះ។
- **ច- ឈ្មោះ និង អាសយដ្ឋានរបស់កូនបំណុលនៃការអនុវត្ត៖** ក្រឡាបញ្ជី ត្រូវអានដីកាសម្រេចអនុញ្ញាតឲ្យលក់ និង ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុឲ្យបានច្បាស់លាស់ ហើយត្រូវសរសេរឲ្យដូចអត្តសញ្ញាណដែលមានកំណត់នៅក្នុងឯកសារទាំងនោះ។
- **ឆ- អត្តសញ្ញាណអ្នកទិញ៖** សរសេរ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត អាសយដ្ឋាន និង ឈ្មោះឪពុកម្តាយរបស់អ្នកទិញ ។

ឯកសារភ្ជាប់ជាមួយលិខិតផ្ទុកផ្ដាក់ឲ្យចុះបញ្ជី៖

- ឯកសារចម្លងយថាភូត នៃដីកាសម្រេចអនុញ្ញាតឲ្យលក់
- ឯកសារថតចម្លងអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនរបស់អ្នកទិញ
- ឯកសារថតចម្លងយថាភូតនៃកំណត់ហេតុ ដែលបញ្ជាក់ថាអ្នកទិញ បានបង់ថ្លៃលក់ទៅតុលាការអនុវត្តរួចហើយ

＊មិនចាំបាច់ភ្ជាប់មកជាមួយប័ណ្ណកម្មសិទ្ធិទេ។

**<u>សំណួរទី ៣៧៖ តើនរណា ជាអ្នកបង់សោហ៊ុយចាំបាច់ដើម្បីផ្ទុកផ្ដាក់ឲ្យចុះបញ្ជី ហើយបង់ដោយរបៀបណា?</u>**

**<u>សោហ៊ុយចាំបាច់ដើម្បីផ្ទុកផ្ដាក់ឲ្យចុះបញ្ជីជាបន្ទុករបស់អ្នកទិញ</u>** (ក្រមនីតិ/ណី មាត្រា ៤៤៨ កថា. ៣)។ ក្រមនីតិវិធីរដ្ឋប្បវេណីមិនបានបញ្ញត្តអំពីរបៀបនៃការបង់ទេ វាអាស្រ័យទៅតាមតុលាការនីមួយៗដែលត្រូវអនុវត្តឲ្យមានលក្ខណៈសមស្រប។ នៅមុនពេលដែលក្រឡាបញ្ជីផ្ទុកផ្ដាក់ឲ្យចុះបញ្ជី អ្នកទិញត្រូវបង់សោហ៊ុយចុះបញ្ជី។ ឧទាហរណ៍ តុលាការអនុវត្តអាចពិចារណា ចាត់ចែងឲ្យអ្នកទិញបង់សោហ៊ុយចុះបញ្ជីស្របពេលដែលអ្នកទិញបង់ប្រាក់ថ្លៃលក់អចលនវត្ថុទៅឲ្យតុលាការអនុវត្ត ជាដើម។

**<u>សំណួរទី ៣៨៖ តើការចុះបញ្ជីណាដែលត្រូវលុបចោលដោយការផ្ទុកផ្ដាក់?</u>**

ក្រឡាបញ្ជីត្រូវពិចារណាដោយប្រុងប្រយ័ត្នលើការផ្ទុកផ្ដាក់ឲ្យចុះបញ្ជីអំពីការលុប និង មិនលុបការចុះបញ្ជីដោយអានក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥១០ និងមាត្រា ៤៤៨ ឲ្យបានច្បាស់លាស់។ ជាទូទៅអាចពិចារណាបានដូចខាងក្រោម។

**ការចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិ និង ការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ននូវកម្មសិទ្ធិ**

- ការលុបការចុះបញ្ជី អំពីការរឹបអូសរបស់ម្ចាស់បំណុលអនុវត្ត (ក្រមនីតិ/ណី មាត្រា ៤៤៨ កថា. ១ ចំណុច ឃ)។
- ការលុបការចុះបញ្ជីទាំងអស់ ក្រៅពីការចុះបញ្ជីអំពីការរឹបអូស និង ការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នដោយមិនគិតពីកាលបរិច្ឆេទនៃការចុះបញ្ជី។

ឧទាហរណ៍៖




① : ការចុះបញ្ជីរឹបអូសជាបណ្ដោះអាសន្ន→ លុប

③ : ការចុះបញ្ជីរឹបអូសជាបណ្ដោះអាសន្ន→ លុប

⑤ : ការចុះបញ្ជីរឹបអូស (ដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា ក្រមនីតិ/ណី មាត្រា ៤២៥) → លុប

＊ការចុះបញ្ជី ② និង ④ ក៏លុបដែរ។

**ការចុះបញ្ជីអំពីសិទ្ធិប្រាតិភោគប្រត្យក្ស និង សិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល**

- ការចុះបញ្ជីបង្កើតហ៊ីប៉ូតែករបស់ម្ចាស់បំណុលនៃការអនុវត្ត ត្រូវលុប (ក្រមនីតិ/ណី មាត្រា ៥១០ កថា.១, កថា. ២, មាត្រា ៤៤៨ កថា. ១ ចំណុច ខ)។
- សិទ្ធិប្រាតិភោគប្រត្យក្ស និង សិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល ដែលបានចុះបញ្ជីនៅក្រោយការចុះបញ្ជីបង្កើតហ៊ីប៉ូតែករបស់ម្ចាស់បំណុលនៃការអនុវត្ត ក៏ត្រូវលុបដែរ (ក្រមនីតិ/ណី មាត្រា ៥១០ កថា.១, កថា.២, មាត្រា ៤៤៨ កថា.១ ចំណុច ខ)។
- នៅក្នុងករណីម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់មុនម្ចាស់បំណុលនៃការអនុវត្ត បានទទួលដីកាសម្រេចចាប់ផ្ដើមត្រួតគ្នា ការចុះបញ្ជីបង្កើតហ៊ីប៉ូតែក និង សិទ្ធិប្រាតិភោគប្រត្យក្ស និង សិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល ដែលបានចុះបញ្ជី នៅក្រោយការចុះបញ្ជីបង្កើតហ៊ីប៉ូតែករបស់ម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់មុននោះ ក៏ត្រូវលុបដែរ (ក្រមនីតិ/ណី មាត្រា ៥១៣ កថា.២, មាត្រា ៤៤៨ កថា. ១ ចំណុច ខ)។

ឧទាហរណ៍ទី១៖




① : ការចុះបញ្ជីបង្កើតហ៊ីប៉ូតែកលំដាប់ទី ១→ មិនលុប

② : ការចុះបញ្ជីអំពីសិទ្ធិជួលអចិន្ត្រៃយ៍→ មិនលុប

③ : ការចុះបញ្ជីបង្កើតហ៊ីប៉ូតែកលំដាប់ទី ២→ មិនលុប

⑤ : ការចុះបញ្ជីបង្កើតហ៊ីប៉ូតែកលំដាប់ទី ៤→ លុប

＊ការចុះបញ្ជី ④ និង ⑥ ក៏លុបដែរ។

ឧទាហរណ៍ទី២៖




① : ការចុះបញ្ជីបង្កើតហ៊ីប៉ូតែកលំដាប់ទី ១ → លុប

② : ការចុះបញ្ជីអំពីសិទ្ធិជួលអចិន្ត្រៃយ៍→ លុប

③ : ការចុះបញ្ជីបង្កើតហ៊ីប៉ូតែកលំដាប់ទី ២→ លុប

⑤ : ការចុះបញ្ជីបង្កើតហ៊ីប៉ូតែកលំដាប់ទី ៤→ លុប

＊ការចុះបញ្ជី ④, ⑥ និង⑦ ក៏លុបដែរ។

**ការចុះបញ្ជីចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង**

- ការចុះបញ្ជីចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ដែលបានធ្វើឡើងនៅក្រោយការចុះបញ្ជីបង្កើតហ៊ីប៉ូតែករបស់ម្ចាស់បំណុលនៃការអនុវត្ត ត្រូវលុប (ក្រមនីតិ/ណី មាត្រា ៤៤៨ កថា. ១ ចំណុច គ)។
- នៅក្នុងករណីដែលបានចុះបញ្ជីរឹបអូសជាបណ្តោះអាសន្ន នៅមុនការចុះបញ្ជីបង្កើតហ៊ីប៉ូតែករបស់ម្ចាស់បំណុលនៃការអនុវត្ត នោះការចុះបញ្ជីចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ដែលបានធ្វើឡើងនៅក្រោយការចុះបញ្ជីរឹបអូសជាបណ្តោះអាសន្ននោះ ក៏ត្រូវលុបដែរ (ក្រមនីតិ/ណី មាត្រា ៥១០ កថា.៣, មាត្រា ៤៤៨ កថា. ១ ចំណុច គ)។

<u>ឧទាហរណ៍ទី១</u>៖




① : ការចុះបញ្ជីចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង → មិនលុប

③ : ការចុះបញ្ជីចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង→ លុប

⑤ : ការចុះបញ្ជីចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង→ លុប

＊ការចុះបញ្ជី ② និង ④ ក៏លុបដែរ។

<u>ឧទាហរណ៍ទី២</u>៖



② : ការចុះបញ្ជីចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង→ លុប

④ : ការចុះបញ្ជីចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង→ លុប

⑥ : ការចុះបញ្ជីចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង→ លុប

＊ការចុះបញ្ជី ①, ③ និង⑤ ក៏លុបដែរ។

**ការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ**

・ការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ ដែលត្រូវបានធ្វើឡើងនៅក្រោយការចុះបញ្ជីរឹបអូសរបស់ម្ចាស់បំណុលនៃការអនុវត្ត ត្រូវលុប (ក្រមនីតិ/ណី មាត្រា ៤៨ កថា.១ ចំណុច ខ)។

ឧទាហរណ៍ទី១៖




① : ការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ→ មិនលុប

＊លុបការចុះបញ្ជី ① និង ③។

ឧទាហរណ៍ទី២៖




③ : ការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ → លុប

＊ការចុះបញ្ជី ① និង ② ក៏លុបដែរ។

**ដំណាក់កាលទី ២៥. ការចុះបញ្ជីផ្អែកតាមការផ្ទុកផ្តាក់៖** មន្ត្រីចុះបញ្ជី ត្រូវធ្វើការចុះបញ្ជីដោយផ្អែកតាមលិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជី។

**<u>សំណួរទី ៣៩៖ តើមន្ត្រីចុះបញ្ជីដែលបានទទួលលិខិតផ្ទុកផ្តាក់ឲ្យចុះបញ្ជី ត្រូវសរសេរអ្វីខ្លះទៅក្នុងសៀវភៅចុះបញ្ជី ?</u>**

ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ប្រការ ២៨ មានចែងអំពីរបៀបនៃការចុះបញ្ជី។ វាមានភាពចាំបាច់ក្នុងការប្រើប្រាស់ពាក្យពេចន៍ឲ្យស្របទៅនឹងការអនុវត្តជាក់ស្តែង។

១. ការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ

នៅក្នុងខ្ទង់ត្រង់ "លេខាចារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬសាលក្រមតុលាការ" ត្រូវសរសេរដូចខាងក្រោម៖

ឧទាហរណ៍៖ "ត្រូវបានផ្ទេរកម្មសិទ្ធិរបស់ Y ទៅឲ្យ Z តាមដីកាសម្រេចអនុញ្ញាតឲ្យលក់ លេខ ៥៦៧៨ (ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១៥ របស់សាលាដំបូងខេត្តកំពត) និង អ្នកទិញបានបង់ថ្លៃលក់ឲ្យទៅសាលាដំបូងខេត្តកំពត នៅថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ លរ Aj ១១១១" (សរសេរជាទឹកខៀវ ឬ ខ្មៅ)

បោះត្រាលេខាចារឹក ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (សរសេរជាទឹកក្រហម)

នៅក្នុងខ្ទង់ត្រង់ "នាមត្រកូល និងនាមខ្លួន ប្រភេទទ្រព្យ"

ត្រូវសរសេរថា "Z" ជាទឹកខៀវ ឬ ខ្មៅ។

នៅក្នុងខ្ទង់ត្រង់ "ថ្ងៃខែឆ្នាំ និងទីកន្លែងកំណើត"

ត្រូវសរសេរ ថ្ងៃខែឆ្នាំកំណើត និងទីកន្លែងកំណើតរបស់Z ជាទឹកខៀវ ឬ ខ្មៅ។

នៅក្នុងខ្ទង់ត្រង់ "សាវតា"

ត្រូវសរសេរ ឈ្មោះឪពុក និងម្តាយរបស់Z ជាទឹកខៀវ ឬ ខ្មៅ។

២. នៅក្នុងខ្ទង់ត្រង់ "បន្ទុកលើអចលនវត្ថុ" ការលុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិដែលបានរលត់ដោយការលក់ ឬ សិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់ ត្រូវសរសេរដូចខាងក្រោម៖

ឧទាហរណ៍៖ "ត្រូវលុបការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែកឲ្យ A (ផ្អែកតាមកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៥) តាមដីកាសម្រេចអនុញ្ញាតឲ្យលក់ លេខ ៥៦៧៨ (ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១៥ របស់សាលាដំបូងខេត្តកំពត ) និង អ្នកទិញបានបង់ថ្លៃលក់ឲ្យទៅសាលាដំបូងខេត្តកំពត នៅថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ លរ Aj ១២ " (សរសេរជាទឹកខៀវ ឬ ខ្មៅ)

បោះត្រាលេខាចារឹក ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (សរសេរជាទឹកក្រហម)

នៅក្នុងខ្ទង់ត្រង់ "លេខាចារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬ សាលក្រមតុលាការ" ត្រូវសរសេរដូចខាងក្រោម។

ឧទាហរណ៍៖ "ត្រូវបានលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិឲ្យ B (ផ្អែកតាម កិច្ចសន្យាលក់ទិញ ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ២០១៥) តាមដីកាសម្រេចអនុញ្ញាតឲ្យលក់ លេខ ៥៦៧៨ (ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១៥ របស់សាលាដំបូងខេត្តកំពត ) និង អ្នកទិញបានបង់ថ្លៃលក់ឲ្យទៅសាលាដំបូងខេត្តកំពត នៅថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ លរ Aj ១២ និង " (សរសេរជាទឹកខៀវ ឬ ខ្មៅ)

បោះត្រាលេខាចារឹក ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (សរសេរជាទឹកក្រហម)

៣. ការលុបការចុះបញ្ជីចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែង ដែលបានបាត់បង់អានុភាពដោយសារការលក់

នៅក្នុងករណី មានការលុបការចុះបញ្ជីចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែង ដែលបានបាត់បង់អានុភាពដោយសារការលក់ ត្រូវសរសេរអំពីការណ៍លុបនេះ នៅក្នុងខ្ទង់ត្រង់ "បន្ទុកលើអចលនវត្ថុ" ។

៤. ការចុះបញ្ជីលុបការចុះបញ្ជីរឹបអូស ឬ រឹបអូសជាបណ្ដោះអាសន្ន

នៅក្នុងខ្ទង់ត្រង់ "បន្ទុកលើអចលនវត្ថុ" ត្រូវសរសេរដូចខាងក្រោម៖

ឧទាហរណ៍៖ "ត្រូវបានលុបការចុះបញ្ជីអំពីការរឹបអូស (កម្មសិទ្ធិដែលតុលាការអនុវត្តនៃសាលាដំបូងខេត្តកំពត បានចេញដីកាសម្រេច លេខ ១២៣៤ ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥) តាមដីកាសម្រេចអនុញ្ញាតឲ្យលក់ លេខ ៥៦៧៨ (ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១៥ របស់សាលាដំបូងខេត្តកំពត ) និង អ្នកទិញបានបង់ថ្លៃលក់ឲ្យទៅសាលាដំបូងខេត្តព្រះវិហារ នៅថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ លរ Aj ១២ ។" (សរសេរជាទឹកក្រហម)

បោះត្រាលេខាចារឹក ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (សរសេរជាទឹកខៀវ ឬ ខ្មៅ)

## ផ្នែកទី ៣ ការចែកចំណែក

**ដំណាក់កាលទី ២៦. ការកំណត់កាលបរិច្ឆេទនៃការចែកចំណែក៖** តុលាការអនុវត្ត ត្រូវកំណត់កាលបរិច្ឆេទនៃការចែកចំណែក នៅពេលដែលមានការបង់ថ្លៃលក់ ឬ នៅពេលដែលដីកាសម្រេចអនុញ្ញាតឲ្យលក់បានចូលជាស្ថាពរ នៅក្នុងករណីដែលមានការស្នើសុំបង់តែចំនួនខ្វះ (ក្រមនីតិ/ណី មាត្រា ៤៨៨ កថា.១ ចំណុច គ)។

**ដំណាក់កាលទី ២៧. ការជូនដំណឹងអំពីកាលបរិច្ឆេទនៃការចែកចំណែក និង ការដាស់តឿនឲ្យដាក់លិខិតគណនា ជាដើម៖** បើកាលបរិច្ឆេទនៃការចែកចំណែកត្រូវបានកំណត់រួច តុលាការអនុវត្តត្រូវធ្វើការជូនដំណឹង ជាអាទិ៍ ដូចខាងក្រោម៖ (Slide 79)

(១) តុលាការអនុវត្ត ត្រូវធ្វើការជូនដំណឹងអំពីទីកន្លែង និង កាលបរិច្ឆេទនៃការចែកចំណែក ទៅម្ចាស់បំណុលនៃការអនុវត្តដែលត្រូវទទួលការចែកចំណែក និង កូនបំណុលនៃការអនុវត្ត (ក្រមនីតិ/ណី មាត្រា ៤៨៨ កថា.១ ចំណុច គ)។

(២) តុលាការអនុវត្ត ត្រូវធ្វើការកោះហៅម្ចាស់បំណុលនៃការអនុវត្តដែលត្រូវទទួលការចែកចំណែក និង កូនបំណុលនៃការអនុវត្ត (ក្រមនីតិ/ណី មាត្រា ៤៩០ កថា.២, ចំណុច គ)។

(៣) ក្រឡាបញ្ជី ត្រូវដាស់តឿនម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែក ឲ្យផ្តល់លិខិតគណនាអំពីប្រាក់ដើមនៃសិទ្ធិលើបំណុល ការប្រាក់រហូតដល់កាលបរិច្ឆេទនៃការចែកចំណែក និង សោហ៊ុយសម្រាប់ការអនុវត្ត ទៅតុលាការអនុវត្តក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ (ក្រមនីតិ/ណី មាត្រា ៤៨៨ កថា.២)។

**<u>សំណួរទី ៤០៖ ក្នុងករណី ដែលម្ចាស់បំណុលមិនបានផ្តល់លិខិតគណនា តើតុលាការអនុវត្តចាំបាច់ត្រូវអនុវត្តការចែកចំណែកទៅឲ្យម្ចាស់បំណុលនោះដែរឬទេ?</u>**

ទោះបីជាមិនបានផ្តល់លិខិតគណនាក៏ដោយ វាមិនមានន័យថា ម្ចាស់បំណុលនោះបាត់បង់នូវលក្ខណៈសម្បត្តិក្នុងការទទួលការចែកចំណែកនោះទេ។ ហេតុនេះ **<u>តុលាការអនុវត្ត ត្រូវតែអនុវត្តការចែកចំណែកទៅឲ្យម្ចាស់បំណុលនោះដូចធម្មតា។</u>** ដោយសារតែម្ចាស់បំណុលមិនបានផ្តល់លិខិតគណនា ហេតុនេះ តុលាការអនុវត្ត ត្រូវមើលឯកសារដែលមានស្រាប់ (ឯកសារចម្លងយថាភូតនៃសៀវភៅចុះបញ្ជីអចលនវត្ថុ លិខិតទាមទារឲ្យចែកចំណែកដែលបញ្ញត្តនៅក្នុងមាត្រា ៤២៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី របាយការណ៍អំពីសិទ្ធិលើបំណុលដែលបញ្ញត្តនៅក្នុងមាត្រា ៤២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ជាដើម) ហើយធ្វើការគណនាទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនោះ ដោយខ្លួនឯង។ ម្យ៉ាងទៀត ទោះបីជា ម្ចាស់បំណុលបានផ្តល់លិខិតគណនានៅក្រោយរយៈពេល ១ សប្តាហ៍ក៏ដោយ ក៏តុលាការអនុវត្ត ត្រូវទទួលយកឯកសារនោះមកប្រើប្រាស់ ព្រោះលិខិតគណនានោះមានអត្ថប្រយោជន៍ក្នុងការប្រើសម្រាប់ឲ្យតុលាការអនុវត្តបង្កើតសេចក្តីព្រាងដើមនៃតារាងចែកចំណែក។

**ដំណាក់កាលទី ២៨. ការបង្កើតសេចក្តីព្រាងដើមនៃតារាងចែកចំណែក៖** តុលាការអនុវត្ត ត្រូវគណនាចំណែកសម្រាប់ម្ចាស់បំណុលនីមួយៗ។ ក្រឡាបញ្ជី ត្រូវគណនាចំនួនទឹកប្រាក់នៃសោហ៊ុយសម្រាប់ការអនុវត្ត ហើយបង្កើតសេចក្តីព្រាងដើមនៃតារាងចែកចំណែក នៅមុនកាលបរិច្ឆេទនៃការចែកចំណែក។(Slide 80)

**<u>សំណួរទី ៤១៖ តើសេចក្តីព្រាងដើមនៃតារាងចែកចំណែកត្រូវបង្កើតឡើងដោយរបៀបណា?</u>** (Slide 81)

សេចក្តីព្រាងដើមនៃតារាងចែកចំណែក គឺជាឯកសារដែលមានសរសេរថា តើត្រូវធ្វើការចែកចំណែកប៉ុន្មានទៅឲ្យនរណា។ តុលាការអនុវត្ត ត្រូវបង្ហាញសេចក្តីព្រាងដើមនៃតារាងចែកចំណែកទៅ ម្ចាស់បំណុល និង កូនបំណុលនៃការអនុវត្ត។ ប្រសិនបើ គ្មានការតវ៉ាទេ "សេចក្តីព្រាងដើមនៃតារាងចែកចំណែក" នឹងក្លាយជា "តារាងចែកចំណែក"។ បន្ទាប់មក តុលាការអនុវត្ត នឹងធ្វើការចែកចំណែកស្របទៅតាមតារាងចែកចំណែក។ ដូច្នេះ តុលាការអនុវត្ត ត្រូវបង្កើតសេចក្តីព្រាងដើមនៃតារាងចែកចំណែកឲ្យបានត្រឹមកាលបរិច្ឆេទនៃការចែកចំណែក។ ជាគោលការណ៍ តុលាការអនុវត្ត ត្រូវធ្វើការគណនាចំណែកសម្រាប់ម្ចាស់បំណុលនីមួយៗ ដោយប្រើលិខិតគណនា

ដែលម្ចាស់បំណុលបានដាក់កាលពីដំណាក់ទី ២៧ ជាមូលដ្ឋាន។ ប៉ុន្តែ ក៏មានករណីដែលលិខិតគណនាដែលបានដាក់ដោយម្ចាស់បំណុលមានកំហុសដែរ ហេតុនេះ តុលាការអនុវត្តចាំបាច់ត្រូវធ្វើការត្រួតពិនិត្យខ្លឹមសារនៃលិខិតគណនានោះ ថាត្រឹមត្រូវ ឬទេ។ ម្យ៉ាងទៀត ក្នុងករណីដែលម្ចាស់បំណុលមិនបានដាក់លិខិតគណនា តុលាការអនុវត្ត ត្រូវធ្វើការគណនាចំណែកសម្រាប់ម្ចាស់បំណុលនីមួយៗ ដោយផ្អែកទៅលើឯកសារដែលមាននៅក្នុងដៃស្រាប់។

**(១) ត្រូវគណនាចំនួនទឹកប្រាក់នៃប្រាក់សម្រាប់ចែកចំណែក (Slide 82~ 85)**

ប្រាក់សម្រាប់ចែកចំណែក មិនមែនត្រឹមតែជាថ្លៃលក់អចលនវត្ថុនោះទេ ប៉ុន្តែ ជាប្រាក់ដែលរួមបញ្ចូលទាំងប្រាក់ធានាដែលអ្នកទិញពុំអាចទាមទារឲ្យតុលាការអនុវត្តសងមកវិញបាន (ក្រមនីតិ/ណី មាត្រា ៤៥២ កថា.១)។ លើសពីនេះ នៅក្នុងករណីដីកាសម្រេចបង្គាប់ឲ្យរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត នោះថ្លៃឈ្នួលដែលកតិកៈនៃអចលនវត្ថុហ៊ីប៉ូតែក បានធ្វើនៅតុលាការអនុវត្ត ត្រូវចាត់ទុកជាថ្លៃលក់ (ក្រមនីតិ/ណី មាត្រា ៥១៧ កថា.៣)។ ដំបូង តុលាការអនុវត្ត ត្រូវកំណត់ចំនួនទឹកប្រាក់នេះជាមុនសិន។

**(២) ត្រូវបញ្ជាក់អំពីវិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែក (Slide 86, 87)**

ក្នុងករណីមានការលក់ដោយបង្ខំដោយផ្អែកតាមការអនុវត្តហ៊ីប៉ូតែក ជនខាងក្រោមនេះនឹងត្រូវទទួលបានការចែកចំណែក (ក្រមនីតិ/ណី មាត្រា ៥១៩, មាត្រា ៤៥៣)។

**ក. ម្ចាស់បំណុលដែលបានដាក់ពាក្យសុំការលក់ដោយបង្ខំ ឬ ការលក់ដោយបង្ខំដែលជាការអនុវត្តឯកសិទ្ធិទូទៅរហូតដល់កំណត់ពេលចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក។**

**ខ. ម្ចាស់បំណុលដែលបានទាមទារឲ្យចែកចំណែក រហូតដល់ពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក។**

**គ. ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន មុនការចុះបញ្ជីអំពីការរឹបអូសដែលជាមូលដ្ឋាននៃដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំជាដំបូង។**

(ប៉ុន្តែ ដោយសារបណ្ដឹងអង្គសេចក្ដីដែលបញ្ជាក់ពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិលើបំណុលមិនទាន់ចូលជាស្ថាពរ ហេតុនេះ ការចែកចំណែកត្រូវបានផ្អាកទុកសិន រហូតដល់ពេលបណ្ដឹងអង្គសេចក្ដីនោះត្រូវបានសម្រេចដាច់ស្រេច។ ក្រមនីតិ/ណី មាត្រា ៤៩៤ កថា.១ ចំណុច ខ, មាត្រា ៤៩៥ កថា.១។)

**ឃ. ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគដែលត្រូវរលត់ដោយការលក់។ ប៉ុន្តែ វាមិនត្រូវយកមកអនុវត្តឡើយចំពោះម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគដែលបានចុះបញ្ជី ក្រោយពេលអានុភាពនៃការរឹបអូសបានកើតឡើង។**

នៅក្នុងករណី ម្ចាស់បំណុល ក ដាក់ពាក្យសុំលក់ដោយបង្ខំទៅតុលាការអនុវត្ត ហើយម្ចាស់បំណុល ខ ទាមទារឲ្យតុលាការអនុវត្តធ្វើការចែកចំណែក នោះអត្ថិភាពនៃសិទ្ធិលើបំណុលទាំងនោះ នឹងមានភាពច្បាស់លាស់ចំពោះតុលាការអនុវត្ត។

ទោះបីជា ម្ចាស់បំណុល គ មិនធ្វើការទាមទារឲ្យចែកចំណែកជាដើមក៏ដោយ ប៉ុន្តែដោយសារនៅក្នុងឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុរបស់តុលាការអនុវត្ត មានសរសេរអំពីម្ចាស់បំណុល គ នោះតុលាការអនុវត្ត ត្រូវពិនិត្យឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុនោះឲ្យបានច្បាស់លាស់ ហើយមិនត្រូវមើលរំលងឡើយ។ យ៉ាងណាមិញ ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ននៅក្រោយការចុះបញ្ជីអំពីការរឹបអូស មិនមានសរសេរនៅក្នុងឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុរបស់តុលាការអនុវត្តទេ ហេតុនេះប្រសិនបើមិនធ្វើការទាមទារឲ្យចែកចំណែក នឹងមិនអាចទទួលបានចំណែកនោះទេ (ក្រមនីតិ/ណី មាត្រា ៤២៦ កថា. ១ ចំណុច ខ។ ប៉ុន្តែ ការចែកចំណែកនឹងត្រូវបានផ្អាកទុក រហូតដល់ពេលបណ្ដឹងអង្គសេចក្ដីត្រូវបានសម្រេចដាច់ស្រេច។ ក្រមនីតិ/ណី មាត្រា ៤៩៤ កថា. ១ ចំណុច ខ និង មាត្រា ៤៩៥ កថា.១។)

ម្ចាស់បំណុល ឃ គឺជាម្ចាស់បំណុលដែលមិនចាំបាច់ធ្វើការទាមទារឲ្យចែកចំណែក ក៏អាចទទួលបានចំណែកដែរ ហេតុនេះតុលាការអនុវត្តត្រូវពិនិត្យឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុនោះឲ្យបានច្បាស់លាស់ ហើយមិនត្រូវមើលរំលងឡើយ។ "សិទ្ធិប្រាតិភោគដែលត្រូវរលត់ដោយការលក់" គឺដូចទៅនឹងការចុះបញ្ជីនៃសិទ្ធិប្រាតិភោគប្រត្យក្សដែលត្រូវបានលុបដោយការផ្ទុកផ្ដាក់ដែលបានសរសេរនៅខាងលើ។

តុលាការអនុវត្ត ត្រូវស្វែងរកម្ចាស់បំណុល គ និង ឃ ដោយមើលលើឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ។ ដូច្នេះ **តុលាការអនុវត្តចាំបាច់ត្រូវឲ្យម្ចាស់បំណុលនៃការអនុវត្តផ្ដល់ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ ហើយបន្ថែមពីលើនេះ តុលាការអនុវត្តត្រូវឲ្យរដ្ឋបាលសុរិយោដីផ្ញើឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ រួចត្រូវស្វែងរកម្ចាស់បំណុល គ និង ឃ ដោយមើលលើឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុនោះ ហើយចាំបាច់ត្រូវធ្វើការចែកចំណែក។**

### (៣) ត្រូវគណនាចំនួនទឹកប្រាក់នៃសោហ៊ុយសម្រាប់ការអនុវត្ត

ក្រឡាបញ្ជី ត្រូវគណនាចំនួនទឹកប្រាក់នៃសោហ៊ុយសម្រាប់ការអនុវត្ត (ក្រមនីតិ/ណី មាត្រា ៣៧៦, មាត្រា ៦៦ កថា. ១)។ សោហ៊ុយសម្រាប់អនុវត្តរួមមាន សោហ៊ុយសម្រាប់ផលប្រយោជន៍រួម (សោហ៊ុយដែលចំណាយដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុលទាំងអស់) គឺត្រូវចែកចំណែកទៅឲ្យម្ចាស់បំណុលដែលបានបង់សោហ៊ុយនេះ ដោយមានអាទិភាពជាងម្ចាស់បំណុលដទៃទៀត។ សោហ៊ុយសម្រាប់ផលប្រយោជន៍រួម គឺជាសោហ៊ុយដែលចំណាយ ដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុលទាំងអស់ ដែលមិនមានចែងច្បាស់លាស់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ក៏ប៉ុន្តែ សោហ៊ុយនេះត្រូវបានគេធ្វើការចែកចំណែកដោយមានលក្ខណៈអាទិភាពបំផុត។ ផ្ទុយទៅវិញ សោហ៊ុយសម្រាប់ការអនុវត្តដែលមិនមែនជាសោហ៊ុយសម្រាប់ផលប្រយោជន៍រួម ត្រូវធ្វើការចែកចំណែកឲ្យមានលំដាប់ដូចគ្នាជាមួយនឹងម្ចាស់បំណុលនីមួយៗដែលមានសិទ្ធិលើបំណុល ព្រោះពុំមានមូលហេតុដែលត្រូវចែកចំណែកជាអាទិភាពទៅម្ចាស់បំណុលផ្សេងនោះទេ។

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ពុំមានបញ្ញត្ត ថាតើនៅក្នុងសោហ៊ុយសម្រាប់ការអនុវត្ត សោហ៊ុយណាជាសោហ៊ុយសម្រាប់ផលប្រយោជន៍រួម សោហ៊ុយណាមិនមែនជាសោហ៊ុយសម្រាប់ផលប្រយោជន៍រួមនោះទេ ហេតុនេះនៅក្នុងការអនុវត្តជាក់ស្តែងចាំបាច់ត្រូវពិចារណាឲ្យបានល្អិតល្អន់។ ជាគោលការណ៍ សោហ៊ុយសម្រាប់ផលប្រយោជន៍រួម គឺជាសោហ៊ុយដែលចំណាយសម្រាប់បន្តដំណើរការនីតិវិធីអនុវត្ត។ បើសោហ៊ុយនេះមិនត្រូវបានបង់ទេ នោះនីតិវិធីមិនអាចដំណើរការបានទេ។ ហេតុនេះ ដោយសារតែសោហ៊ុយនេះត្រូវបានបង់ ទើបម្ចាស់បំណុលទាំងអស់ទទួលបានផលប្រយោជន៍ (ដូច្នេះ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី គេហៅសោហ៊ុសម្រាប់ការអនុវត្តដែលជាសោហ៊ុយសម្រាប់ផលប្រយោជន៍រួមថា "សោហ៊ុយសម្រាប់នីតិវិធី" ក្រមនីតិ/ណី មាត្រា ៣៧១ ចំណុច ខ)។ ជាលទ្ធផល សោហ៊ុយសម្រាប់ការអនុវត្តដែលម្ចាស់បំណុលនៃការអនុវត្តបានចំណាយ ជាធម្មតា គឺជាសោហ៊ុយសម្រាប់ផលប្រយោជន៍រួម។ ផ្ទុយទៅវិញ សោហ៊ុយសម្រាប់ការអនុវត្តដែលត្រូវបានចំណាយដោយម្ចាស់បំណុលក្រៅពីម្ចាស់បំណុលនៃការអនុវត្ត ភាគច្រើនមិនមែនជាសោហ៊ុយសម្រាប់ផលប្រយោជន៍រួមទេ។ ឧទាហរណ៍៖ ប្រសិនបើ គេពិចារណាអំពីសោហ៊ុយសម្រាប់ធ្វើការទាមទារឲ្យចែកចំណែក ទោះជាម្ចាស់បំណុលមិនធ្វើការទាមទារឲ្យចែកចំណែកក៏ដោយ ក៏នីតិវិធីនៃការអនុវត្តអាចបន្តទៅបានដោយគ្មានបញ្ហាដែរ។ ការទាមទារឲ្យចែកចំណែក គឺធ្វើឡើងដើម្បីតែផលប្រយោជន៍របស់ម្ចាស់បំណុលនោះខ្លួនឯងតែប៉ុណ្ណោះ។ ហេតុនេះ វាមិនមែនជា សោហ៊ុយសម្រាប់ផលប្រយោជន៍រួមទេ។

**(៤) ត្រូវបញ្ជាក់អំពីលំដាប់នៃការចែកចំណែក និងគណនាចំនួនទឹកប្រាក់នៃការចែកចំណែក**

តុលាការអនុវត្ត ត្រូវធ្វើការកំណត់លំដាប់នៃម្ចាស់បំណុលនីមួយៗ ស្របទៅតាម ក្រមរដ្ឋប្បវេណី ច្បាប់ដែលទាក់ទងនឹងពាណិជ្ជកម្ម ឬ ច្បាប់ផ្សេងទៀត (ក្រមនីតិ/ណី មាត្រា ៤៩០ កថា.៥)។ ចំពោះ ហ៊ីប៉ូតែកត្រូវប្រយ័ត្ននូវចំណុចខាងក្រោម៖

- ម្ចាស់បំណុលហ៊ីប៉ូតែកត្រូវទទួលការចែកចំណែកដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត (ក្រមរដ្ឋប្បវេណី មាត្រា ៨៤៣ កថា. ១)។
- ក្នុងករណីធ្វើការចែកចំណែកឲ្យទៅម្ចាស់បំណុលហ៊ីប៉ូតែកច្រើន ម្ចាស់បំណុលហ៊ីប៉ូតែកដែលបានធ្វើការចុះបញ្ជីមុន មានអាទិភាពត្រូវទទួលបានការចែកចំណែកមុន (ក្រមរដ្ឋប្បវេណី មាត្រា៨៥១)។
- នៅក្នុងករណីសិទ្ធិលើបំណុលដែលបានត្រូវធានាដោយហ៊ីប៉ូតែកមានរួមបញ្ចូលទាំង ការប្រាក់ និង ចំនួនទឹកប្រាក់នៃសំណងការខូចខាតដោយសារការយឺតយ៉ាវ ម្ចាស់បំណុលហ៊ីប៉ូតែកត្រូវទទួលបានការចែកចំណែកដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតសម្រាប់អំឡុងពេល ២ (ពីរ) ឆ្នាំចុងក្រោយចាប់ពីកាលបរិច្ឆេទនៃការចែកចំណែក។ ប៉ុន្តែ ចំពោះការប្រាក់ និងចំនួនទឹកប្រាក់នៃសំណងការខូចខាតដោយសារការយឺតយ៉ាវ ដែលមានមុនអំឡុងពេលនេះ ម្ចាស់បំណុលហ៊ីប៉ូតែកត្រូវទទួលបានការចែកចំណែកដោយមានលំដាប់ដូចគ្នាជាមួយនឹងម្ចាស់បំណុលដែលគ្មានប្រាតិភោគ (ក្រមរដ្ឋប្បវេណី មាត្រា ៨៥២)។
- សិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវកំណត់នៅពេលដែលបានដាក់ពាក្យសុំឲ្យអនុវត្តហ៊ីប៉ូតែក (ក្រមរដ្ឋប្បវេណី មាត្រា ៨៨៥ កថា. ១ ចំណុច ក)។

លើកឧទាហរណ៍ដែលសាមញ្ញមួយ៖ (Slide 88 ~ 96)

នៅថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០១២ $X_1$ បានឲ្យ Y ខ្ចីប្រាក់ចំនួន ៣០០០០ ដុល្លារ។ ភាគីទាំងពីរបានព្រមព្រៀងគ្នាអំពី ថ្ងៃកំណត់សងនៅ ថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០១៣ ការប្រាក់ ១០% ក្នុង១ ឆ្នាំ, ការប្រាក់ដោយសារការយឺតយ៉ាវ ២០% ក្នុង ១ ឆ្នាំ។ នៅថ្ងៃដដែល $X_1$ បានបង្កើតហ៊ីប៉ូតែកលំដាប់ទី ១ លើអចលនវត្ថុ A ដែលជាកម្មសិទ្ធិរបស់ Y ព្រមទាំងបានចុះបញ្ជីផងដែរ។

នៅថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០១២ $X_2$ បានឲ្យ Y ខ្ចីប្រាក់ចំនួន ២០០០០ ដុល្លារ។ ភាគីទាំងពីរបានព្រមព្រៀងគ្នាអំពី ថ្ងៃកំណត់សងនៅ ថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០១៦ ការប្រាក់ ១០% ក្នុង១ ឆ្នាំ, ការប្រាក់ដោយសារការយឺតយ៉ាវ ២០% ក្នុង ១ ឆ្នាំ។ នៅថ្ងៃដដែល $X_2$ បានបង្កើតហ៊ីប៉ូតែកលំដាប់ទី ២ លើអចលនវត្ថុ A ដែលជាកម្មសិទ្ធិរបស់ Y ព្រមទាំងបានចុះបញ្ជីផងដែរ។

នៅថ្ងៃទី ១ ខែឧសភា ឆ្នាំ ២០១៥ $X_3$ បានឲ្យ Y ខ្ចីប្រាក់ចំនួន ៥០០០ ដុល្លារ។ ដោយសារតែ $X_3$ និង Y ជាមិត្តភក្តិនឹងគ្នា ហេតុនេះគាត់ទាំងពីរបានព្រមព្រៀងគ្នាថា មិនគិតពីការប្រាក់ និងការប្រាក់ដោយសារការយឺតយ៉ាវទេ។

ក្រោយមក ដោយសារតែមានព័ត៌មានថា ពាណិជ្ជកម្មរបស់ Y ជិតក្ស័យធន $X_3$ បានរឹបអូសជាបណ្ដោះអាសន្នលើអចលនវត្ថុ A ។ $X_3$ បានចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន នៅថ្ងៃទី ២០ ខែសីហា ឆ្នាំ២០១៥។

បន្ទាប់មក $X_1$ បានអនុវត្តហ៊ីប៉ូតែក ហើយនៅថ្ងៃទី ១ ខែកញ្ញា ឆ្នាំ ២០១៥ បានធ្វើការចុះបញ្ជីរឹបអូសដើម្បី $X_1$ ។ ក្រោយមក នីតិវិធីបានបន្ត ហើយ ដី A ត្រូវបានលក់ដោយបង្ខំទៅឲ្យ Z ។ Z បានបង់ប្រាក់ជានា និងប្រាក់ថ្លៃលក់ សរុបចំនួន ៧១០០០ ដុល្លារ ទៅឲ្យតុលាការអនុវត្ត។ តុលាការអនុវត្ត បានកំណត់កាលបរិច្ឆេទនៃការចែកចំណែក នៅថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០១៥។ សោហ៊ុយសម្រាប់នីតិវិធី (សោហ៊ុយសម្រាប់ផលប្រយោជន៍រួម ដែលនៅក្នុងសោហ៊ុយសម្រាប់ការអនុវត្ត) ដែលបានកើតឡើងគិតមកដល់កាលបរិច្ឆេទនោះគឺ ៥០០ ដុល្លារ។ សោហ៊ុយសម្រាប់ការអនុវត្តក្រៅពីនេះ មិនបានកើតឡើងទេ។

Y : កូនបំណុលនៃការអនុវត្ត

$X_1$ : ម្ចាស់បំណុលនៃការអនុវត្ត, ម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ១

$X_2$ : ម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី ២, ម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែក

$X_3$ : ម្ចាស់បំណុលនៃការរឹបអូសជាបណ្ដោះអាសន្ននៅមុនការចុះបញ្ជីអំពីការរឹបអូសរបស់ $X_1$, ម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែក

### ចំនួនសិទ្ធិលើបំណុលរបស់ $X_1$ នៅកាលបរិច្ឆេទនៃការចែកចំណែក

ចំនួនសិទ្ធិលើបំណុលរបស់ $X_1$ នៅកាលបរិច្ឆេទនៃការចែកចំណែកគឺ ៤៥០០០ ដុល្លារ។ នៅក្នុងនោះ មានប្រាក់ដើម ៣០០០០ ដុល្លារ, ការប្រាក់(ក្នុងអំឡុងពេល១ ឆ្នាំ) ៣០០០ ដុល្លារ, ចំនួនទឹកប្រាក់នៃសំណងការខូចខាតដោយសារការយឺតយ៉ាវ (ក្នុងអំឡុងពេល ២ឆ្នាំ) ១២០០០ ដុល្លារ។ ហ៊ីប៉ូតែក គ្របដណ្ដប់តែលើការប្រាក់ និងចំនួនទឹកប្រាក់នៃសំណងការខូចខាតដោយសារការយឺតយ៉ាវ សម្រាប់អំឡុងពេល ២ ឆ្នាំចុងក្រោយតែប៉ុណ្ណោះ។ ក្នុងអំឡុងពេល ២ ឆ្នាំនោះ គឺគណនាដោយគិតថយក្រោយចាប់ពីកាលបរិច្ឆេទនៃការចែកចំណែក។ ហេតុនេះ ហ៊ីប៉ូតែកគ្របដណ្ដប់តែលើ ចំនួនទឹកប្រាក់នៃសំណងការខូចខាតដោយសារការយឺតយ៉ាវ ១២០០០ ដុល្លារប៉ុណ្ណោះ មិនគ្របដណ្ដប់លើការប្រាក់ ៣០០០ ដុល្លារនោះទេ។ ដូច្នេះ ការប្រាក់ ៣០០០ ដុល្លារ នឹងត្រូវបានចែកក្នុងលំដាប់ដូចគ្នាទៅនឹងម្ចាស់បំណុលទូទៅដែលមិនត្រូវបានធានាដោយហ៊ីប៉ូតែក។




**ចំនួនសិទ្ធិលើបំណុលរបស់ $X_2$ នៅកាលបរិច្ឆេទនៃការចែកចំណែក**

ចំនួនសិទ្ធិលើបំណុលរបស់ $X_2$ នៅកាលបរិច្ឆេទនៃការចែកចំណែកគឺ ២៦០០០ ដុល្លារ។ នៅក្នុងនោះមានប្រាក់ដើម ២០០០០ ដុល្លារ, ការប្រាក់(ក្នុងអំឡុងពេល៣ ឆ្នាំ) ៦០០០ ដុល្លារ។ ហ៊ីប៉ូតែក គ្រប់ដណ្តប់តែលើការប្រាក់ និង ចំនួនទឹកប្រាក់នៃសំណងការខូចខាតដោយសារការយឺតយ៉ាវ សម្រាប់អំឡុងពេល ២ ឆ្នាំចុងក្រោយតែប៉ុណ្ណោះ។ ក្នុងអំឡុងពេល ២ ឆ្នាំនោះ គឺគណនាដោយគិតថយក្រោយចាប់ពីកាលបរិច្ឆេទនៃការចែកចំណែក។ ហេតុនេះ ហ៊ីប៉ូតែកគ្រប់ដណ្តប់តែលើ ការប្រាក់ក្នុងអំឡុងពេល ២ ឆ្នាំចុងក្រោយ ៤០០០ ដុល្លារ នៅក្នុងការប្រាក់ ៦០០០ ដុល្លារ ប៉ុណ្ណោះ មិនគ្រប់ដណ្តប់លើការប្រាក់ ២០០០ ដុល្លារទៀតនោះទេ។ ដូច្នេះ ការប្រាក់ ២០០០ ដុល្លារ នឹងត្រូវបានចែកក្នុងលំដាប់ដូចគ្នាទៅនឹងម្ចាស់បំណុលទូទៅដែលមិនត្រូវបានធានាដោយហ៊ីប៉ូតែក។

យ៉ាងណាមិញ ថ្ងៃកំណត់សងនៃសិទ្ធិលើបំណុលដែលត្រូវបានធានារបស់ $X_2$ គឺ ១ ឆ្នាំក្រោយកាលបរិច្ឆេទនៃការចែកចំណែក។ សិទ្ធិលើបំណុលដែលពេលកំណត់ពិតប្រាកដពុំទាន់ឈានចូលមកដល់ ត្រូវចាត់ទុកថា ពេលកំណត់សងបានចូលមកដល់ (ក្រមនីតិ/ណី មាត្រា ៤៩០ កថា.៦)។ ប៉ុន្តែ $X_2$ មិនអាចទទួលបានការប្រាក់ដែលកើតឡើងនៅក្រោយកាលបរិច្ឆេទនៃការចែកចំណែកនោះទេ។




**ចំនួនសិទ្ធិលើបំណុលរបស់ $X_3$ នៅកាលបរិច្ឆេទនៃការចែកចំណែក**

ចំនួនសិទ្ធិលើបំណុលរបស់ $X_3$ នៅកាលបរិច្ឆេទនៃការចែកចំណែក គឺមានតែប្រាក់ដើម ៥០០០ ដុល្លារប៉ុណ្ណោះ។ $X_3$ មិនមានសិទ្ធិប្រាតិភោគទេ ហេតុនេះ $X_3$ អាចទទួលបានចំណែក តែក្នុងករណីដែលមាននៅសល់ប្រាក់សម្រាប់ចែកចំណែក បន្ទាប់ពីការចែកចំណែកជាអាទិភាពទៅ $X_1$ និង $X_2$ រួចប៉ុណ្ណោះ។

យ៉ាងណាមិញ នៅកាលបរិច្ឆេទនៃការចែកចំណែក តុលាការអនុវត្តនឹងផ្អាកទុកចំណែក ដោយមិនធ្វើការចែកប្រាក់ទៅ $X_3$ ឡើយ (ក្រមនីតិ/ណី មាត្រា ៤៩៤ កថា.១ ចំណុច ខ) ព្រោះ ទោះបី $X_3$ បានធ្វើការរឹបអូសជាបណ្តោះអាសន្នរួចក៏ដោយ សិទ្ធិលើបំណុលរបស់ $X_3$ មិនទាន់មានសាលក្រម ឬសាលដីកា ជាដើម ដើម្បីបញ្ជាក់នោះទេ។ នៅពេលអនាគត $X_3$ ទទួលបានសាលក្រមឈ្នះក្តី ហើយនៅពេលដែល $X_3$ ដាក់សាលក្រមស្ថាពរនោះទៅតុលាការអនុវត្ត $X_3$ នឹងអាចទទួលបានចំណែក (ក្រមនីតិ/ណី មាត្រា ៤៩៥ កថា.១)

តើប្រាក់ ៧១០០០ ដុល្លារ ដែល Z បានបង់ទៅតុលាការអនុវត្តនោះ ត្រូវចែកចំណែកប៉ុន្មាន ទៅនរណាខ្លះ?

| | |
|---|---|
| ៥០០ ដុល្លារ៖ ត្រូវចែកចំណែកទៅឲ្យម្ចាស់បំណុលដែលបានចំណាយលើសោហ៊ុយសម្រាប់នីតិវិធី (ជាធម្មតាចែកចំណែកទៅឲ្យ $X_1$) | |
| ៤២០០០ ដុល្លារ៖ ត្រូវចែកចំណែកទៅឲ្យ $X_1$ (ប្រាក់ដើម ៣០០០០ ដុល្លារ និង ចំនួនទឹកប្រាក់នៃសំណងការខូចខាតដោយសារការយឺតយ៉ាវក្នុងអំឡុងពេល ២ឆ្នាំ ចុងក្រោយ ១២០០០ ដុល្លារ) | ៧១០០០ ដុល្លារ |
| ២៤០០០ ដុល្លារ៖ ត្រូវចែកចំណែកទៅឲ្យ $X_2$ (ប្រាក់ដើម ២០០០០ ដុល្លារ និង ចំនួនទឹកប្រាក់នៃសំណងការខូចខាតដោយសារការយឺតយ៉ាវក្នុងអំឡុងពេល ២ឆ្នាំ ចុងក្រោយ ៤០០០ ដុល្លារ) | |
| ៤៥០០ ដុល្លារ៖ ត្រូវចែកចំណែកទៅឲ្យ $X_1$ $X_2$ និង $X_3$ ដោយសមមាត្រទៅនឹងចំនួននៃសិទ្ធិលើបំណុលនីមួយៗ ។ | |

＊វិធីចែកចំណែកនៃប្រាក់ ៤៥០០ ដុល្លារ

នៅក្នុងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ $X_1$ ផ្នែកដែលមិនត្រូវបានចែកចំណែកជាអាទិភាព៖ ៣០០០ ដុល្លារ

នៅក្នុងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ $X_2$ ផ្នែកដែលមិនត្រូវបានចែកចំណែកជាអាទិភាព៖ ២០០០ដុល្លារ

ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ $X_3$ ៖ ៥០០០ ដុល្លារ

→ចំនួនទឹកប្រាក់នៃចំណែករបស់ $X_1$ ៖ ៤៥០០ × ៣០០០／១០០០០＝១៣៥០ ដុល្លារ

→ចំនួនទឹកប្រាក់នៃចំណែករបស់ $X_2$ ៖ ៤៥០០ × ២០០០／១០០០០＝៩០០ ដុល្លារ

→ចំនួនទឹកប្រាក់នៃចំណែករបស់ $X_3$ ៖ ៤៥០០ × ៥០០០／១០០០០＝២២៥០ ដុល្លារ

ប្រសិនបើ សោហ៊ុយសម្រាប់ការអនុវត្ត និងចំនួនទឹកប្រាក់នៃចំណែករបស់ម្ចាស់បំណុលនីមួយៗតាមការកំណត់ខាងលើ ត្រូវបានសរសេរជាលាយលក្ខណ៍អក្សរ ស្របទៅតាមក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៤៩០ កថាខណ្ឌទី ៤ នោះសេចក្តីព្រាងដើមនៃតារាងចែកចំណែកនឹងត្រូវបានបង្កើតឡើង។

**ដំណាក់កាលទី ២៩. ការបើកកាលបរិច្ឆេទនៃការចែកចំណែក និង ការអនុវត្តការចែកចំណែក៖** តុលាការអនុវត្ត ត្រូវបើកកាលបរិច្ឆេទនៃការចែកចំណែក និងអនុវត្តការចែកចំណែក។

**សំណួរទី ៤២៖ តើតុលាការអនុវត្ត ត្រូវធ្វើអ្វីខ្លះ នៅកាលបរិច្ឆេទនៃការចែកចំណែក?**

នៅក្នុងករណី ម្ចាស់បំណុលដែលទទួលការចែកចំណែកមានតែម្នាក់ ឬ ប្រាក់ដែលត្រូវចែកចំណែកទៅឲ្យម្ចាស់បំណុលលើសពី ២នាក់ អាចសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បាន នោះនៅកាលបរិច្ឆេទនៃការចែកចំណែក តុលាការអនុវត្តត្រូវធ្វើការចែកចំណែក និង បង់សោហ៊ុយសម្រាប់ការអនុវត្តទៅឲ្យម្ចាស់បំណុលទាំងអស់នោះ។ ប្រសិនបើ មានប្រាក់ដែលនៅសេសសល់ តុលាការអនុវត្តត្រូវប្រគល់ទៅឲ្យកូនបំណុលនៃការអនុវត្ត (ក្រមនីតិ/ណី មាត្រា ៤៨៩ កថា.១ វាក្យខណ្ឌទី២, កថា. ២)។

ចំពោះករណីក្រៅពីនេះ តុលាការអនុវត្ត ត្រូវបង្កើតតារាងចែកចំណែក (ក្រមនីតិ/ណី មាត្រា ៤៩០ កថា. ១)។ ចំណុចដែលត្រូវសរសេរនៅក្នុងតារាងចែកចំណែកត្រូវបានបញ្ញត្តនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៤៩០ កថាខណ្ឌទី ៤។ ការបង្កើតតារាងចែកចំណែក មានដំណើរការដូចខាងក្រោម៖

**(១) ការបង្ហាញ និង ការកែតម្រូវសេចក្តីព្រាងដើមនៃតារាងចែកចំណែក**

តុលាការអនុវត្ត ត្រូវយកសេចក្តីព្រាងដើមនៃតារាងចែកចំណែកដែលបានបង្កើតរួច មកបង្ហាញ រួចសួរយោបល់ម្ចាស់បំណុលនីមួយៗ និង កូនបំណុលនៃការអនុវត្ត។ បើមានភាពចាំបាច់ តុលាការអនុវត្ត អាចធ្វើការពិនិត្យភស្តុតាងជាឯកសារ ដែលអាចធ្វើការពិនិត្យភ្លាមៗបាន (ក្រមនីតិ/ណី មាត្រា ៤៩០ កថា. ៣)។ ផ្អែកលើព័ត៌មានដែលទទួលបាន តុលាការអនុវត្តត្រូវធ្វើការកែតម្រូវសេចក្តីព្រាងដើមនៃតារាងចែកចំណែក បើមានភាពចាំបាច់។

**(២) ការបង្កើតតារាងចែកចំណែក**

បន្ទាប់ពី តុលាការអនុវត្តបានបញ្ចប់ការកែតម្រូវសេចក្តីព្រាងដើមនៃតារាងចែកចំណែក និង បានចេញនូវលទ្ធផលចុងក្រោយរួច តុលាការអនុវត្តត្រូវធ្វើការកំណត់លំដាប់នៃម្ចាស់បំណុលនីមួយៗ និង ចំនួនទឹកប្រាក់នៃចំណែកដែលម្ចាស់បំណុលនីមួយៗត្រូវទទួលបាន រួចបង្កើតតារាងចែកចំណែក យោងតាមការកំណត់នៃក្រមរដ្ឋប្បវេណី ច្បាប់ដែលទាក់ទងនឹងពាណិជ្ជកម្ម ឬ ច្បាប់ផ្សេងទៀត (ក្រមនីតិ/ណី មាត្រា ៤៩០ កថា. ៥)។ ប៉ុន្តែនៅក្នុងករណីដែលម្ចាស់បំណុលទាំងអស់បង្ហាញខ្លួននៅកាលបរិច្ឆេទនៃការចែកចំណែក ហើយបានព្រមព្រៀងគ្នាអំពីការចែកចំណែក នោះវាក៏អាចមាន ករណីដែលខ្លឹមសារនៅក្នុងតារាងចែកចំណែកអំពីលំដាប់នៃម្ចាស់បំណុលនីមួយៗ និង ចំនួនទឹកប្រាក់នៃចំណែកដែលម្ចាស់បំណុលនីមួយៗត្រូវទទួលបាន មានភាពខុសទៅនឹងអ្វីដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ជាដើមដែរ (ក្រមនីតិ/ណី មាត្រា ៤៩០ កថា. ៥)។

**(៣) ការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក**

ម្ចាស់បំណុល ឬ កូនបំណុលដែលមានឧបាស្រ័យចំពោះតារាងចែកចំណែកដែលតុលាការអនុវត្តបានបង្កើត អាចថ្លែងសេចក្តីតវ៉ាបាន (ក្រមនីតិ/ណី មាត្រា ៤៩១ កថា. ១)។ តុលាការអនុវត្ត មិនចាំបាច់ធ្វើការកែប្រែតារាងចែកចំណែកទេ និង មិនត្រូវធ្វើការចែកចំណែកចំពោះផ្នែកដែលត្រូវបានតវ៉ានោះឡើយ។

យ៉ាងណាមិញ ម្ចាស់បំណុល ឬ កូនបំណុលនៃការអនុវត្តដែលបានថ្លែងសេចក្តីតវ៉ា ត្រូវដាក់ពាក្យបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ឬ ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារទៅតុលាការអនុវត្ត ហើយត្រូវបញ្ជាក់ថា បានដាក់ពាក្យបណ្តឹងក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ **ព្រោះបើមិនបានដាក់ពាក្យបណ្តឹងក្នុងអំឡុងពេលកំណត់នេះទេ គេនឹងចាត់ទុកថា ការតវ៉ានោះចំពោះការសរសេរលើតារាងចែកចំណែកត្រូវបានដកវិញ (ក្រមនីតិ/ណី មាត្រា ៤៩២ កថា. ៣, មាត្រា ៤៩៣ កថា. ៤)។ ដូច្នេះ ម្ចាស់បំណុល ឬ កូនបំណុលនៃការអនុវត្តដែលបានថ្លែងសេចក្តីតវ៉ា ត្រូវធ្វើសកម្មភាពឲ្យបានឆាប់រហ័ស ស្របតាមក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៤៩២ ឬ មាត្រា ៤៩៣។**

**(៤) ការអនុវត្តការចែកចំណែក**

តុលាការអនុវត្ត ត្រូវធ្វើការចែកចំណែកតែផ្នែកដែលគ្មានការតវ៉ា ដោយផ្អែកលើតារាងចែកចំណែក (ក្រមនីតិ/ណី មាត្រា ៤៩១ កថា.២)។ ចំពោះផ្នែកដែលត្រូវបានតវ៉ា ប្រសិនបើមិនមានការបញ្ជាក់ថា បានដាក់ពាក្យបណ្តឹងក្នុងអំឡុងពេល ១ សប្តាហ៍ គិតចាប់ពីកាលបរិច្ឆេទនៃការចែកចំណែកទេ នោះគេនឹងចាត់ទុកថា ការតវ៉ា

នោះចំពោះការសរសេរលើតារាងចែកចំណែកត្រូវបានដកវិញ   ហេតុនេះ  ផ្នែកដែលត្រូវបានតវ៉ានោះ  ក៏ត្រូវធ្វើការចែកចំណែកដែរ។

យ៉ាងណាមិញ  ចំពោះផ្នែកដែលមិនមានការតវ៉ាក៏ដោយ  ផ្នែកដែលមានមូលហេតុដូចដែលបានបញ្ញត្តនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី  មាត្រា  ៤៩៤  មិនត្រូវធ្វើការចែកចំណែកទេ  ហើយតុលាការអនុវត្តត្រូវផ្អាកទុកទឹកប្រាក់នោះសិន។   នៅក្នុងករណីដែលមិនមានមូលហេតុក្នុងការផ្អាកទុកទេ   តុលាការអនុវត្តត្រូវអនុវត្តការចែកចំណែកដោយផ្អែកតាមមាត្រា ៤៩៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

*******************************************